# ប្រទេសកម្ពុជា

ប្រទេសកម្ពុជា ជាប្រទេសប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដោយមានរដ្ឋាភិបាល កើតចេញ ពីការបោះឆ្នោត។ នៅថ្ងៃទី ១៤ ខែ តុលា ស្តេចក្រុមឃុនសីហមុនី ត្រូវបានជ្រើសរើសដោយ ក្រុមប្រឹក្សារាជបល្ល័ង្គ អោយស្នងរាជពីព្រះបិតារបស់ព្រះអង្គ ធ្វើជាព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ និងជាព្រះប្រមុខរដ្ឋ។ ការបោះឆ្នោត តំណាងរាស្ត្រថ្មីបំផុត បានធ្វើឡើងនៅខែកក្កដា ២០០៣។ អំពើហឹង្សាមានលក្ខណៈនយោបាយ រួមទាំងការសំលាប់ផង មានការថយចុះខ្លាំង បើប្រៀបធៀបទៅនឹងការ បោះឆ្នោតពីលើកមុនៗ ប៉ុន្តែការគំរាមគំហែងអ្នកបោះឆ្នោត ដោយអាជ្ញាធរមូលដ្ឋាន នឹងបញ្ហាបច្ចេក ទេសពាក់ព័ន្ធទៅនឹងដំណើរការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីឈ្មោះអ្នក បោះឆ្នោត បានធ្វើអោយ ប្រជាពលរដ្ឋជាច្រើនបាត់បង់សិទ្ធិបោះឆ្នោត។ ក្នុងការបោះឆ្នោតនោះ គណបក្សប្រជាជនកម្ពុជា បានទទួល ៧៣អសនៈ នៅក្នុងអសនៈរដ្ឋសភាជាតិដែលមានចំនួនសរុប១២៣អសនៈ។ គណបក្សរាជានិយម ហ៊្វុនស៊ិនប៉ិច ទទួលបាន ២៦អសនៈ ហើយគណបក្សសមរង្ស៊ីបានទទួល ២៤ អសនៈ។ គណបក្សប្រជាជន កម្ពុជា និងហ៊្វុនស៊ិនប៉ិចបាន បង្កើតរដ្ឋាភិបាលចំរុះមួយ ក៏ប៉ុន្តែគណបក្សប្រជាជនកម្ពុជា ជាអ្នកមានអំណាច ត្រួតត្រាលើរដ្ឋាភិបាលនេះ។ គណបក្ស សមរង្ស៊ីដើរតួនាទីជាគណបក្ស ប្រឆាំងយ៉ាងសកម្មមួយ ប៉ុន្តែមិនត្រូវ បានគេអនុញ្ញាត អោយមានសមាជិកភាពនៅក្នុង គណៈកម្មការ នានានៃរដ្ឋសភាឡើយ។ ទោះបីជាច្បាប់បាន ចែងអំពីឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌ក៏ដោយ ក៏ក្នុងការ អនុវត្តជាក់ស្តែង ប្រព័ន្ធយុត្តិធម៌នេះជារឿយៗ បានទទួលរងឥទ្ធិពលពីស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រត្តិបត្តិ ព្រមទាំងមាន អំពើពុករលួយផងដែរ។

នគរបាលជាតិ ដែលជាភ្នាក់ងាររបស់ក្រសួងមហាផ្ទៃ មានកាតព្វកិច្ចចំបង ក្នុងការថែរក្សា សន្តិសុខក្នុងផ្ទៃ ប្រទេស។ កងរាជអាវុធហត្ថ ត្រូវបានអនុញ្ញាតអោយធ្វើការចាប់ខ្លួនជនស៊ីវិលបាន លុះត្រាតែមានការអនុញ្ញាតិពី អាជ្ញាធរមូលដ្ឋាន។ ជាធម្មតា អាជ្ញាធរស៊ីវិលជាអ្នកគ្រប់គ្រងទៅលើ កងកំលាំងសន្តិសុខ ក៏ប៉ុន្តែនៅក្នុងការអនុវត្ត ជាក់ស្តែង កងកំលាំងសន្តិសុខនេះ បែរជាបំរើផលប្រយោជន៍ ថ្នាក់ដឹកនាំនៃគណបក្សប្រជាជនទៅវិញ។ សមាជិកខ្លះ នៃកងកំលាំងសន្តិសុខ បានប្រព្រឹត្តអំពើរំលោភសិទ្ធិ មនុស្សយ៉ាងធ្ងន់ធ្ងរ។

ប្រទេសកម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចទីផ្សារសេរី។ ប្រជាជនប្រហែលជា ៨០% នៃចំនួនប្រជាជនសរុប ១៣,៨ លាននាក់ ប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ យោងទៅតាមតួលេខផ្លូវការ ប្រាក់ចំនូលប្រចាំឆ្នាំ២០០៣ សំរាប់មនុស្សម្នាក់គឺ ២៩៧ដុល្លាអាមេរិក។ តួលេខនេះមិនបានឆ្លុះបញ្ចាំង អោយបានត្រឹមត្រូវ អំពីលទ្ធភាពទិញដូរឡើយ (purchasing power) ជាពិសេសនៅតាមទីប្រជុំជន។ ជំនួយបរទេសគឺជាផ្នែកមួយយ៉ាងសំខាន់ សំរាប់ហិរញ្ញវត្ថុជាតិ ដោយក្នុងនោះ យ៉ាងហោចណាស់ ៥០% នៃថវិការរដ្ឋ បានមកពីជំនួយបរទេស។ នៅក្នុងឆ្នាំ២០០៣ អត្រាកំណើនពិតនៃសេដ្ឋកិច្ចជាតិ ត្រូវបានគេប៉ាន់ប្រមាណថា ប្រហែលជា ៥,២% ហើយគេរំពឹងទុកថានឹងកើនឡើងដល់ ៤,៥% នៅក្នុងឆ្នាំនេះ។ ប្រទេសកម្ពុជាមានការលូតលាស់យ៉ាងខ្លាំង ខាងឧស្សាហកម្មនាំចេញផលិតផលសំលៀកបំពាក់ ក៏ប៉ុន្តែកម្ពុជា មានការលំបាកក្នុងការទាក់ទាញវិនិយោគទុនបរទេស ដោយសារតែមានអំពើពុករលួយ និងការខ្វះខាតខាងប្រព័ន្ធច្បាប់ ដែលអាចអោយអនុវត្តបាន។

ការគោរពសិទ្ធមនុស្សរបស់រដ្ឋាភិបាល នៅមានភាពទន់ខ្សោយ ហើយរដ្ឋាភិបាលនៅតែប្រព្រឹត្តអំពើរំលោភ បំពានជាច្រើន។ នៅក្នុងកំឡុងឆ្នាំនេះ អង្គការមិនមែនរដ្ឋាភិបាលបានប៉ាន់ស្មានថា យ៉ាងតិចណាស់ មានការសំលាប់ ទាក់ទងនឹងនយោបាយ បួនករណី ហើយនិងការសំលាប់ដែលត្រូវបានគេចោទថាមានលក្ខណៈនយោបាយ ចំនួនបីករណីបើទោះបីជាគេពិបាកនឹងដឹងអោយបានប្រាកដអំពីបំណង នៃការសំលាប់នោះក៏ដោយ។ បុគ្គលិកយោធា និងនគរបាល ជាអ្នកទទួលខុសត្រូវចំពោះឃាតកម្មទាំងឡាយ ទាំងឃាតកម្មនយោបាយ និងមិនមែននយោបាយ។ ក៏ប៉ុន្តែគ្មានភស្តុតាង ដែលគួរអោយជឿបានណាមួយ បញ្ជាក់ថា ការធ្វើឃាតទាំងអស់នេះ មានការអនុញ្ញាតិជាផ្លូវការឡើយ។ មានរបាយការណ៍ គួរអោយជឿបានមួយចំនួនបាននិយាយថា សមាជិកខ្លះរបស់កងកំលាំងសន្តិសុខ បានវ៉ាយ រឺក៏ធ្វើបាប បុគ្គលដែលនៅក្នុងឃុំដើម្បីគាបយកចំលើយសារភាព។ មន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ជាញឹកញាប់មិនមានឆន្ទៈនយោបាយ និងថវិកា ដើម្បីចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ប្រឆាំងនឹងសមាជិកកងកំលាំងសន្តិសុខ ដែលគេ សង្ស័យថាបានរំលោភសិទ្ធមនុស្សទេ។ ទន្ទឹមនឹងនោះ ក៏មានឃាតកម្មនយោបាយខ្លះបានប្រព្រឹត្តឡើងដោយបុគ្គលផ្សេងៗ ដែលមិនមែនជាសមាជិកកងកំលាំងសន្តិសុខដែរ។ ស្ថានភាពពន្ធនាគារនៅមានសភាពយ៉ាប់យឺន ហើយរដ្ឋាភិបាលនៅ តែបន្តការចាប់ខ្លួនតាមទំនើងចិត្ត ព្រមទាំងចាប់ឃុំខ្លួនជនសង្ស័យមុនធ្វើការវិនិច្ឆ័យទោស យូរលើសរយៈពេលកំណត់។ ស្ថាប័នប្រជាធិបតេយ្យនានា ជាពិសេស

ស្ថាប័នយុត្តិធម៌ នៅតែមានភាពទន់ខ្សោយដដែល។ ឃាតកម្មជាច្រើនដែលទាក់ ទងនឹងរឿងនយោបាយ កម្រនឹងត្រូវបានកាត់ទោសណាស់។ ជាញឹកញាប់ ប្រជាពលរដ្ឋចូលខ្លួនក្នុងតុលាការ ដោយមិនមានមេធាវីការពារក្តី ដែលជាហេតុធ្វើអោយគេត្រូវបាត់បង់សិទ្ធិ ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌។ រដ្ឋាភិបាលបានត្រួតពិនិត្យលើខ្លឹមសារនៃការផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុជាច្រើន។ អាជ្ញាធរតែងតែ រំខានដល់សិទ្ធនៃការប្រមូលផ្តុំ។ ការរើសអើងនៅក្នុងសង្គម ប្រឆាំងនឹងស្ត្រីភេទ នៅតែចោទជាបញ្ហានៅ ឡើយ ក្នុងខណៈដែលអំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រី និងការរំលោភសិទ្ធិកុមារ កើតមានជាហូរហែ។ ស្របពេលគ្នានេះដែរ មានបញ្ហាទំនាស់ដីធ្លី កើតមានជាញឹកញាប់ ហើយរដ្ឋាភិបាលនិងតុលាការពុំបានដោះស្រាយវិបត្តិនេះអោយមានភាពយុត្តិធម៌ទេ។ ទោះបីជា ចំនួនសហជីពបានកើនឡើងនិងមានសកម្មភាពសកម្មជាងមុនក៏ដោយ ក៏សកម្មភាពប្រឆាំងនឹងសហជីព ដោយនិយោជក និងការមិនអនុវត្តន៍ច្បាប់ការងារ ដោយអាជ្ញាធរ នៅតែមានបន្ត។ ពលកម្មកុមារដោយបង្ខំ នៅតែជាបញ្ហានៅក្នុងផ្នែកខ្លះនៃសេដ្ឋកិច្ចជាតិ។ ការជួញដូរស្ត្រីភេទនិងកុមារ ក្នុងស្រុកនិងឆ្លងកាត់ព្រំដែន រួមទាំងការនាំយកទៅធ្វើជាពេស្យាចារផង គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ។

## ការគោរពសិទ្ធិមនុស្ស

### ១. ការគោរពចំពោះសិទ្ធិសេរីភាពនិងសេចក្តីថ្លៃថ្នូរបស់បុគ្គលរួមមានៈ

ក. ការផ្តាច់ជីវិតដោយបំពាននិងមិនស្របច្បាប់

អង្គការមិនមែនរដ្ឋាភិបាលបានប៉ាន់ស្មានថាមានករណីសំលាប់នយោបាយចំនួនបួន និងករណីដែលអាចជាការ សំលាប់នយោបាយ ចំនួនបីនៅក្នុងឆ្នាំនេះ។

នៅខែមករា សកម្មជនគណបក្សសមរង្ស៊ីចំនួនបីរូប ត្រូវបានគេបាញ់សំលាប់ក្នុងករណីចំនួនពីរដាច់ដោយឡែកពី គ្នា។ នៅថ្ងៃទី ១០ ខែមករា ខ្មាន់កាំភ្លើងបានបាញ់សំលាប់សកម្មជនម្នាក់នៅក្នុងខេត្តកំពង់ចាម។ ជនសង្ស័យម្នាក់ត្រូវបាន ប៉ូលីសចាប់ខ្លួន និងចោទប្រកាន់អោយមានទោសនៅខែកក្កដា ក្រោយពីសវនាការមួយ ដែលធ្វើដោយតុលាការនៅខេត្ត។ ថ្ងៃទី១៥ ខែមករា សកម្មជនពីររូបផ្សេងទៀត ត្រូវបានគេសំលាប់នៅផ្ទះរបស់ពួកគេ នៅក្នុងខេត្តបន្ទាយមានជ័យ។ ក្នុងករណីនេះ ជនសង្ស័យចំនួនប្រាំពីររូបត្រូវបានចាប់ខ្លួន ហើយបានសារភាពថាបានប្លន់ និងធ្វើមនុស្សឃាត។ យ៉ាងហោច

ណាស់ក៏មានបួននាក់ក្នុងចំនោមជនសង្ស័យទាំងនោះ ជាសមាជិកនៃគណបក្សប្រជាជន។ ប្រាំនាក់ក្នុងចំនោមជនសង្ស័យប្រាំពីរនាក់ ត្រូវបានគេដោះលែង ជនសង្ស័យពីនាក់ត្រូវគេកាត់អោយមានទោស មនុស្សឃាត ហើយគេទាំងពីរ ត្រូវបានកាត់ទោសអោយជាប់ពន្ធធានាគារ ចំនួន១៧ឆ្នាំហើយនិងពិន័យជាប្រាក់ចំនួន ៥000 ដុល្លារ (ម្ភៃលានរៀល) ដើម្បីជា សំណងដល់គ្រួសារជនរងគ្រោះ។

នៅថ្ងៃទី ២២ ខែមករា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លោក ជា វិជ្ជាត្រូវបានគេបាញ់ សំលាប់នៅក្បែរផ្លូវដែលមានមនុស្សច្រើន នៅទីក្រុងភ្នំពេញ។ លោក ជា វិជ្ជា ជាសកម្មជនសហជីព ដែលមាន សមានចិត្តជាមួយគណបក្សសមរង្ស៊ី។ ការចោទប្រកាន់ត្រូវបានគេធ្វើឡើងចំពោះបុគ្គលពីររូប ក្នុងករណីនេះ ប៉ុន្តែត្រូវបានគេលើកលែងការចោទប្រកាន់វិញ ដោយសារថាគ្មានភស្តុតាងគ្រប់គ្រាន់។ ចៅក្រមស៊ើបអង្កេត ដែលបានលើកលែងការចោទប្រកាន់នោះ ត្រូវបានគេផ្ទេរការងារ ហើយព្រះរាជាអាជ្ញាបានធ្វើការជំទាស់ ចំពោះការលើកលែងការ ចោទប្រកាន់នេះ។ សាលាឧទ្ធរណ៍បានធ្វើការបដិសេធចំពោះការលើកលែងនេះ ហើយបានបញ្ជាអោយតុលាការក្រុង បន្តការស៊ើបអង្កេត។ នៅចុងឆ្នាំនេះ ជនសង្ស័យទាំងពីររូប ស្ថិតនៅក្នុងការឃុំខ្លួននៅឡើយ ដោយរងចាំការស៊ើបអង្កេត បន្ត។

នៅថ្ងៃទី ២៥ ខែមករា ជនដៃដល់មិនស្គាល់អត្តសញ្ញាណ បានបាញ់សំលាប់មេភូមិរងនៃគណបក្សហ្វុនស៊ិនប៉ិច នៅក្នុងខេត្តកំពត។ ជនដៃដល់នោះបានរត់គេចខ្លួន ចេញពីកន្លែងកើតហេតុបន្ទាប់ពីការបាញ់ប្រហារហើយរហូតដល់ ចុងឆ្នាំនេះ កំពុងគេចខ្លួននៅឡើយ ។ គេបានចេញដីការចាប់ខ្លួនហើយ។

នៅថ្ងៃទី ០៧ ខែឧសភា លោក រស់ សុវណ្ណារេត ជាមេសហជីពរោងចក្រ ត្រូវបានគេសំលាប់ នៅទីក្រុងភ្នំពេញ។ មានបុរសពីរនាក់ជិះម៉ូតូ បានជិះមកក្បែរម៉ូតូជនរងគ្រោះ ហើយបាញ់សំលាប់តែម្តង។ ទាហានម្នាក់មកពីអង្គភាពកង ឆត្រ័យោង ត្រូវបានគេចាប់ខ្លួនជាជនសង្ស័យក្នុងការសំលាប់នេះ។ ជនសង្ស័យនេះកំពុងតែរងចាំសាវនាការកាត់ទោស។

ការចោទប្រកាន់ចំពោះអំពើឃាតកម្មដែលពាក់ព័ន្ធនឹងរឿងនយោបាយ នៅតែបន្តមាន ទាំងមុននិងក្រោយការ បោះឆ្នោតសភា នៅខែកក្កដា។ អង្គការក្រៅរដ្ឋាភិបាលបានធ្វើការប៉ាន់ប្រមាណថាមានករណីឃាតកម្មដែលអាចមាន ទំនាក់ទំនងនឹងរឿងនយោបាយចំនួន៣៣ករណី។ ប៉ុន្តែជារឿយៗ វាមានការលំបាក ក្នុងការកំណត់ថា តើគោលបំនង នៃការសំលាប់ទាំងនេះ មានការទាក់ទងនឹង

រឿងនយោបាយដែររឺយ៉ាងណានោះ។ ឧទាហរណ៏ កាលពីថ្ងៃទី៦ ខែកុម្ភៈ ២០០៣ ប្រធានសង្ឃជាន់ខ្ពស់ព្រះសង្ឃសំ ប៊ុនធឿននៃភ្នំអដ្ឋរសត្រូវគេសំលាប់។ គាត់បានចូលរួមយ៉ាងសកម្ម ក្នុងការជំរុញលើកទឹកចិត្ត អោយព្រះសង្ឃទៅចូលរួមបោះឆ្នោតជ្រើស រើសតំណាងរាស្រ្ត បន្ទាប់ពីសម្តេចសង្ឃរាជដែលគាំទ្រ គណបក្សប្រជាជនបានហាមឃាត់មិនអោយព្រះសង្ឃទៅចុះឈ្មោះបោះឆ្នោត។ គ្មានជនសង្ស័យណាម្នាក់ ត្រូវបានចាប់ ខ្លួនទេ។ យោងតាមសម្តីអាជ្ញាធរ ការស៊ើបអង្កេតនៅតែបន្តមាន។ នៅថ្ងៃទី១៨ ខែកុម្ភៈ ២០០៣ បុរសប្រដាប់ ដោយអាវុធពីរនាក់ បានបាញ់លោក ឱម រ័ត្នសាឌី ដែលជាទីប្រឹក្សាផ្នែកកិច្ចការបរទេសរបស់ព្រះប្រធានរដ្ឋសភា ព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ។ ឃាតកម្មនេះត្រូវបានមជ្ឈដ្ឋានទូទៅជឿថា បង្កឡើងដោយហេតុផលនយោបាយ ប៉ុន្តែប៉ូលីសបានចាប់ខ្លួនទាហានកងយោធពលខេមរភូមិន្ទ២នាក់ ដែលបានសារភាពថា គេបានបាញ់លោក ឱម រ័ត្នសាឌី ក្នុងបំណងប្លន់យកទូរស័ព្ទដៃរបស់គាត់។ នៅខែតុលា ២០០៣ តុលាការក្រុង បានកាត់ទោសនាយទាហានទាំងពីរនាក់ នោះអោយជាប់ ពន្ធនាគារ២០ឆ្នាំ។ ទោះជាមានការកាត់ទោសនេះក្តី មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដទៃទៀតបានសង្ស័យថា ជនដែលត្រូវគេកាត់ទោសទាំងពីរនាក់នោះមិនមែនជាឃាតករ ពិតប្រាកដទេ។ នៅថ្ងៃទី៦ខែសីហា ២០០៣ ក្មេងស្រីអាយុ ១៦ឆ្នាំដែលជាកូនរបស់សកម្មជនគណបក្សសមរង្ស៊ី ត្រូវបានមេភូមិដែលគាំទ្រគណបក្សប្រជាជនបាញ់សំលាប់។ ប៉ូលីសបានចាប់ខ្លួនមេភូមិរូបនោះហើយ ប៉ុន្តែមន្ត្រីតុលាការបានចេញ បញ្ជាអោយគ្រួសារជនរងគ្រោះទទួលយកសំណងជាទឹកប្រាក់ និងការព្យួរទោសចំនួន២ឆ្នាំ។ សកម្មជនគណបក្សសមរង្ស៊ី បានដាក់ពាក្យបណ្តឹងទៅសាលាឧទ្ធរណ៏ ហើយនាំគ្រួសាររបស់គាត់ ទៅកន្លែងផ្សេង ដើម្បីចៀសវាងការសងសឹក ចំពោះការដែលគាត់បានដាក់ពាក្យបណ្តឹងនោះ។ មកទល់ដំណាច់ឆ្នាំ ករណីនោះនៅតែមិនទាន់បានសំរេចនៅឡើយទេ។ នៅថ្ងៃ ទី១៨ខែតុលា ២០០៣ លោក ជួ ជេតថារិទ្ធ ដែលជាអ្នករាយការណ៏អោយវិទ្យុតាព្រហ្មដែលគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច និងជាមន្ត្រីមកពីគណបក្សហ៊្វុនស៊ិនប៉ិចនៅក្រសួងមហាផ្ទៃ ត្រូវបានក្មាន់កាំភ្លើង ពីរនាក់បាញ់សំលាប់នៅមុខស្ថានីយវិទ្យុ។ រហូតមកទល់ចុងឆ្នាំនេះ នៅមិនទាន់មានជនសង្ស័យណាម្នាក់ត្រូវបានចាប់ខ្លួននៅឡើយទេ។ គ្រួសាររបស់គាត់ បានចាក

ចេញពីប្រទេសកម្ពុជាហើយ ។ វិទ្យុតាព្រហ្មតែងតែធ្វើការរិះ គន់ចំពោះរដ្ឋាភិបាល ហើយការបាញ់ប្រហារនេះ កើតឡើង នៅរយៈ៤ថ្ងៃ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានធ្វើការព្រមានជាសាធារណៈ ដល់គណបក្សហ៊្វុនស៊ិនប៉ិច អោយ មេដឹកនាំគណបក្ស ធ្វើការត្រួតពិនិត្យចំពោះប្រព័ន្ធផ្សព្វផ្សាយពតិមានរបស់ខ្លួន ។

នៅឆ្នាំ២០០២ ប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតឃុំសង្កាត់ជាលើកដំបូង ។ ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) បានរាយការណ៍ថា នៅមុនការបោះឆ្នោត មានសកម្មជននយោបាយ២២នាក់ (៥ នាក់នៅឆ្នាំ២០០០ ១២នាក់នៅឆ្នាំ២០០១ និង៥នាក់នៅឆ្នាំ ២០០២) រាប់បញ្ចូល ទាំងបេក្ខជននិងសមាជិកគ្រួសារ ត្រូវបានគេសំលាប់ក្នុង២០ករណីផ្សេងៗគ្នា ក្នុងស្ថានភាពដែលគួរអោយសង្ស័យ ។ ក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្សយល់ ស្របគ្នាថា មានយ៉ាងហោចណាស់៧ករណីនៃករណីទាំងនោះ កើតឡើងដោយហេតុផលនយោបាយ ។ UNHCHR រាយការណ៍ថា ការស៊ើបអង្កេតរបស់ប៉ូលីសលើករណី ឃាតកម្មទាំងនេះមានចំណុចខ្វះខាតជាច្រើន ។

នៅក្នុងឆ្នាំ២០០៤នេះ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា មានសមាជិកនៃកំលាំងទាហាន កងរាជអាវុធ ហត្ថ និងនគរបាល បានពាក់ព័ន្ធក្នុងការសំលាប់ក្រៅច្បាប់ចំនួន៦៦ករណី ។ អាជ្ញាធរបានធ្វើការប្តឹងបាន ៩០ភាគរយ នៃ ករណីទាំងអស់ ប៉ុន្តែមានតែ ៥ ភាគរយទេ ដែលឈានទៅដល់ការកាត់ទោស ។

ថ្ងៃទី ១៨ ខែ សីហា សមាជិកនៃកងយោធាម្នាក់បានស្លាប់ ដោយរបួសស្នាមពីការវាយដំធ្ងន់ធ្ងរ ។ មេបញ្ជាការ របស់គាត់ និងបងប្អូនថ្លៃនៃមេបញ្ជាការនោះ ដែលត្រូវបានគេឃើញជូនជនរងគ្រោះដាក់ផ្ទះរបស់គាត់ ក្រោយពីគាត់ មានរបួសស្នាម ត្រូវបានគេសង្ស័យថាមានជាប់ពាក់ព័ន្ធទៅនឹងការវាយដំនោះ ។ នៅពាក់កណ្តាលខែធ្នូ តុលាការខេត្ត ក្រចេះ ដែលជាកន្លែងកើតហេតុ បានចេញដីកាចាប់ខ្លួនជនសង្ស័យទាំងពីរអ្នកនោះហើយ ។ ជនសង្ស័យទាំងនោះ បាន បង្ហាញមុខនៅតុលាការនៅចុងខែធ្នូ ហើយកំពុងតែត្រូវឃុំខ្លួនរងចាំការស៊ើបសង្កេត ។

នៅខែកក្កដា អ្នកទោសម្នាក់ដែលរងចាំការកាត់ទោស ត្រូវបានគេវាយដំរហូតដល់ស្លាប់ ។ មន្ត្រីនគបាលដែល គេសង្ស័យថាបានធ្វើការវាយដំនោះ ជាសាច់ញាតិនៃភាគីនៅក្នុងជម្លោះ ដែលទាក់ទងទៅនឹងអ្នកទោសនោះ ។ ការប្តឹងផ្តល់ តាមផ្លូវច្បាប់

មិនត្រូវបានគេធ្វើឡើងចំពោះមន្ត្រីប៉ូលីសនោះឡើយ ហើយមានរបាយការណ៍មកថា គាត់ត្រូវបានគេផ្ទេរទៅធ្វើការកន្លែងផ្សេងទៀត។

នៅខែមិថុនា ឆ្នាំ២០០៣ ប៉ូលីសបង្ក្រាបបាតុកម្ម បានបាញ់សំលាប់អ្នកធ្វើកូដកម្មរបស់សហជីពម្នាក់នៅក្នុងពេល បាតុកម្ម។ ប៉ូលីសម្នាក់បានស្លាប់នៅក្នុងហេតុការណ៍ជាមួយគ្នានោះដែរ។

ចំនួនអ្នករងគ្រោះដោយសារគ្រាប់មីននៅតែខ្ពស់ដដែល។ ក្នុងចន្លោះខែមករា និង វិច្ឆិកា មានករណីគ្រោះថ្នាក់ ដោយសារគ្រាប់មីនចំនួន៣២២ករណី ហើយនិង ៤៧៧ ករណីដោយសារគ្រប់មិនទាន់ផ្ទុះ។ នៅឆ្នាំ២០០៣ មានចំនួន អ្នករងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះមាន៧៧២ ករណី និង ៨៤៧ករណីនៅឆ្នាំ ២០០២។

ក្នុងកំឡុងឆ្នាំ២០០៣ មានការសំលាប់ឥស្សរជនជាន់ខ្ពស់ ដោយឃាតករមិនស្គាល់មុខមួយចំនួន។ ជាឧទាហរណ៍ ថ្ងៃទី២២ ខែមេសា ២០០៣ ចៅក្រម សុខ សេថាមុនី នៃតុលាការក្រុងភ្នំពេញ ត្រូវបានគេបាញ់សំលាប់នៅក្នុងរថយន្ត របស់គាត់ ក្នុងពេលដែលគាត់កំពុងធ្វើដំណើរទៅធ្វើការ។ ក្រោយមក កងរាជអាវុធហត្ថជាតិបានចាប់ខ្លួនជនសង្ស័យ ៣នាក់ ដែលប៉ូលីសបានអះអាងថាមានជាប់ទាក់ទងនឹងចលនាកងទ័ពសេរីជាតិកម្ពុជា (CFF)។ នៅខែមេសា ជនសង្ស័យ ត្រូវបានគេដោះលែង ដោយមូលហេតុខ្វះភស្តុតាង។ គ្មានការចាប់ខ្លួនជនសង្ស័យដ៏ទៃទៀតឡើយ។

កញ្ញា ទូច ស្រីនិច ដែលជាអ្នកចំរៀងដ៏ល្បីម្នាក់ ហើយដែលបានច្រៀងនូវចំរៀងជាច្រើន ដែលមានអត្ថន័យ នយោបាយគាំទ្រគណបក្សហ្វ៊ុនស៊ិនប៊ិច ត្រូវបានខ្មាន់កាំភ្លើងមិនស្គាល់អត្តសញ្ញាណ បាញ់បីដងនៅចុងឆ្នាំ ២០០៣។ កញ្ញា ស្រីនិច បានរួចផុតពីការបាញ់ប្រហារនោះ ប៉ុន្តែត្រូវពិការមិនអាចកំរើកបាន។ ម្តាយរបស់នាងត្រូវបានស្លាប់ នៅក្នុងឧប្បទវហេតុនេះ។ អំពើវាយប្រហារនេះ ត្រូវបានគេយល់ថា ជាអំពើពាក់ព័ន្ធ នឹងនយោបាយ រីឯអ្នកខ្លះទៀត បានចោទប្រកាន់ថាជារឿងផ្ទាល់ខ្លួន។ រហូតដល់ចុងឆ្នាំនេះ មិនមានការចាប់ខ្លួននរណាម្នាក់ទេ ក្នុងករណីនេះ។

នៅខែតុលា ២០០៣ សាលាឧទ្ធរណ៍បានបើកសាវនាការម្តងទៀត កាត់ទោសលោកឈូក រិន ដែលជា អតីត មេបញ្ជាការខ្មែរក្រហម

អំពីតួនាទីរបស់គាត់នៅក្នុងការវាយប្រហាររថភ្លើងកាលពីឆ្នាំ១៩៩៤ ។ ខែបន្ទាប់មកទៀត សាលាឧទ្ធរណ៍បានសំរេចកាត់ទោសលោកឈូករិន អោយជាប់ពន្ធនាគាមួយជីវិត។ មេធាវីរបស់លោកឈូក រិន បាន ដាក់ពាក្យបណ្តឹងសារទុក្ខទៅតុលាការកំពូល។ ដោយហេតុថា តុលាការក្រុងបានសំរេចថាលោកឈូករិនគ្មានទោស តាំងពីដំបូងមកហើយនោះ ច្បាប់បានកំនត់ថា គាត់អាចនឹងមិនត្រូវបានគេដាក់ពន្ធនាគារទេ លុះត្រាតែ តុលាការ កំពូលសំរេចថាគាត់មានទោស។ ករណីនេះស្ថិតនៅការរងចាំការកាត់ទោសនៅតុលាការកំពូលនៅឡើយ នៅចុង ឆ្នាំនេះ។

ការកាត់ទោសរកយុត្តិធម៌ដោយមហាជនដែលមិនមានជំនឿលើប៉ូលីស (តុលាការរាស្ត្រ) និង ឃាតកម្មលើ អ្នកដែលគេចោទថាចេះអាបធ្មប់ នៅតែបន្តមាននៅក្នុងឆ្នាំ២00៤។ អំពើហឹង្សាបែបតុលាការរាស្ត្រដែលមានហ្វូង មនុស្សធ្វើការចាប់ខ្លួន និងវាយដំ លើអ្នកដែលគេសង្ស័យថាជាចោរ នៅកន្លែងកើតហេតុនោះ មាន ២៦ ករណី និង បណ្តាលអោយស្លាប់ចំនួន ១៩ នាក ់ក្នុងឆ្នាំនេះ។ នៅខែមិថុនា មានមនុស្ស បីរូបត្រូវបានគេសំលាប់ ក្រោយពី ប្រជាពលរដ្ឋចោទប្រកាន់ថាចេះ អាបធ្មប់។ ជនសង្ស័យពីរនាក់ត្រូវបានគេចាប់ខ្លួន។ នៅខែសីហា គ្រូខ្មែរម្នាក់ត្រូវ បានគេបាញ់សំលាប់នៅនឹងផ្ទះរបស់គាត់ ប្រជាពលរដ្ឋនៅក្បែរនោះជឿថាគាត់ចេះអាបធ្មប់។ ការកាត់ទោសរបស់ រដ្ឋាភិបាល ចំពោះជនដែលទទួលខុសត្រូវចំពោះអំពើហឹង្សាទាំងនេះ មានតិចតួចបំផុត។

### ខ. ការបាត់ខ្លួន

គេពុំឃើញមានរបាយការណ៍អំពីការបាត់ខ្លួនដែលទាក់ទងនឹងរឿងនយោបាយទេ។

### គ. ការធ្វើទារុណកម្ម និងធ្វើបាប រឺដាក់ទោសទណ្ឌដែលមានលក្ខណៈសាហាវ អមនុស្សធម៌ និងបន្ទាប បន្ថោកផ្សេងៗ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហាមប្រាមការធ្វើបាប រឺទារុណកម្មលើរាងកាយអ្នកទោសក្នុងពន្ធនាគារ។ ទោះជាយ៉ាងនេះក្តី ការធ្វើទារុណកម្ម វាយដំ និងការធ្វើបាបលើរាងកាយដ៏ទៃទៀត លើអ្នកដែលត្រូវឃុំខ្លួន នៅតែបន្ត ជាបញ្ហាដ៏ធ្ងន់ធ្ងរ។ ក្នុងកំឡុងឆ្នាំ ២00៤ មានរបាយការណ៍ដែលគួរអោយជឿបានថាកំលាំងយោធា រឺ មន្ត្រីប៉ូលីស បានប្រើប្រាស់ការធ្វើទារុណកម្មផ្នែករាងកាយនិងផ្លូវចិត្ត និងការវាយធ្វើបាបជនល្មើសដែលនៅក្នុងឃុំយ៉ាងដំណំ ជា ពិសេស នៅពេលសួរចំលើយ។

អង្គការក្រៅរដ្ឋាភិបាលមួយបានរាយការណ៏ថា នៅក្នុង ការសម្ភាសន៏ ជាមួយអ្នកទោស នៅពន្ធនាគារចំនួន១៨ មានអ្នកទោស១០៦នាក់បានអះអាងថាពួកគេត្រូវបាន គេធ្វើទារុណកម្ម ហើយ ៦៥ នាក់ត្រូវគេ ធ្វើទារុណកម្មក្នុងខណៈពេលដែលឋិតក្រោមការឃុំខ្លួនរបស់នគរបាល ហើយចំនួន ៤១នាក់ នៅពេលស្ថិតនៅក្នុង ពន្ធនាគារ។ សមាជិកនគបាល និងកំលាំងសន្តិសុខដែលបានប្រព្រឹត្តអំពើរំលោភ តែងតែត្រូវបានគេការពារ អោយ រួចផុតពីការកាត់ទោស និងចំណាត់ការវិន័យដោយអាជ្ញាធរមូលដ្ឋាន បើទោះបីជាមានកិច្ចខំប្រឹងប្រែងពីរដ្ឋាភិបាល កណ្តាល និងការទប់ស្កាក់ រឺលប់បំបាត់ការរំលោភសិទ្ធិអ្នកទោស និងការកែរលំអនូវបញ្ហាគណនេយ្យភាពក្តី។

ស្ថានភាពពន្ធនាគាមិនបានឆ្លើយតបទៅនឹងស្តង់ដាអន្តរជាតិទេ ហើយមានលក្ខណៈគំរាមកំហែងដល់ជីវិត។ នាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ជាអ្នកទទួលខុសត្រូវទាំងចំពោះអ្នកដែលត្រូវឃុំខ្លួន មុនការកាត់ទោស និងទាំងអ្នកដែលត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារហើយ។ ក្នុងឆ្នាំនេះ ស្ថានភាពពន្ធនាគារនៅតែមានលក្ខណៈ យ៉ាប់យឺន ហើយកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការកែលំអរស្ថានភាពពន្ធនាគារ និងអនុវត្តន៏បទបញ្ជាថ្មីៗ ត្រូវ រាំងស្ទះដោយកង្វះខាតថវិការ និងការអនុវត្តដែលមានលក្ខណៈទន់ខ្សោយ។ អង្គការសិទ្ធិមនុស្សបានលើកឡើង នូវ បញ្ហាធ្ងន់ធ្ងរមួយចំនួនដែលរួមមាន ចំនួនមនុស្សក្នុងពន្ធនាគារ ច្រើនលើសចំនុះ បញ្ហាសុខភាព កង្វះម្ហូបអាហារនិងទឹក កង្វះជីវជាតិ និង បញ្ហាសន្តិសុខ។ នៅឆ្នាំនេះ អង្គការ ក្រៅរដ្ឋាភិបាលមួយដែលបានត្រួត ពិនិត្យពន្ធនាគារចំនួន១៨ ក្នុងចំនោមពន្ធនាគារ២៤ ដែលមាននៅទូទាំង ប្រទេស បានកត់សំគាល់ថា ចំនួនអ្នកទោសនៅក្នុងពន្ធនាគារទាំងនោះ បានកើនឡើង ហើយពន្ធនាគារទាំងនោះសុទ្ធតែផ្ទុកមនុស្សលើសចំនុះ។ នៅខែសីហា ពន្ធនាគារនៅខេត្តកណ្តាល ដែលអាចដាក់អ្នកទោសបានត្រឹម ១១០ នាក់នោះ បានទទួលអ្នកទោសដល់ទៅ២៦៦នាក់។ នៅពន្ធនាគារខ្លះ បន្ទាប់ពីមានការប៉ុនប៉ងរត់គេចនោះ ការប្រើប្រាស់ខ្នោះជើង និងការដាក់អ្នកទោសនៅក្នុងបន្ទប់តូច ងងឹត នៅតែ បន្តមាន។ ប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល សំរាប់របបអាហារ របស់អ្នកទោសម្នាក់ៗ ត្រូវបានប្រើមិនចំគោលដៅ ហើយមានកំរិតទាបមិនគ្រប់គ្រាន់ ដែលធ្វើអោយបញ្ហាកង្វះ ជីជាតិមានសភាពកាន់តែធ្ងន់ធ្ងរឡើង។ តាមបទ បញ្ជាពន្ធនាគារ បងប្អូនសាច់ញាតិអាចយកអាហារ និងរបស់ របរចាំបាច់ផ្សេងៗទៅអោយអ្នកទោសបាន ហើយអ្នក

ទោសទាំងនោះ ពឹងផ្អែកទៅលើជំនួយទាំងនោះ ក្នុងការ រស់នៅរបស់គេ ប៉ុន្តែជាញឹកញាប់ គ្រួសារសាច់ញាតិត្រូវ បង់ចិត្តផ្តល់សំនូកអោយមន្ត្រីពន្ធនាគារ ជាមុនសិន ទើបគេអនុញ្ញាតអោយផ្តល់ជំនួយទាំងនោះទៅអ្នកទោស។ ក្នុងកំឡុងពេល ៦ ខែដំបូងនៃឆ្នាំនេះ អង្គការក្រៅ រដ្ឋាភិបាលបានរាយការណ៍ថា មានអ្នកទោសចំនួន ៥៨ នាក់ ត្រូវបានស្លាប់ដោយសារកង្វះអាហារ និងថ្នាំសង្កូវ រឺដោយសារជំងឺដែលបង្កឡើង រឺកាន់តែធ្ងន់ធ្ងរឡើង នៅពេល ដែលគេជាប់ពន្ធនាគារ។

នៅខែកក្កដា ជនដែលត្រូវគេឃុំខ្លួនមុនការកាត់ទោស ដោយនគរបាលនៅខេត្តតាកែវត្រូវបានគេវាយដំរហូត ដល់ស្លាប់ (សូមមើលផ្នែក ១ក)

ក្នុងឆ្នាំ ២០០២ មន្ត្រីប៉ូលីស បីនាក់ត្រូវបានគេព្យួរការងារ និងចោទប្រកាន់ពីបទមនុស្សឃាត ក្នុងការវាយដំ អ្នកទោសរហូតដល់ស្លាប់ នៅឆ្នាំ ២០០១ នៅក្នុងខេត្តព្រៃវែង។ ការចោទប្រកាន់បទឧក្រិដ្ឋទាំងនេះ ត្រូវបានគេដាក់ នៅតុលាការខេត្ត ប៉ុន្តែតុលាការមិនបានចាត់ការទៅលើមន្ត្រីទាំងនោះទេ។ ជនសង្ស័យខ្លះទាំងនេះខ្លះត្រូវបានគេ ដំឡើងឋានៈ។

នៅក្នុងពន្ធនាគារភាគច្រើនពុំមានការបែងចែករវាងអ្នកទោសពេញវ័យនិងអនីតិជន រវាងស្រីនិងប្រុស រឺក៏រវាងអ្នកដែលមានទោសធ្ងន់ រឺស្រាលនោះទេ។

រាជរដ្ឋាភិបាលបានអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សជាតិនិងអន្តរជាតិ ទៅសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្ស ដល់អ្នកយាមពន្ធនាគារ។ ប៉ុន្តែអង្គការទាំងនោះបាននិយាយថា មានពេលខ្លះ កិច្ចសហការពីអាជ្ញាធរមូលដ្ឋាននៅមានកំរិត។ ក្រសួងមហាផ្ទៃនៅតែធ្វើការទាមទារ អោយមេធាវី អ្នកឃ្លាំមើលសិទ្ធិ មនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀត សុំលិខិតអនុញ្ញាតិពីក្រសួងជាមុនសិន មុននឹងទៅសួរសុខទុក្ខ។ ក្នុងករណីខ្លះ ក្រសួងមិនបានផ្តល់ការអនុញ្ញាតិនោះទេ។ អង្គការក្រៅរដ្ឋាភិបាលមិនត្រូវ បានអនុញ្ញាតអោយជួបសម្ភាស ជាមួយ ទណ្ឌិតតែម្នាក់ឯង ដោយគ្មានវត្តមានមន្ត្រីពន្ធនាគារឡើយ។

## ឃ. ការចាប់ខ្លួន ឃុំខ្លួន និងនិរទេសតាមទំនើងចិត្ត

រដ្ឋធម្មនុញ្ញមិនអនុញ្ញាតអោយមានការចាប់ខ្លួន និងឃុំខ្លួនដោយបំពានទេ ប៉ុន្តែជាទូទៅរដ្ឋាភិបាល មិនគោរព តាមការហាមប្រាមនេះឡើយ។ ក្នុងឆ្នាំនេះ មានមនុស្សមួយចំនួនត្រូវបានចាប់ខ្លួនដោយមិនមាន

ដីការត្រឹមត្រូវ ហើយអង្គការសិទ្ធិមនុស្សបានរាយការណ៍ថា មានមនុស្សក្នុង៦៦ករណីត្រូវបានឃុំខ្លួនដោយខុសច្បាប់ដោយប៉ូលីស ។

អនុក្រិត្យមួយចេញនៅឆ្នាំ២០០២ បានបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ ។ អគ្គស្នងការដ្ឋាននេះ ឋិតនៅ ក្រោមការត្រួតត្រារបស់ក្រសួងមហាផ្ទៃ និងមានតួនាទីគ្រប់គ្រងនគរបាលស៊ីវិលគ្រប់ផ្នែកទាំងអស់ ។ កំលាំងនគរបាល ត្រូវបានបែងចែកជានគរបាលដែលមានសមត្ថកិច្ចធ្វើការចាប់ខ្លួន នគរបាលដែលមិនមានសមត្ថកិច្ចនេះ និងនគរបាល យុត្តិធមិ ។ នៅក្នុងឆ្នាំនេះ មានរបាយការណ៍ថា មាននគរបាលបានទទួលលុយ ពីការការពារមុខជំនួញមិនស្របច្បាប់
និងមានជនសង្ស័យខ្លះត្រូវបានដោះលែងដោយសារអំពើពុករលួយរបស់នគរបាល ។ បញ្ហាទាំងនេះបានបង្ក អោយមាន បរិយាកាសនិរទណ្ឌភាពសំរាប់ជនល្មើសមួយចំនួន ។

ច្បាប់អនុញ្ញាតអោយប៉ូលីសឃុំខ្លួនជនណាម្នាក់
និងធ្វើការស៊ើបអង្កេតបានក្នុងរយៈពេល៤៨ម៉ោងមុនពេលធ្វើ ការចោទប្រកាន់ជននោះ ប៉ុន្តែ អាជ្ញាធរតែងតែឃុំខ្លួនជនសង្ស័យអស់រយៈពេលយ៉ាងយូរ មុននឹងធ្វើការចោទប្រកាន់ ។ ជនដែលត្រូវបានចោទប្រកាន់នោះ មានសិទ្ធិទទួលបានមេធាវីតាមផ្លូវច្បាប់ ។ ប៉ុន្តែ អ្នកជាប់ឃុំឃាំង តែងតែត្រូវគេឃុំខ្លួន អស់រយៈជាច្រើនថ្ងៃ ទំរាំតែគេអាចទទួលបានមេធាវី រឺជួបជាមួយសមាជិកគ្រួសារគេបាន ។ ចៅក្រមស៊ើបអង្កេតមាន តួនាទីប្រមូលភស្តុតាង មុននឹងសំរេចថានឹងត្រូវធ្វើការកាត់ទោសរឺយ៉ាងណា ។ អង្គការក្រៅរដ្ឋាភិបាល មួយបានរាយការណ៍ ថា នៅឆ្នាំនេះ មានពាក្យបណ្តឹងចំនួន១២៥ ទាក់ទិនទៅនឹងការឃុំខ្លួនមុនសវនាការ ដែល អូសបន្លាយយូរជាងរយៈពេល៦ ខែដែលកំនត់ដោយច្បាប់ ។ នៅក្នុងខែឧសភា ឆ្នាំ២០០៣ មានមនុស្សបួននាក់ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ថា បាន គាំទ្រភេរវជនចាម៉ាអ៊ីស្លាមីយា ពួកគេមិនត្រូវបានផ្តល់នូវសវនាការដំបូងទេ ។ នៅខែធ្នូ ជនសង្ស័យបីរូបក្នុងចំណោម បួនរូប ត្រូវគេកាត់ទោសអោយជាប់ពន្ធនាគាមួយជីវិត រីឯជនសង្ស័យទីបួនត្រូវគេកាត់ទោសថាមិនមានទោស ។ តាម អង្គការលើកលែងទោសអន្តរជាតិ រដ្ឋាភិបាលបានអះអាងថាបណ្តឹងឧទ្ធរណ៍ដែលធ្វើ ដោយមេធាវីការពារ គឺជាការ ធ្វើសារដើមឡើងវិញ ដូច្នេះហើយបទបញ្ញាតិអំពីការឃុំខ្លួនអ្នកទោសប្រាំមួយខែ

មិនត្រូវបានគេរំលោភទេ។ សវនាការ សាលាឧទ្ធរណ៍ត្រូវបានរដ្ឋាភិបាលបកស្រាយថា ជាសវនាកាថ្មី ដែលជាការត្រួសត្រាយផ្លូវអោយមានការឃុំខ្លួនរយៈពេល ៦ ខែទៀត។ អ្នកទោសជាច្រើនជាពិសេសអ្នកដែលមិនមាន អ្នកច្បាប់ជាតំណាង តែងតែមិនមានឱកាសធានាខ្លួនចេញក្រៅឃុំទេ។ UNHCR និយាយថា ការឃុំខ្លួនដែលអូសបន្លាយពេលយូរបែបនេះ ភាគច្រើនបណ្តាលមកពីការកើនឡើង នៃចំនួនអ្នកទោសក្នុងពន្ធនាគារ និង សមត្ថភាពមានកំរិតនៃប្រព័ន្ធតុលាការ។

នៅខែមេសា សមាជិក CFFដែលជាប់សង្ស័យម្នាក់ បានចូលប្រគល់ខ្លួនដោយខ្លួនឯង ក្រោយពីធ្វើអោយផ្ទុះ គ្រាប់បែកនៅ ខេត្តកោះកុង និងបានបាញ់ប្រហារទៅលើមេប៉ូលីសមូលដ្ឋាន។ ជនសង្ស័យកំពុងរង់ចាំការកាត់ទោសនៅ ចុងឆ្នាំនេះ។ សមាជិក CFFដែលគេសង្ស័យ ចំនួន១៨នាក់បន្ថែមទៀត ត្រូវបានគេចាប់ខ្លួនតាំងពីខែវិច្ឆិកា ឆ្នាំ២០០៣ ។ នៅខែមេសា សមាជិក CFF ដែលគេចោទប្រកាន់បីនាក់ ត្រូវបានកាត់ទោសអោយជាប់ពន្ធធានាគា ពីដប់ឆ្នាំទៅ១៥ឆ្នាំ ។ ប្រាំពីរនាក់ត្រូវបានគេដោះលែង នៅសល់បួននាក់ទៀតកំពុងរងចាំការកាត់ទោស។ ការចោទប្រកាន់លើជនទាំងនេះរួម មាន សមាជិកភាពក្នុងក្រុមប្រដាប់អាវុធខុសច្បាប់ និងសមាជិកភាពក្នុងអង្គការភេរវកម្ម។

## ង. ការបដិសេធនូវការធ្វើសវនាការជាសាធារណៈ និងដោយយុត្តិធមិ

រដ្ឋធម្មនុញ្ញកំនត់អោយមានប្រព័ន្ធតុលាការឯករាជ្យមួយ ប៉ុន្តែរដ្ឋាភិបាលមិនបានគោរពតាមការកំនត់នេះទេ នៅក្នុងការអនុវត្តន៏ជាក់ស្តែង។ តុលាការត្រូវទទួលរងនូវឥទ្ធិពលនិងការជ្រៀតជ្រែកពីសំណាក់អំណាច នីតិប្រតិបត្តិ ព្រមទាំងមានអំពើពុករលួយ ដែលរីករាលដាលយ៉ាងខ្លាំងក្នុងចំនោមចៅក្រមទៀតផង។

ប្រព័ន្ធតុលាការមានតុលាការថ្នាក់ក្រោម (សាលាដំបូង) សាលាឧទ្ធរណ៏ និង តុលាការកំពូល។ រដ្ឋធម្មនុញ្ញ ថែមទាំងបានកំនត់អោយមានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញមួយ ដែលមានអំណាចពិនិត្យនូវធម្មនុញ្ញភាពនៃច្បាប់ទាំងឡាយ ហើយនិងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានតួនាទីតែងតាំង ត្រួតពិនិត្យ និងដាក់វិន័យលើចៅក្រមទៀតផង។ សមាសភាពនៃក្រុមប្រឹក្សាទាំងពីរនេះ មានលក្ខណៈលំអៀងយ៉ាងខ្លាំង ទៅខាងគណបក្សប្រជាជន។

សវនាការត្រូវធ្វើជាសាធារណៈ។ ចុងចោទមានសិទ្ធិចូលរួមនិងប្រឹក្សាជាមួយមេធាវី តទល់និងសួរសាក្សីដែល ដាក់បន្ទុកលើគេ និងផ្តល់សាក្សីនិងភស្តុតាងក្នុងនាមខ្លួនគេផ្ទាល់។ ប៉ុន្តែជាទូទៅសវនាការគឺគ្រាន់ តែជាការបង្គ្រប់កិច្ច និងដោយមិនមានការសាកសួរសាក្សីរបស់ ភាគីបដិបក្សអោយបានទូលំទូលាយឡើយ។

ការខ្វះខាតផ្នែកធនធាន ប្រាក់បៀវត្សន៍ដែលមានកំរិតទាប និងការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ បានរួមចំនែក ធ្វើអោយមានអំពើពុករលួយយ៉ាងខ្លាំង និងភាពគ្មានប្រសិទ្ធិភាពនៅក្នុងប្រព័ន្ធតុលាការ ហើយនៅក្នុងការអនុវត្តន៍ រដ្ឋាភិបាលមិនបានធានាអោយមានដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់ទេ។

ជនជាប់ចោទមានសិទ្ធិតាមច្បាប់ចំពោះសច្ចធារណ៍នៃនិរទោស និងមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែដោយសារ តែអំពើពុករលួយដែលរីកសុះសាយគ្រប់ទីកន្លែង ជនជាប់ចោទទាំងនោះត្រូវស្លូកប៉ាន់ចៅក្រមដើម្បី ទទួលបានសាលក្រម។ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ជួនកាលត្រូវបានរឹតត្បឹតដោយសារការលំបាក ក្នុងការដឹកជញ្ជូនអ្នកទោស ពីពន្ធនាគារនៅតាមបណ្តាខេត្តមកសាលាឧទ្ធរណ៍នៅភ្នំពេញជាដើម។ ដោយហេតុនេះហើយ មានសវនាការឧទ្ធរណ៍ជា ច្រើនត្រូវបានធ្វើដោយមិនមានវត្តមានចុងចោទ។

ចៅក្រមនិងព្រះរាជអាជ្ញាភាគច្រើន មិនបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់គ្រប់គ្រាន់ទេ។ កន្លងមក UNHCHR បានបោះពុម្ភ ច្បាប់ទាំងអស់របស់ប្រទេសកម្ពុជាចែកជូនចៅក្រមទាំងអស់ផងដែរ។ នៅឆ្នាំ២០០៣ សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា បានបើកឡើងវិញ និងបានទទួលនិស្សិតរបស់ខ្លួនជាលើកទី១ តាំងពីទសវត្សន៍ ឆ្នាំ១៩៦០មក។ និស្សិតបញ្ចប់ការសិក្សាចំនួន ៥០នាក់ដំបូងកំពុង ធ្វើកម្មសិក្សាខាងផ្នែកច្បាប់នៅចុងឆ្នាំនេះ។ មេធាវី ដែលបានទទួលការបណ្តុះបណ្តាលថ្មីៗ បាននាំអោយមានការរីកចំរើនគួរអោយកត់សំគាល់សំរាប់ជនជាប់ចោទ ក្នុងការទទួលបានមេធាវី រួមមានការថយចុះនូវរយៈពេលឃុំខ្លួនមុនសវនាការ និងការធានាខ្លួនអោយនៅក្រៅឃុំ។ ទោះយ៉ាង នេះក្តី កង្វះខាតយ៉ាងខ្លាំងនូវមេធាវីដែលមានការបណ្តុះបណ្តាល នៅទូទាំងប្រទេស ជាពិសេសនៅតំបន់ ក្រៅទីក្រុងភ្នំពេញ នៅតែជាបញ្ហា។ បុគ្គលដែលគ្មានលទ្ធភាពក្នុងការទទួលបាននូវមេធាវីការពារ តែងតែត្រូវបាត់បង់នូវសិទ្ធិរបស់គេ ក្នុងការ ទទួលបាននូវការកាត់ទោសដោយយុត្តិធម៌មួយ។

ការស្បថសច្ចា និងចំលើយជាលាយល័ក្ខអក្សររបស់សាក្សី និងជនជាប់ចោទ ជាទូទៅគឺជាភស្តុតាងតែមួយគត់ ដែលគេប្រើនៅពេលសវនាការ ។ ចំលើយរបស់ជនជាប់ចោទជួនកាលបានដោយការបង្ខិតបង្ខំ ដូចជា ដោយការវាយដំ រឺគំរាមកំហែង ហើយជនជាប់ចោទដែលមិនចេះអក្សរ ជាទូទៅមិនត្រូវបានគេប្រាប់ រឺមិនយល់អំពីអត្ថន័យ នៃចំលើយ សារភាព ដែលគេបង្ខំអោយគាត់ចុះហត្ថលេខានោះទេ។ ក្នុងករណីដែលមានពាក់ព័ន្ធនឹងកំលាំងយោធា មន្ត្រីយោធាតែងតែប្រើការគាបសង្កត់ទៅលើចៅក្រម អោយដោះលែងចុងចោទ ដោយមិនបាច់មានការកាត់ទោសឡើយ ។

ការពន្យាពេលរបស់តុលាការ រឺក៏អំពើពុករលួយ តែងតែធ្វើអោយជនដែលត្រូវចោទប្រកាន់ពីបទល្មើសទាំង នោះគេចផុតពីការកាត់ទោស។ មន្ត្រីរាជការមួយចំនួន រឺសមាជិកគ្រួសាររបស់គេដែលបានប្រព្រឹត្តបទល្មើស ចួនកាល ហាក់ដូចជារីករាយ និងនិរទណ្ឌភាពរបស់គេ។ ទោះបីជាតុលាការបានកាត់ទោសសមាជិកខ្លះនៃកំលាំងសន្តិសុខ ដែល បានរំលោភបំពានលើសិទ្ធិមនុស្សក៏ដោយ ក៏ភាពគ្មានទោសពៃរសំរាប់ភាគច្រើននៃអ្នកដែលបានរំលោភ បំពានទាំងនោះ នៅតែជាបញ្ហា។ មន្ត្រីរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងមូលដ្ឋានភាគច្រើននៅតែមិនមានឆន្ទៈនយោបាយ និងធនធានហិរញ្ញវត្ថុ ក្នុងការចាត់វិធានការណ៍ អោយមានប្រសិទ្ធភាព ចំពោះមន្ត្រីយោធានិងសន្តិសុខ ដែលជាប់សង្ស័យពីបទល្មើស រំលោភសិទ្ធិមនុស្សឡើយ ។

ក្រុមប្រឹក្សាកំនែទំរង់ប្រព័ន្ធយុត្តិធមិ មិនមានការរីកចំរើនក្នុងការបំពេញតួនាទីរបស់ខ្លួន ដើម្បីរៀបចំ និងអនុវត្ត វិធានការណ៍កំនែទំរង់ឡើយ ។ នៅឆ្នាំ២០០២ រដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាកំនែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិមួយ ទៀត នៅក្នុងខណៈពេលដែលមានការរិះគន់ថា សហប្រធានរបស់ក្រុមប្រឹក្សាកំនែទំរង់យុត្តិធមិដែលមានរដ្ឋមន្ត្រីមួយរូប និងប្រធានតុលាការកំពូលនោះ មិនមានភាពឯករាជ្យគ្រប់គ្រាន់។ នៅខែឧសភា ២០០៣ ក្រុមប្រឹក្សាកំនែទំរង់ច្បាប់និង យុត្តិធមិ(CLJR) បានធ្វើពង្រៀងមួយលើកម្មវិធីសំរាប់ផ្នែកយុត្តិធមិ និងធ្វើសិក្ខាសាលាមួយ ជាមួយសង្គមស៊ីវិល ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធដទៃទៀត។ ក្នុងឆ្នាំនេះ ក្រុមប្រឹក្សានេះបានសហការជាមួយនឹងម្ចាស់ជំនួយនានា ដើម្បីអនុវត្តកម្មវិធីសំរាប់ផ្នែកយុត្តិធមិនេះ និងបានបញ្ជូនពង្រៀងច្បាប់ជាច្រើនទៅរដ្ឋសភា ដើម្បីសុំការអនុម័ត រាប់បញ្ចូលទាំងពង្រៀងស្តីអំពីលក្ខន្តិកចៅក្រម តុលាការរដ្ឋបាល និងវិសោធនកម្ម ទៅលើច្បាប់ស្តីអំពីការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រមផងដែរ។ លើសពីនេះទៀតនៅខែ វិច្ឆិកា CLJR បានបញ្ជូនផែនការសកម្មភាព សំរាប់ទិសដៅកំនែទំរង់ច្បាប់ទៅក្រុមប្រឹក្សារដ្ឋមន្ត្រី។

ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម បានដាក់វិន័យលើមន្ត្រីយុត្តិធម៌ពីររូប ដែលបានធ្វើខុសបទបញ្ញត្តិនៅក្នុងឆ្នាំនេះ។ សំរាប់ករណីទាំងពីរនេះ បញ្ហាក្រមសីលធម៌ រឺការប្រព្រឹត្តខុសច្បាប់មិនមែនជាមូលដ្ឋានសំរាប់ចំណាត់ការដាក់វិន័យ ដែលមានរូបភាពជាការផ្លាស់ប្តូរការងារពីតុលាការក្រុងភ្នំពេញ ទៅតុលាការខេត្តដែលគេមិនសូវចង់ទៅនោះឡើយ ប៉ុន្តែវាគឺជាការកំនត់សាលក្រមដែលមានភាពចំរូងចំរាស់ទៅវិញ។ អ្នកសង្កេតការផ្នែកច្បាប់បានចោទប្រកាន់ថា ឧត្តម ក្រុមប្រឹក្សាអង្គចៅក្រម ឋិតនៅក្រោមឥទ្ធិពលនយោបាយ និងមិនបានការពារអោយមានប្រសិទ្ធិភាព នូវឯករាជ្យភាព របស់អំណាចតុលាការឡើយ។

នៅខែមករា ២០០៣ ប្រាក់បៀវត្សន៏មន្ត្រីតុលាការត្រូវបានតំលើង ពី ២០ដុល្លារ (៨០ ០០០រៀល) ក្នុង មួយខែ ទៅចន្លោះពី ៣៣០ដុល្លារ និង៦៤០ ដុល្លារ (១រ៣ និង ២រ៥លានរៀល) ក្នុងមួយខែ ក្នុងគោលបំនងកាត់ បន្ថយការប្រព្រឹត្តខុសនិងអំពើពុករលួយ។ អ្នកសង្កេតការបានយល់ស្របថា វប្បធម៌ពុករលួយ និងកង្វះឯករាជ្យភាព នៃប្រព័ន្ធតុលាការ នៅតែដដែលហើយពុំមានផលវិជ្ជមានណាមួយពីការដំឡើងប្រាក់ខែនោះទេ។ ក្រុមសិទ្ធិមនុស្សបានបន្តរាយការណ៏ថា រដ្ឋាភិបាលបានបង្ហាញនូវការត្រួតត្រារបស់ខ្លួនទៅលើតុលាការ ដោយបានបញ្ជា អោយធ្វើការចាប់ខ្លួន ឡើងវិញ នូវជនសង្ស័យទាំងឡាយណាដែលត្រូវបានដោះលែងដោយតុលាការ រឺដោយវិធីក្រៅប្រព័ន្ធតុលាការ។ ចៅក្រមបានលើកឧទារហណ៏អំពីការជ្រៀតជ្រែកពីមន្ត្រីជាន់ខ្ពស់ ដែលបញ្ជាអោយចៅក្រមចេញសាលក្រម អោយស្របទៅតាម អាទិភាពនយោបាយ។ នៅឆ្នាំ២០០២ លោកនាយករដ្ឋមន្ត្រីត្រូវបានគេចោទប្រកាន់ថា បានបញ្ជាអោយ ដកការចោទ ប្រកាន់ព្រហ្មទណ្ឌមិនត្រឹមត្រូវចំពោះអតីតដៃគូរជំនួញបរទេសរបស់គាត់ ក្នុងជំលោះរដ្ឋប្បវេណីមួយ ដែលពាក់ព័ន្ធនឹង ការចោទប្រកាន់ពីបទរំលោភបំពានលើកិច្ចសន្យា។

មេធាវីក៏បានកត់សំគាល់ផងដែរថា មាននគរបាល និងមន្ត្រីពន្ធនាគារខ្លះ ដោយមានការគាំទ្រដោយចេញមុខពី សំណាក់មន្ត្រីរដ្ឋាភិបាល បានបដិសេធមិនអោយគេជួបអ្នកជាប់ ពន្ធនាគារជាលក្ខណៈឯកជន រឺអោយបានយូរគ្រាប់គ្រាន់ ឡើយ ដែលនេះជាការរំលោភច្បាប់មួយ។ បន្ទាប់ពី អំពើហិង្សាប្រឆាំងថៃនៅថ្ងៃទី២៩ ខែមករា២០០៣មក សមាជិកគ្រួសារ និងក្រុមអ្នកសិទ្ធិមនុស្សបានកត់សំគាល់ថា ពួកគេមិនអាចប្រាស្រ័យទាក់ទងជាមួយមនុស្ស៩៧នាក់ ដែលបានឃុំខ្លួនដោយរដ្ឋាភិបាល ក្នុងខណៈពេលគេកំពុងធ្វើការស៊ើបអង្កេតឡើយ។

ប្រទេសកម្ពុជាមានតុលាការយោធាដាច់ដោយឡែកមួយ។ ហើយប្រព័ន្ធតុលាការយោធានេះក៏មាន

បញ្ហា ខ្វះខាតស្រដៀងគ្នានឹងប្រព័ន្ធតុលាការស៊ីវិលដែរ។ ការបែងចែកផ្នែកច្បាប់ រវាងតុលាការយោធា និងតុលាការស៊ីវិល ជួនកាលត្រូវបានគេបំភ្លេចចោល ក្នុងការអនុវត្តន៍ជាក់ស្តែង។ មានជនស៊ីវិលមួយចំនួន ត្រូវបានកោះហៅដើម្បីសាកសួរ ចំលើយដោយតុលាការយោធា ដែលមិនមានយុត្តាធិការទៅលើករណី របស់ពួកគេទេ។

នៅ២០០១ គេបានដាក់អោយប្រើនូវច្បាប់មួយដើម្បីបង្កើតតុលាការពិសេសធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមពីបទល្មើសប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមដែលបានប្រព្រឹត្តពីឆ្នាំ១៩៧៥ដល់១៩៧៩។ រដ្ឋាភិបាលបានស្វែងរកជំនួយឧបត្ថម្ភ និងកិច្ចសហប្រតិបត្តិការពីអង្គការសហប្រជាជាតិតាំងពីឆ្នាំ១៩៩៧ ព្រមទាំងជំនួយហិរញ្ញវត្ថុពីប្រទេសផ្តល់ជំនួយនានា ដើម្បីអោយការកាត់ទោសនោះអាចមានដំណើរការទៅបាន។ ក្នុងខែឧសភា ឆ្នាំ ២០០៣ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសំរេចមួយលើពង្រៀងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់ទោសលើបទឧក្រិដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃទី ៤ ខែតុលា រដ្ឋសភាជាតិនៃព្រះ-រាជាណាចក្រកម្ពុជា បានអោយសច្ចានុម័តដោយសំលេងជាឯកច្ឆ័ន លើកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ហើយនៅថ្ងៃទី៥ ខែតុលា រដ្ឋសភាជាតិក៏បានយល់ព្រមលើវិសោធនកម្មចាំបាច់មួយចំនួនដើម្បីអោយសាលាក្តីនោះអាចមានដំណើរការទៅបាន។ ការពិគ្រោះពិភាក្សា បានកើតឡើងរវាងអង្គការសហប្រជាជាតិ និងប្រទេសអ្នកផ្តល់ជំនួយសំខាន់ៗ ដើម្បីឆ្លើយតបទៅនិងតំរូវការថវិកា ក្នុងការចាប់ផ្តើមសាលាក្តីនេះ។

ពុំមានរបាយការណ៍ណាមួយនិយាយអំពីអ្នកទោសនយោបាយទេ។

## ច. ការជ្រៀតជ្រែកតាមទំនើងចិត្តទៅលើភាពជាឯកជន គ្រួសារ គេហដ្ឋាន ឬ លិខិតឆ្លងឆ្លើយ

រដ្ឋធម្មនុញ្ញបានកំនត់អោយមានភាពជាឯកជននៃលំនៅដ្ឋាន និងលិខិតឆ្លងឆ្លើយ និងហាមប្រាមការឆែកឆេរដោយខុសច្បាប់ ប៉ុន្តែជាប្រចាំ នគរបាលបានធ្វើការឆែកឆេរ និងរឹបអូសដោយមិនមានដីការឡើយ។ មិនមានរបាយការណ៍ថារដ្ឋាភិបាលបានធ្វើការត្រួតពិនិត្យលើប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិកឯកជនទេ។

ចាប់តាំងពីសមូហភាវូបនីយកម្ម (ការប្រមូលផ្តុំជាសហករណ៍) ដោយបង្ខិតបង្ខំនៅសម័យគ្រប់គ្រងរបស់ខ្មែរក្រហម និងការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនជាច្រើនពាន់នាក់មក កម្មសិទ្ធិដីធ្លីមិនមានលក្ខណៈច្បាស់លាស់ទេ ហើយម្ចាស់កម្មសិទ្ធិដីភាគច្រើនគ្មានឯកសារសំគាល់កម្មសិទ្ធិជាផ្លូវការអោយបានគ្រប់គ្រាន់ឡើយ។ បន្ទាប់ពីការបញ្ចប់ទៅនូវចលនាឧទ្ទាមខ្មែរក្រហម ការប្រញាប់ចាប់យកធ្វើជាកម្មសិទ្ធិ នូវដីធ្លី

ដែលត្រូវប៉ាន់នៅតាមផ្លូវពាណិជ្ជកម្មឆ្លងដែន បានធ្វើអោយបញ្ហាកម្មសិទ្ធិដីធ្លីនេះមានសភាពកាន់តែធ្ងន់ធ្ងរឡើង។ ការរីករាលដាលនៃការកាន់កាប់ដីធ្លី ក្នុងឆ្នាំថ្មីៗនេះ បានបង្កអោយមានជំលោះនិងភាពតានតឹងកើនឡើង រវាងសហគមន៍ជនក្រីក្រនិងអ្នកកាន់កាប់ដីធ្លីដែលមានទ្រព្យសម្បត្តិច្រើន។ នៅឆ្នាំ២០០២ ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់បានបង្កើតគណកម្មការសុរិយោដី មួយដែលមានតួនាទីដោះស្រាយទំនាស់ដីធ្លីដែលមិនទាន់បានចុះបញ្ជី ឬមិនទាន់បានទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។ មានការរីកចំរើនតិចតួចនៅក្នុងការងាររបស់ខ្លួន ព្រោះគណកម្មការនេះបានបំពេញការងាររបស់ខ្លួនដោយយឺតយ៉ាវ ដោយសារការខ្វះខាតផ្នែកហិរញ្ញវត្ថុ ការបណ្តុះបណ្តាល និងបទពិសោធន៍។ តុលាការដែលឋិតនៅក្រោមឱវាទក្រសួង យុត្តិធម៌នៅតែត្រូវទទួលខុសត្រូវដោះស្រាយទំនាស់លើដីធ្លីដែលបានចុះបញ្ជីរួចហើយ ឬក៏ដីធ្លីដែលភាគីទំនាស់បានទទួលកម្មសិទ្ធិរួចហើយ។

នៅក្នុងឆ្នាំនេះ ក្រសួងរៀបចំដែនដី នគររូបនីយកម្មនិងសំណង់ បានចាប់ផ្តើមអនុវត្តន៍ ច្បាប់ភូមិបាល ដែលបានអនុម័ត្តកាលពីឆ្នាំ២០០១ ដើម្បីការពារកម្មសិទ្ធិដីធ្លី និងលិខិតស្របច្បាប់។ នៅមានបញ្ហាជាច្រើនបន្តកើតមាន ដែលអ្នករស់នៅលើដីរបស់ខ្លួន ត្រូវបានគេបង្ខំអោយទៅតាំងទីលំនៅនៅលើដីផ្សេងនៅពេលដែលមន្ត្រី ឬអ្នកជំនួញមានអំណាចបានឃុបឃិតជាមួយអាជ្ញាធរមូលដ្ឋាន នៅក្នុងរឿងនេះ។ អង្គការក្រៅរដ្ឋាភិបាលនានា បានរាយការណ៍ថានៅក្នុងអំឡុងឆ្នាំនេះ មានករណីទំនាស់ដីធ្លីឯកជននិងសមូហភាពចំនួន៣៩៦ករណី ដែលប៉ះពាល់ចំនួន ១០៩៥៨ គ្រួសារ។ មានអ្នកខ្លះក្នុងចំនោមអ្នកដែលត្រូវ បានគេបណ្តេញចេញជាស្ថាពរហើយនោះ បានតវ៉ាចំពោះសកម្មភាពនេះនៅតុលាការ ប៉ុន្តែភាគច្រើននៃអ្នកទាំងនេះត្រូវចាញ់ក្តី ដែលអាចដោយសារតែអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ។ នៅចុងឆ្នាំនេះ បណ្តឹងឧទ្ធរណ៍មួយចំនួនកំពុងនៅរង់ចាំការកាត់ក្តីនៅសាលាឧទ្ធរណ៍ ឬតុលាការកំពូល។ ករណីមួយដែលកំពុងរង់ចាំដំណោះស្រាយនោះ គឺបណ្តឹងមួយដែលបានដាក់ប្តឹងដោយមន្ត្រីម្នាក់នៃក្រសួងកិច្ចការនារី ចំពោះប្រជាជនចំនួន៣០៦គ្រួសារ ដែលមន្ត្រីនោះបានចោទប្រកាន់ថាបានរំលោភយកដីរបស់ខ្លួន។ ប្រជាពលរដ្ឋ បានចោទមន្ត្រីនោះវិញថា បានបង្ខំពួកគាត់អោយលក់ដីនេះក្នុងតំលៃទាបជាងទីផ្សារធម្មតា។

នៅខែ សីហា ប៉ូលីស បានបណ្តេញចេញទាំងបង្ខំប្រជាជនចំនួន២៥០គ្រួសារ និងបានវាយដំលើអ្នកតវ៉ាប្រឆាំង នៅក្នុងរឿងទំនាស់ដីនៅប៉ោយប៉ែត ដែលកាន់កាប់ដោយលោករដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ ជនបទ។ សាលដីការរបស់តុលាការកំពូល ដែលសំរេចកាលពីខែកក្កដា បានសំរេចអោយបណ្តេញចេញអ្នកស្រុកទាំងនេះបន្ទាប់ពីមានជំលោះប្តឹងផ្តល់រឿងកម្មសិទ្ធិដីធ្លីអស់រយៈពេល៥ឆ្នាំកន្លងមក។

រហូតមកដល់ចុងឆ្នាំ ជំលោះមួយដែលដំបូងបានប៉ះពាល់ដល់ប្រជាជនចំនួនប្រហែល ១៨០០ គ្រួសារ ទាក់ទងនិងគំរោងសាងសង់ផ្លូវជាតិ រវាងរាជធានីភ្នំពេញនិងទីក្រុងហូជីមិញ ត្រូវបានដោះស្រាយដល់គ្រួសារភាគច្រើន លើកលែងតែប្រជាជនចំនួន១៨៣គ្រួសារប៉ុណ្ណោះនៅមិនទាន់បានដោះស្រាយ។ ពាក្យបណ្ដឹងត្រូវបានដាក់ជូនទៅគណៈកម្មាធិការដោះស្រាយអន្តរក្រសួង សំរាប់ការដោះស្រាយថវិកា នៅក្នុងឆ្នាំ២០០២ និង ២០០៣ និងក្នុងអំឡុងឆ្នាំនេះ ដោយចោទប្រកាន់ថា ថវិកាដែលនឹងត្រូវអោយនោះ មិនគ្រប់គ្រាន់ទេ។

នៅក្នុងឱកាសនៃការថ្លែងកាលពីថ្ងៃទី ១៨ ខែ តុលា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ពីការយកដីពីអ្នករំលោភ ហើយយកទៅអោយប្រជាពលរដ្ឋក្រីក្រវិញនោះ មានអ្នកស្រុកចំនួនរាប់ពាន់អ្នកនៅក្រុងព្រះសីហនុ បានចាប់ផ្ដើមទៅដណ្ដើមដីកាន់កាប់ដីឡូទំនេរដែលមានម្ចាស់គ្រប់គ្រងជាអ្នកមានទ្រព្យសម្បត្តិ ឬម្ចាស់ដីពុំមានវត្តមាននៅទីនោះ។ អាជ្ញាធមិមូលដ្ឋានបានចេញដីការចាប់ខ្លួនប្រជាពលរដ្ឋចំនួន ២៩នាក់ ដែលពាក់ព័ន្ធនិងសកម្មភាពដណ្ដើមដីកាន់កាប់នេះ ហើយដែលបន្ទមកទៀត បានចាប់ខ្លួនជនសង្ស័យចំនួន១៧នាក់។ រហូតមកដល់ចុងឆ្នាំ អ្នកចាប់ខ្លួនចំនួន១១នាក់ត្រូវបានគេដោះលែង ហើយ៦នាក់ទៀតកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់ប៉ូលីសនៅឡើយដើម្បីរង់ចាំការឡើងតុលា។

នៅក្នុងខែវិច្ឆិកា មានជំលោះដីធ្លីដ៏ធំមួយបានកើតឡើង ដោយមានការពាក់ព័ន្ធជាមួយប្រជាជនរាប់រយនាក់នៅក្នុងខេត្តពោធិសាត់ កំពង់ឆ្នាំង និងក្រុមហ៊ុន ភាពីម៉ិច។ ជំលោះនោះជាប់ពាក់ព័ន្ធនិងដីសម្បទានទំហំ ៧៤១ ០០០ អារ ដែលរដ្ឋាភិបាលបានផ្ដល់ទៅអោយក្រុមហ៊ុនភាពីម៉ិច។ នៅក្នុអំឡុងពេលនៃការប្រឆាំងតវ៉ានៅមុខការដ្ឋានក្រុមហ៊ុននេះ មានគ្រាប់បែកមួយគ្រាប់ត្រូវបានគេចោលទៅ លើក្រុមអ្នកតវ៉ា ដោយធ្វើអោយរបួសមនុស្ស៨នាក់។ ប៉ូលីសមិនបានធ្វើការចាប់ខ្លួនអ្នកណាម្នាក់ទេនៅក្នុងរឿងគប់គ្រាប់បែកនេះ។ អាជ្ញាធមិខេត្ត បានទាមទាអោយក្រុមហ៊ុមភាពីម៉ិច បញ្ឈប់សកម្មភាពរបស់ខ្លួន ប៉ុន្តែក្រុមហ៊ុននេះនៅតែបន្តសកម្មភាពអភិវឌ្ឍន៍ការដ្ឋានរបស់ខ្លួន។

ខុសពីឆ្នាំមុនៗ ពុំមានករណីណាមួយដែលគេបានដឹងថា មានការផ្លាស់ប្ដូរទីលំនៅប្រជាពលរដ្ឋដោយសារគំរោងអភិវឌ្ឍន៍សហគមន៍ ដោយសាលាក្រុងភ្នំពេញ។

## ផ្នែកទី២: ការគោរពសេរីភាពស៊ីវិល ដោយរាប់បញ្ចូលទាំង :

### ក. សេរីភាពក្នុងការបញ្ចេញមតិនិងសារពតិមាន

រដ្ឋធម្មនុញ្ញកំនត់អោយមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារពតិមាន ហើយជាទូទៅ

រដ្ឋាភិបាលបានគោរពចំពោះសេរីភាពទាំងនេះក្នុងការអនុវត្តន៏ជាក់ស្តែង ប៉ុន្តែមិនបានដាក់កំហិតដល់ សេរីភាពនៃការពិភាក្សាក្នុងថ្នាក់រៀននោះទេ ក៏ប៉ុន្តែមានបញ្ហាមួយចំនួននៅតែបន្តកើតមាននៅឡើយ។ រដ្ឋធម្មនុញ្ញបានដាក់ក៏រិតជាប្រយោលលើការបញ្ចេញមតិដោយសេរី ដោយទាមទារថាការ បញ្ចេញមតិនោះមិនប៉ះពាល់ដល់សន្តិសុខសាធារណៈ។ រដ្ឋធម្មនុញ្ញក៏បានប្រកាសផងដែរថាព្រះមហាក្សត្រជា បុគ្គលដែល "មិនអាចរំលោភបំពានបាន"។

ច្បាប់សារពត៌មានផ្តល់ដល់អ្នកសារពត៌មាននូវសិទ្ធិមួយចំនួន ដែលរួមមានការហាមប្រាមមិនអោយមានការត្រួតពិនិត្យមុនធ្វើការចេញផ្សាយ និងការការពារមិនអោយដាក់ពន្ធនាគារដោយសារតែការបញ្ចេញមតិ។ ទោះជាយ៉ាងនេះក៏ដោយ ច្បាប់សារពត៌មានក៏មានរួមបញ្ចូលនូវការហាមប្រាម ដែលមិនច្បាស់លាស់ ចំពោះការបោះពុម្ពផ្សាយអត្ថបទទាំងឡាយ ដែលប៉ះពាល់ដល់សន្តិសុខជាតិនិងស្ថេរភាពនយោបាយ។ សារ ពត៌មានបានបោះពុម្ពផ្សាយនូវអត្ថបទសារពត៌មានមួយចំនួនធំ ដែលរិះគន់ចំពោះរដ្ឋាភិបាល ក្នុងនេះរាប់បញ្ចូល ទាំងការរិះគន់ផ្ទាល់ចំពោះលោកនាយករដ្ឋមន្ត្រី ព្រះប្រធានរដ្ឋសភាជាតិ និងមន្ត្រីជាន់ខ្ពស់ដទៃៗទៀត។

ទោះជាបីជាចំនួននៃការចេញផ្សាយនៅមានក៏រិត សារពត៌មានគឺជាប្រភពទីមួយនៃពត៌មាននិងការសំដែងមតិនយោបាយ។ គណបក្សនយោបាយធំៗទាំងអស់មានលទ្ធភាពសមរម្យនិងទៀងទាត់ក្នុងការប្រើប្រាស់សារពត៌មានបោះពុម្ពផ្សាយ។ សារពត៌មាន មានលក្ខណៈលំអៀងផ្នែកនយោបាយជាទូទៅ។ ទោះបីជាច្បាប់សារពត៌មានមិនបានអនុញ្ញាតដោយជាក់លាក់ អោយសារពត៌មានទទួលយកជំនួយហិរញ្ញវត្ថុពីគណបក្សនយោបាយក៏ដោយ ក៏មានសារពត៌សំខាន់ៗមួយចំនួនជាភាសាខ្មែរ បានទទួលការគាំទ្របែបនេះពីគណបក្សនយោបាយផ្សេងៗ។ គេប៉ាន់ប្រមាណថាមានកាសែតបោះពុម្ពផ្សាយជាភាសាខ្មែរ ចំនួនប្រមាណជា២០ ដែលធ្វើការបោះពុម្ពជាប្រចាំ។ ក្នុងចំណោមកាសែតទាំងនេះ មានកាសែតចំនួនចំនួនពាក់កណ្តាល តូវគេចាត់ទុកថាគាំទ្រគណបក្សប្រជាជន កាសែតមួយភាគបីនៃចំនួននេះ គាំទ្រគណបក្សហ៊្វុនសិនប៉ិច និងកាសែតមួយគាំទ្រគណបក្សប្រឆាំង សមរង្ស៊ី។ ក្នុងរយៈពេលឆ្នាំនេះ មានការសែតថ្នាក់ខេត្តចំនួន៤ ត្រូវបានចាប់ផ្តើមបោះពុម្ពផ្សាយពត៌មានក្នុងស្រុក។ បន្ថែមលើនេះទៀត មានកាសែតប្រចាំថ្ងៃជាភាសាបារាំង ជាភាសាអង់គ្លេស ចិន និងភាសាវៀតណាម។ និងកាសែតជាភាសាអង់គ្លេស២ផ្សេងទៀត ដែលធ្វើការបោះពុម្ពផ្សាយជាទៀងទាត់។ ទោះជាកាសែតដែលមានការបោះពុម្ពផ្សាយធំជាងគេទាំង៣ ត្រូវបានគេគិតថាជាកាសែតគាំទ្រគណបក្សប្រជាជនក៏ដោយ ក៏កាសែតភាគច្រើនជានិច្ចកាលរិះគន់រដ្ឋាភិបាល ជាពិសេសចំពោះ

បញ្ហាពាក់ព័ន្ធនឹងអំពើពុករលួយ។ នាយករដ្ឋមន្ត្រីហ៊ុនសែន និងព្រះប្រធានរដ្ឋសភា ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ តែងតែទទួលរងការវាយប្រហារពីកាសែតប្រឆាំង។

រដ្ឋាភិបាល កងកំលាំងយោធា និងគណបក្សនយោបាយកាន់អំណាច នៅតែបន្តគ្រប់គ្រងលើប្រព័ន្ធពត៌មានផ្សព្វផ្សាយ និងគ្រប់គ្រងលើខ្លឹមសារនៃការផ្សព្វផ្សាយ។ យោងតាមរបាយការណ៍មួយកាលពីឆ្នាំ២០០១ដោយ UNHCHR បានអោយដឹងថា នីតិវិធីសុំអាជ្ញាប័ណ្ណផ្សព្វផ្សាយ និងការបែងចែកប្រេកង់វិទ្យុ ឬទូរទស្សន៍មានលក្ខណៈលំអៀង។ គណបក្សសមរង្ស៊ី និងក្រុមគាំទ្រសកម្មភាពសិទ្ធិមនុស្សឯករាជ្យ ដែលមានសម្ព័ន្ធភាពជាមួយគណបក្សប្រឆាំង ត្រូវបានបដិសេធនឹអាជ្ញាប័ណ្ណផ្សព្វផ្សាយតាមរលកធាតុអាកាស។

មានស្ថានីយទូរទស្សន៍ចំនួន៧។ ស្ថានីយទាំងអស់នេះត្រូវគ្រប់គ្រង ឬក៏ទទួលឥទ្ធិពលយ៉ាងខ្លាំងពីគណបក្សប្រជាជន។ ការគ្រប់គ្រងរបស់រដ្ឋាភិបាលបានរឹតត្បឹតយ៉ាងខ្លាំងទៅលើខ្លឹមសារនៃការផ្សព្វផ្សាយរបស់វិទ្យុ និងទូរទស្សន៍។ ស្ថានីយវិទ្យុនិងទូរទស្សន៍ជាតិដែល គ្រប់គ្រងដោយក្រសួងពត៌មាននោះ បានចាក់ផ្សាយសម័យប្រជុំរដ្ឋសភា ហើយជាញឹកញាប់ ការចាក់ផ្សាយនេះត្រូវបានគេត្រួតពិនិត្យ។ ស្ថានីយវិទ្យុនិងទូរទស្សន៍ជាតិចាក់ផ្សាយជាប្រចាំនូវកម្មវិធីសិទ្ធិមនុស្ស សកម្មភាពសង្គម សុខភាពសាធារណៈ សង្គមស៊ីវិលដែលផលិតដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។

មានរបាយការណ៍អំពីការធ្វើទុក្ខបុកម្នេញ ចំពោះអ្នកដែលធ្វើការក្នុងសារពត៌មានបោះពុម្ព និងផ្សព្វផ្សាយតាមរលកធាតុអាកាស។ នៅថ្ងៃទី២៣ ខែកុម្ភៈ អ្នកកាសែតមួយរូបត្រូវបានចាប់ដាក់ខ្នោះនិងវាយដោយអាជ្ញាធមិសួនឧទ្យានជាតិ នៅពេលដែលអ្នកកាសែតរូបនោះ ព្យាយាមថតរូបពួកគេដែលធ្វើមិនគប្បីដល់អ្នកស្រុក។ នៅក្នុងអំឡុងឆ្នាំនេះដែរ អាជ្ញាធមិបានឃុំខ្លួនអ្នកកាសែតចំនួន៧នាក់ នៅក្នុងឧប្បត្តិហេតុផ្សេងៗគ្នា ដោយចោទប្រកាន់ពួកគេទាំងនោះ ពីការក្លែងឯកសារនិងជីវិតទាលុយ។

ភ្លាមៗបន្ទាប់ពីមានបាតុកម្មប្រឆាំងថៃ ខែមករា ឆ្នាំ២០០៣ ទាំងម្ចាស់ស្ថានីយវិទ្យុឯករាជ្យសំបុកឃ្មុំ ១០៥ និងទាំងនិពន្ធនាយកកាសែតខ្មែរ "រស្មីអង្គរ " ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ពីបទផ្សព្វផ្សាយ និងបោះពុម្ពផ្សាយពត៌មានមិនពិត (សូមមើលផ្នែកទី២.ខ)។ ពួកគេត្រូវបានដោះលែងដោយបង់ប្រាក់ធានា បន្ទាប់ពីត្រូវបានគេឃុំខ្លួនអស់រយៈពេល២សប្តាហ៍។ នៅក្នុងខែ តុលា ឆ្នាំ២០០៣ លោក ជូ ជេតថារិទ្ធ អ្នកសរសេរពត៌មានអោយវិទ្យុ តាព្រហ្ម ដែលគាំទ្រគណបក្ស ហ៊្វុនស៊ីនប៉ិច និងជាអតីតអ្នកជំនួយការរបស់គណបក្សនេះ បានត្រូវគេបាញ់សំលាប់នៅមុខស្ថានីយវិទ្យុតាព្រហ្ម (សូមមើលផ្នែកទី១.ក)។

កម្មវិធីវិទ្យុសំលេងប្រជាធិបតេយ្យ ដែលផលិតដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានចាក់

ផ្សាយវិទ្យុឯកជនចំនួន២ ដែលកម្មវិធីនេះជារឿយៗ បានផ្សព្វផ្សាយទស្សនៈឯករាជ្យនិងការប្រឆាំង រដ្ឋាភិបាលកម្ពុជា។ កម្មវិធីផ្សាយរបស់មជ្ឈមណ្ឌលនេះ មានប្រជាប្រិយភាពយ៉ាងខ្លាំង ហើយទទឹមនិងនេះ ក៏មានការប្រឈមមុខចំពោះលទ្ធភាពជាច្រើន ដែលមជ្ឈមណ្ឌលនេះជួបប្រទះ ក្នុងការផ្សាយកម្មវិធីរបស់ខ្លួន នៅក្នុងរយៈពេលនៃឆ្នាំនេះ។ នៅក្នុងខែមិថុនា ម្ចាស់វិទ្យុដែលគាំទ្រគណបក្ស ហ៊្វុនសិនប៊ិច បានបញ្ឈប់ការ ផ្សាយកម្មវិធីសំលេងប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បន្ទាប់ពីកម្មវិធីនេះបានរិះគន់ថ្នាក់ ដឹកនាំគណបក្សហ៊្វុនសិនប៊ិចរួចមក។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៣ មក ក្រសួងពត៌មាន បានបដិសេធន៏ការ ផ្តល់អាជ្ញាប័ណបើកវិទ្យុ ដល់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដោយអះអាងថា រាជធានីភ្នំពេញ មានស្ថានីយ៏ វិទ្យុនិងសារពត៌មានច្រើនពេកហើយ។

ពាក្យបណ្តឹងពីការបរិហារកេរ្តិ៍ និងបង្ខូចកេរ្តិ៍ឈ្មោះ មានការកើនឡើងនៅក្នុងអំឡុងឆ្នាំនេះ ដោយមានសារពត៌មានចំនួន ៧ត្រូវបានគេប្តឹងចំពោះការបរិហារកេរ្តិ៍ ហើយអ្នកយកពត៌មានចំនួន៦នាក់ ត្រូវបានចាប់ខ្លួននៅក្នុងរយៈពេល៨ខែ នៃឆ្នាំនេះ។ អ្នកយកពត៌មាន២នាក់ ត្រូវបានគេកាត់ទោសពីបទ បរិហារកេរ្តិ៍ ហើយតំរូវអោយបង់ប្រាក់សងជម្ងឺចិត្ត ដល់ដើមចោទទៀតផង ដែលដើមចោទ នៅក្នុងករណី ទាំងពីរនេះជាសមាជិករបស់រាជរដ្ឋាភិបាល។

ប្រព័ន្ធសារពត៌មានត្រូវបានរាយការណ៏ថាបានធ្វើការត្រួតពិនិត្យលើការផ្សាយរបស់ខ្លួនដោយខ្លួនឯង ក្នុងអំឡុងឆ្នាំនេះ។ បន្ទាប់ពីការបោះឆ្នោត ខែកក្កដា ឆ្នាំ២០០៣ ប្រព័ន្ធសារពត៌មានបានធ្វើការត្រួតពិនិត្យ លើការផ្សាយរបស់ខ្លួន នៅក្នុងឱកាសជាច្រើន បន្ទាប់ពីមានការទូរស័ព្ទមកពីគណបក្សប្រជាជន និងគណបក្សហ៊្វុនសិនប៊ិច ដើម្បីអោយមានការកំនត់ក្នុងការទិទៀនរិះគន់ដល់គណបក្សនិមួយៗ។

ការចូលយកពត៌មានស្តីពីកិច្ចប្រជុំពិភាក្សារបស់រដ្ឋសភាជាតិ ត្រូវបានអនុញ្ញាតិដោយរដ្ឋធម្មនុញ្ញ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្សាយកិច្ចប្រជុំពិភាក្សារបស់រដ្ឋសភា នៅលើកញ្ចក់ទូទស្សន៏ជាតិកម្ពុជា តែទោះ ជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាល បន្តការហាមឃាត់អ្នកសារពត៌មានទៅក្នុងអាគាររដ្ឋាភិបាល។ នៅខែ មេសា ឆ្នាំ២០០៣ រដ្ឋសភាជាតិបានហាមឃាត់អ្នកយកពត៌មាន មិនអោយចូលក្នុងបរិវេណរដ្ឋសភា ប្រសិន បើមានការអនុញ្ញាតិពីអគ្គលេខារដ្ឋសភាមកពីគណបក្សហ៊្វុនសិនប៊ិចឡើយ។ គេបានចេញសេចក្តីណែនាំ "សន្តិសុខ" នេះ នៅរយៈពេលប៉ុន្មានម៉ោងក្រោយពីការផ្តាច់ខ្លួនជាសាធារណៈ របស់សមាជិកសភា៣រូប និង មន្ត្រីរាជានិយម៤រូបផ្សេងទៀតរបស់គណបក្សហ៊្វុនសិនប៊ិច ទៅចូលរួមជាមួយគណបក្សប្រឆាំង សមរង្ស៊ី។

ទន្ទឹមនេះដែរ សេចក្តីសំរេចនេះត្រូវធ្វើឡើងបន្ទាប់ពីលោកអភិបាលក្រុងភ្នំពេញ កែប ជុតិមា បានបិទទ្វារការប្រជុំប្រចាំសប្តាហ៍របស់សាលាក្រុង ដែលជាប្រពៃណីការប្រជុំនេះតែងតែបើកជាសាធារណៈ ។

នៅក្នុងអំឡុងឆ្នាំនេះដែរ អាជ្ញាធមិរដ្ឋាភិបាលបានដកហូតការបោះពុម្ពផ្សាយមិនអោយដល់ដៃប្រជាពលរដ្ឋ។ នៅខែធ្នូ អាជ្ញាធមិ រាជរដ្ឋាភិបាលបានរឹបអូសសៀវភៅដែលមានលក្ខណៈ ចំរូងចំរាស់ដែលនិយាយពីការពាក់ព័ន្ធដល់ភរិយារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងការស្លាប់របស់តារាភាពយន្តល្បីល្បាញ នាង សិដ្ឋពិលីកា។ ទោះជាយ៉ាងណា កូនសៀវភៅនោះ នៅតែត្រូវបានគេដាក់លក់ក្នុងស្នាក់ការគណបក្សសមរង្ស៊ី និងបោះពុម្ពនៅរោងពុម្ពដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាលអ្វីឡើយ ។

រាជរដ្ឋាភិបាលមិនបានហាមឃាត់ការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណិត ដែលកំពុងមានការប្រើយ៉ាងទូលំទូលាយនៅក្នុងទីក្រុងនិងទីប្រជុំជនធំៗឡើយ ។

### ខ. សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងការបង្កើតសមាគម

រដ្ឋធម្មនុញ្ញបានផ្តល់នូវសេរីភាពក្នុងការប្រជុំដោយសន្តិភាព ប៉ុន្តែរដ្ឋាភិបាលមិនបានគោរពសេរីភាពនេះទេនៅក្នុងការអនុវត្តន៏ជាក់ស្តែង។ រដ្ឋាភិបាលបានតំរូវអោយមានការសុំលិខិតអនុញ្ញាតិជាមុនសិនមុននឹងការដង្ហែក្បួន ឬធ្វើបាតុកម្ម។ ជានិច្ចកាល រដ្ឋាភិបាលមិនផ្តល់ការអនុញ្ញាតិអោយទៅ ក្រុមដែលរិះគន់គណបក្សកាន់អំណាចទេ។ ក្នុងរយៈពេលឆ្នាំនេះ រដ្ឋាភិបាលបានលើកយកករណីកុប្បកម្មប្រឆាំងថៃ ខែមករា ឆ្នាំ២០០៣ និងសន្តិសុខសាធារណៈ ធ្វើជាហេតុផលក្នុងការបដិសេធមិនអនុញ្ញាតអោយធ្វើការប្រជុំ ហើយក្រុមដែលប្រមូលផ្តុំប្រជុំដោយមិនមានការអនុញ្ញាតិត្រូវបានប៉ូលីសបំបែកដោយប្រើកំលាំង ដែលភាគច្រើននៃការបំបែកទាំងនេះបានបង្កអោយមានរបួសស្នាមតិចតួចដល់បាតុករ។ រាជរដ្ឋាភិបាលបានធ្វើការបង្ក្រាបបាតុកម្មចំនួន៥លើក ដែលគេមិនផ្តល់ការអនុញ្ញាតិអោយធ្វើ និងបំបែកការប្រជុំចំនួន៣លើករបស់សមាគមគ្រូបង្រៀន។ នៅខែមករា ការធ្វើបាតុកម្មរបស់គណបក្សរណសិរ្សជនជាតិខ្មែរ នៅពីមុខរដ្ឋសភា ត្រូវបានគេបំបែក។ នៅពេលនោះ មានបាតុករចំនួន៤នាក់ត្រូវបានគេចាប់ខ្លួន ហើយត្រូវបង្ខំអោយចុះហត្ថលេខាលើកិច្ចសន្យា មិនត្រូវធ្វើការប្រឆាំងតវ៉ាទៀត នៅពេលអនាគត។ នៅខែមិថុនា ប៉ូលីសបានបំបែកហ្វូងបាតុកម្មដែលមានប្រជាជនរាប់រយនាក់ចូលរួម តវ៉ាប្រឆាំងរឿងការរំលោភយកដី ដោយមន្ត្រីរដ្ឋាភិបាល ដោយពួកអ្នកតវ៉ាទាំងនោះបានបិទផ្លូវជាតិ។ ក្រុមប៉ូលីសបានប្រើដំបងនិងជ័រឆក់ ដើម្បីបំបែកក្រុមអ្នកតវ៉ាទាំងនោះ។

រដ្ឋាភិបាលខកខានមិនបានការពារអ្នកធ្វើបាតុកម្មដោយសន្តិវិធីអោយជៀសផុតពី អំពើហិង្សាឡើយ។ នៅក្នុងខែវិច្ឆិកា អ្នកភូមិជាច្រើននាក់បានប្រមូលផ្តុំ នៅខាងក្រៅក្រុមហ៊ុន ភាពីម៉ិក ដែលមានពាក់

ព័ន្ធនិងជំលោះដីធ្លី ដែលនៅពេលនោះមានគេចោលគ្រាប់មួយគ្រាប់ទៅលើហ្វូងអ្នកតវ៉ាប្រឆាំង ដែលធ្វើអោយមានរបួសអ្នកតវ៉ាចំនួន៨នាក់។ អាជ្ញាធមិមិនបានធ្វើការចាប់ខ្លួនជនសង្ស័យដែលបានប្រព្រិត្តអំពើនោះទេ ឬក៏មិនបានផ្តល់ការការពារសន្តិសុខដល់អ្នកប្រឆាំងតវ៉ាទាំងនោះឡើយ ( សូមមើលផ្នែកទី១ ច) ។

អ្នកគ្រាំទ្រនៃគណបក្សកំពុងកាន់អំណាចនិងប្រឆាំង បានដង្ហែក្បួនជួបជុំនៅតាមដងផ្លូវ នៅក្នុងអំឡុងពេលនៃយុទ្ធនាការបោះឆ្នោត ឆ្នាំ២០០៣។

រដ្ឋធម្មនុញ្ញបានផ្តល់អោយមាននូវសេរីភាពក្នុងការធ្វើសមាគម ហើយជាទូទៅរដ្ឋាភិបាលបានគោរពនូវសិទ្ធិសេរីភាពនេះក្នុងការអនុវត្តន៏ ប៉ុន្តែរដ្ឋាភិបាលមិនបានអនុវត្តអោយមានប្រសិទ្ធិភាពនូវបទបញ្ញត្តិសេរីភាពសមាគមនៃច្បាប់ការងារឡើយ( សូមមើលផ្នែកទី៦.ក.) ។

រដ្ឋាភិបាលមិនបានហាមឃាត់ឬបង្ខិតបង្ខំការចូលជាសមាជិកនៃអង្គការនយោបាយទេ។ ជាធម្មតាគណបក្សនយោបាយអាចធ្វើសកម្មភាពរបស់គេដោយសេរីនិងដោយគ្មានការជ្រៀតជ្រែកពីរដ្ឋាភិបាល។ អង្គការសិទ្ធិមនុស្សបានរាយការណ៏ថា អាជ្ញាធមិមូលដ្ឋានខ្លះបានព្រមានសមាជិកគណបក្សនយោបាយ មួយចំនួនថា ប្រសិនបើពួកគេបន្តគាំទ្រ គណបក្សទាំងនោះទៀត ពួកគេនឹងបាត់បង់សិទ្ធិរស់នៅក្នុងតំបន់នោះ ត្រូវគេដកហូតទ្រព្យសម្បត្តិ និងត្រូវគេហាមឃាត់មិនអោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាននោះទេ។ នៅក្នុងអំឡុងឆ្នាំនេះ គណបក្សសម្ព័ន្ធភាពកំពុងកាន់អំណាច បានកំរាមកំហែងថានិងដកអភ័យឯកសិទ្ធិសមាជិកសភាជាច្រើនរូបមកពីគណបក្ស សម រង្ស៊ី ជាមួយនិងករណីប្តឹងផ្តល់ឡើងតុលាដែលមានលក្ខណៈហេតុផលខាងនយោបាយ ប្រឆាំងពួកគេ។ រហូតមកដល់ចុងឆ្នាំ រដ្ឋសភាជាតិមិនបានមានចំណាត់ការណាមួយក្នុងការដកអភ័យឯកសិទ្ធិសមាជិកសភានោះទេ។

សមាជិកភាពក្នុងអង្គការចាត់តាំងខ្មែរក្រហម ដែលបានគ្រប់គ្រងប្រទេសពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយពីមុនបានធ្វើការតស៊ូប្រឆាំងនឹងរដ្ឋាភិបាលដោយអាវុធនោះ គឺជាការខុសច្បាប់ ដូចគ្នានឹងសមាជិកភាពនៅក្នុងក្រុមប្រដាប់អាវុធដទៃទៀតដែរ។

**គ. សេរីភាពខាងសាសនា**

រដ្ឋធម្មនុញ្ញបានផ្តល់អោយមាននូវសេរីភាពខាងសាសនា ហើយជាទូទៅរដ្ឋាភិបាលបានគោរពនូវសិទ្ធិសេរីភាពនេះក្នុងការអនុវត្តន៏ជាក់ស្តែង។ រដ្ឋធម្មនុញ្ញក៏បានហាមប្រាមផងដែរនូវការរើសអើងខាងសាសនា ហើយសាសនាភាគតិចស្ទើរតែមិនមានទទួលរងនូវការរើសអើងជាផ្លូវការណាមួយទេ។ ព្រះពុទ្ធសាសនា គឺជា

សាសនារបស់រដ្ឋ ហើយប្រជាជនជាង៩៥ភាគរយជាអ្នកកាន់ព្រះពុទ្ធសាសនា។ ប្រជាជនដែលនៅសល់ពីនេះភាគច្រើនគឺជាជនជាតិភាគតិចចាម ។

នៅក្នុងខែមករា ឆ្នាំ២០០៣ ក្រសួងធម្មការនិងកិច្ចការសាសនា បានចេញបទបញ្ជាមួយហាមឃាត់ការផ្លាស់ប្តូរសាសនាជាសាធារណៈ។ ក្នុងអំឡុងឆ្នាំនេះ បទបញ្ជានោះត្រូវបានគេអនុវត្តន៍តែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។

សំរាប់ការពិភាក្សាលំអិតបន្ថែមទៀត សូមមើលរបាយការណ៍អំពីសេរីភាពខាងសាសនាទូទាំងពិភពលោកឆ្នាំ២០០៤ ។

### ឃ. សេរីភាពនៃការធ្វើដំណើរក្នុងប្រទេស ក្រៅប្រទេស អន្តោប្រវេសន៍ និងមាតុភូមិនិវត្តន៍

រដ្ឋធម្មនុញ្ញ និងច្បាប់បានផ្តល់អោយមានសេរីភាពទាំងនេះ ហើយជាទូទៅរដ្ឋាភិបាលបានគោរពនូវសេរីភាពទាំងនេះក្នុងការអនុវត្តន៍ជាក់ស្តែង។ មានសេចក្តីរាយការណ៍ពតិមានផ្សេងៗជាច្រើន ស្តីពីការហាមប្រាមដល់អ្នកកាសែត និងក្រុមសិទ្ធិមនុស្សមិនអោយធ្វើដំណើរទៅកាន់ខេត្តមណ្ឌលគីរីនិងរតនគីរី បន្ទាប់ពីមានការបះបោរពីក្រុមពួកកុលសម្ព័ន្ធភ្នំនៅក្នុងប្រទេសវៀតណាមកាលពីខែមេសា។ ក្រុមបុគ្គលិកជំនួយត្រូវបានគេប្រាប់អោយសុំការអនុញ្ញាតិ ពីអាជ្ញាធមិដែនដីដើម្បីធ្វើដំណើរនៅក្នុងខេត្តទាំង២នេះ។

រដ្ឋាភិបាលមិនបានដាក់កំហិតលើការធ្វើដំណើរទៅបរទេសទេ។ រដ្ឋាភិបាលថែមទាំងមិនបានដាក់កំហិតលើការធ្វើអន្តោប្រវេសន៍ ឬក៏ហាមឃាត់អ្នកដែលបានចាកចេញពីប្រទេសមិនអោយត្រលប់មកវិញដែរ។

រដ្ឋធម្មនុញ្ញបានហាមឃាត់ការធ្វើនិរទេសទាំងបង្ខំ ហើយរដ្ឋាភិបាលក៏មិនបានអនុវត្តន៍ប្រការនោះទេ។ ក្នុងឆ្នាំ២០០២ សមាជិកសភាមួយរូបមកពីគណបក្សហ្វុនសិនប៉ិច បានលាលែងចេញពីសមាជិកសភា ហើយបានបង្ខំចិត្តរស់នៅជាភាពនិរទេសនៅក្រៅប្រទេស។

នៅក្នុងខែ មិនា ឆ្នាំ២០០២ រដ្ឋាភិបាលបានចុះហត្ថលេខាលើអនុស្សរណៈមួយជាមួយ សហរដ្ឋអា- មេរិក ដើម្បីសំរួលដល់ការបញ្ជូនត្រលប់មកវិញនូវជនជាតិកម្ពុជា ដែលក្នុងនោះ មានជនជាតិខ្មែរចំនួន ១២៧នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍មកពីសហរដ្ឋអាមេរិក នៅចុងឆ្នាំនេះ។ នៅក្នុងឆ្នាំ២០០២នេះដែរ ជនជាតិខ្មែរចំនួន៣៦នាក់ត្រូវបានគេឃុំខ្លួនជាច្រើនសប្តាហ៍ នៅពេលដែលគេទើបបញ្ជូនត្រលប់មកដល់ ប្រទេសកម្ពុជា ហើយមួយចំនួនទៀតត្រូវបានគេរាយការណ៍ថា បានត្រូវបង្ខំអោយបង់ប្រាក់សំណូកនៅក្នុង អំឡុងពេលនៃការជាប់ឃុំឃាំង នោះ។ រដ្ឋាភិបាលបានគោរពនូវសិទ្ធិរបស់បុគ្គលទាំងនេះ ហើយនិងការខិតខំ ប្រឹងប្រែងរបស់គេ

ក្នុងការធ្វើសមារណីកម្មទៅក្នុងសង្គម។ នៅក្នុងអំឡុងឆ្នាំនេះ មានអង្គការក្រៅរដ្ឋាភិបាលមួយ បានផ្តល់ការឧបត្ថម្ភដល់ការធ្វើសមាហរណីកម្ម ដល់ជនជាតិខ្មែរដែលត្រូវបានគេបញ្ជូនត្រលប់មកវិញ។

ច្បាប់អនុញ្ញាតអោយមានការផ្តល់នូវសិទ្ធិជ្រកកោន រឺឋានៈជាជនភៀសខ្លួន ហើយប្រទេសកម្ពុជាជា ហត្ថលេខីនៃអនុសញ្ញា អង្គការសហប្រជាជាតិឆ្នាំ១៩៥១ពាក់ព័ន្ធនឹងឋានៈជាជនភៀសខ្លួន និងពិធីសារឆ្នាំ១៩៦៧។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងការអនុវត្តន៏ជាក់ស្តែង រដ្ឋាភិបាល មិនបាន គោរពអោយបានខ្ជាប់ខ្ជួនទៅតាមច្បាប់ទាំងនោះឡើយ។ របាយការណ៏គួរអោយជឿទុកចិត្ត បានបង្ហាញថា ជនជាតិភ្នំវៀតណាម ដែលស្វែងរក ការជ្រកកោននៅប្រទេសកម្ពុជាត្រូវបានគេចាប់បញ្ជូនចេញវិញដោយ គ្មានការពិនិត្យអោយបានត្រឹមត្រូវឡើយ ទោះបីជាមានវត្តមានរបស់ UNHCR នៅក្នុងប្រទេសហើយក៏ ដោយ UNHCR មានការិយាល័យរបស់ខ្លួននៅទីក្រុងភ្នំពេញ តែបានបិទការិយាល័យនៅខេត្តរតនគីរី ក្នុងខែមេសាតាមសំណូមពរ អាជ្ញាធរដែនដី។ ក្នុងខែកក្កដា ណេះជ្រ បានធ្វើដំណើរទៅកាន់ខេត្តនេះជា ច្រើនលើក ដើម្បីប្រមូលក្រុមជនព្រៃភ្នំដែលបានភៀសខ្លួនពីប្រទេសវៀតណាម។ រដ្ឋាភិបាលបានអនុញ្ញាតអោយ UNHCR ដឹកជញ្ជូនជនទាំងនោះមកទីក្រុងភ្នំពេញ ដើម្បីរៀបចំបែបបទអោយពួកគេចេញទៅតាំងទីលំនៅនៅឯប្រទេស ទីបី ។ ជនជាតិព្រៃភ្នំចំនួន១៣ នាក់ បានសំរេចចិត្តវិលត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ។ មកដល់ចុងឆ្នាំ២០០៤ UNHCR នៅតែបន្តបញ្ជូនពួកគេដែលនៅសេសសល់អោយ ទៅរស់នៅឯប្រទេសទីបីដដែល។ មានពត៏មានជាច្រើនបានរាយការណ៏ថាអាជ្ញាធរវៀតណាមបានផ្តល់ជាប្រាក់រង្វាន់ដល់ ក្រុមប៉ូលីសខ្មែរនៅតាមព្រំដែនដែលបានចាប់បញ្ជូនជនភៀសខ្លួនវៀតណាមទៅកាន់ប្រទេសវៀតណាមវិញ។ ហើយក៏មានរបាយការណ៏ពី វត្តមានរបស់ប៉ូលីសសំងាត់វៀតណាមនៅធ្វើការយ៉ាងសកម្មនៅតាមព្រំដែនលើទឹកដីកម្ពុជា។ ជនស្វែងរកការជ្រកកោននៅបរទេសដែលបានធ្វើដំណើរមកដល់ ការិយាល័យ UNHCR នៅភ្នំពេញ ក៏ត្រូវបានគេរៀបចំសំណុំបែបបទអោយបានទៅរស់នៅឯប្រទេសទីបីផងដែរក្រោមកិច្ចសហប្រតិបត្តិការពី សំណាក់រដ្ឋាភិបាល។ ក្នុងឆ្នាំនេះ ជនភៀសខ្លួនព្រៃភ្នំចំនួន៨៣៦ នាក់ ត្រូវបានបញ្ជូនអោយទៅរស់នៅឯ ប្រទេសទីបីតាមរយះ ការិយាល័យនៅក្រុងភ្នំពេញ។

ការិយាល័យនេះក៏បានបញ្ជូនជនភៀសខ្លួន៦១ នាក់ ដែល មានសញ្ជាតិផ្សេងៗ អោយទៅរស់នៅឯប្រទេសទី បីដែរ។ ទោះបីជា UNHCR បានព្រមព្រៀងនៅឆ្នាំ២០០២ ជាមួយរដ្ឋាភិបាលកម្ពុជានិងវៀតណាមក្នុងការជួយ សំរួលដល់ការធ្វើមាតុភូមិនិវត្តន៏ ដោយស្ម័គ្រចិត្តរបស់ពួកជនជាតិភ្នំដែលបានឆ្លងដែនចូលកម្ពុជាក៏ដោយ ក៏កិច្ចព្រមព្រៀងនោះត្រូវបរាជ័យទៅ វិញ នៅដើមឆ្នាំ២០០៣ ដោយជំរុំតាមខេត្ត

ត្រូវបានគេបញ្ជាអោយបំបាត់ចោល ហើយជនភៀសខ្លួន ដែលនៅសេសសល់ ត្រូវគេបញ្ជូនទៅភ្នំពេញដើម្បី ត្រូវគេបញ្ជូនទៅភ្នំពេញដើម្បី ធ្វើការតាំងទីលំនៅថ្មី។ នៅខែឧសភាឆ្នាំ២០០៣ ជនជាតិភ្នំចំនួន៩០០នាក់ ដែលបានទទួលការអនុញ្ញាតិពីរដ្ឋាភិបាលអោយតាំង ទីលំនៅថ្មីនៅបរទេសកាលពីឆ្នាំ២០០២នោះត្រូវបានគេ ដឹកជញ្ជូនទៅកាន់ប្រទេសទីបី ។

នៅថ្ងៃទី ៥ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជាបានចាប់ជនភៀសខ្លួនកូរ៉េខាងជើងចំនួន ៧នាក់ ហើយនៅថ្ងៃទី ២៤ កញ្ញា សារពតិមានអន្តរជាតិនានាបានរាយការណ៏ថា ជនជាតិកូរ៉េខាងជើងទាំង ៧នាក់នោះ បានធ្វើដំនើរដល់ កូរ៉េខាងត្បូងហើយ ដើម្បីបោះទីតាំងរស់នៅ។

## ផ្នែកទី៣: ការគោរពសិទ្ធិនយោបាយ : សិទ្ធិរបស់ពលរដ្ឋ ក្នុងការផ្លាស់ប្តូររដ្ឋាភិបាល

រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បានផ្តល់សិទ្ធិដល់ពលរដ្ឋក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់ពួកគេដោយសន្តិវិធី ហើយតាមការអនុវត្តន៏ជាក់ស្តែង ប្រជាពលរដ្ឋខ្មែរបានប្រើប្រាស់សិទ្ធិនេះតាមរយៈការបោះឆ្នោតជាសកល។ សិទ្ធិបោះឆ្នោតគឺជាសេរីភាពរបស់ពលរដ្ឋគ្រប់រូបដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ មានពលរដ្ឋប្រហែល ជា ៨៣% នៃចំនួនអ្នកចុះឈ្មោះបោះឆ្នោតបានចេញទៅបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាជាតិ នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៣។ ក្នុងការបោះឆ្នោតលើកនេះ គណបក្សប្រជាជនកម្ពុជាបានទទួលសំលេង ៧៣អសនៈ រីឯគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ២៦អសនៈ និង គណបក្សសមរង្ស៊ីទទួលបាន ២៤អសនៈ។ នៅខែកក្កដា ២០០៤ គណបក្សប្រជាជន និងគណបក្សហ៊្វុនស៊ិនប៉ិច បានយល់ព្រមបង្កើតរដ្ឋាភិបាលចំរុះមួយ ដែលមានតែឈ្មោះ ប៉ុន្តែតាមពិតរដ្ឋាភិបាលចំរុះនោះឋិតនៅក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាជន ទាំងស្រុង។ ក្រុមអ្នកសង្កេតការបោះឆ្នោតទាំងអស់ ដែលរួមមានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក បានកត់សំគាល់ថា ការបោះឆ្នោតនៅក្នុងខែកក្កដាកន្លង ទៅនេះ មានភាពប្រសើរជាងការបោះឆ្នោតមុនៗ ប៉ុន្តែពួកគេ ក៏បានសន្និដ្ឋានផងដែរថាការបោះឆ្នោតលើកនេះ នៅពុំទាន់មានលក្ខណៈប្រជាធិបតេយ្យគ្រប់គ្រាន់តាមខ្នាតអន្តរជាតិនៅឡើយទេ។ អំពើហិង្សានយោបាយ នៅតែជាបញ្ហាតែវាមានចំនួនតិច ជាងការបោះឆ្នោតមុនៗ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកបានរាយការណ៏ថា មានឃាតកម្ម៣៣ករណីដែលទំនងជាឃាតកម្មនយោ បាយក្នុងកំឡុងឆ្នាំបោះឆ្នោតនោះ។ គោលបំណងភាគច្រើននៃឃាតកម្មទាំងនោះមិនបានគេដឹងច្បាស់លាស់ទេ។ រដ្ឋាភិបាលគ្រាន់តែបានចាត់វិធានការប្រឆាំងនឹងជនល្មើសខ្លះប៉ុណ្ណោះ ហើយធ្វើការដោះ ស្រាយចំពោះ បទល្មើសផ្សេងៗទៀតដោយមិនសមស្រប។ បញ្ហាបច្ចេកទេស នៃដំនើរការចុះ

បញ្ជីឈ្មោះ ហើយនិងការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតបានធ្វើ អោយ ប្រជាពលរដ្ឋជាច្រើនបាត់បង់សិទ្ធិក្នុងការបោះឆ្នោត។ ក្នុងពេលជាមួយគ្នានេះផងដែរ ក៏មានករណីគំរាម និងបំភ័យអ្នកបោះឆ្នោតពីសំណាក់មន្ត្រីមូលដ្ឋាន។ គណកម្មការជាតិរៀបចំការបោះឆ្នោតខកខានក្នុងការ បង្កើតដំនើរការមួយដែលអាចទុកចិត្តបាន ដើម្បីដោះស្រាយពាក្យបណ្តឹងអំពីការបោះឆ្នោតរួមទាំងការចោទ ប្រកាន់អំពីការគំរាមបំភិតបំភ័យនយោបាយ ការចែកអំនោយ ការទិញសន្លឹកឆ្នោត និងភាពមិនប្រក្រតីក្នុង និតិវិធីផ្សេងៗ។ ការតែងតាំងដោយក្រសួងមហាផ្ទៃនូវសមាជិកនៃគណកម្មការជាតិរៀបចំការបោះឆ្នោតបាន ធ្វើឡើងដោយគ្មានតម្លាភាព ហើយបានធ្វើអោយគណកម្មការជាតិរៀបចំការបោះឆ្នោតនេះរងនូវការចោទ ប្រកាន់ថាបានទទួលឥទ្ធិពលនយោបាយពីគណបក្សប្រជាជនកម្ពុជា។

ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សដែលបានចុះឈ្មោះចូលរួមប្រកួតប្រជែង មានភាពល្អប្រសើរជាងមុន ហើយការពិភាក្សានយោបាយដោយចំហរ និងការពិភាក្សាជាពហុបក្សត្រូវបានផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍របស់ជាតិជាលើកដំបូង។ ប៉ុន្តែ ការផ្សាយពតិមានតាមប្រព័ន្ធអេឡិចត្រូនិច នៅតែមានភាពលំអៀងយ៉ាងខ្លាំងទៅលើគណបក្សប្រជាជនដែលកំពុងកាន់អំណាច។ ក្នុងខែមិថុនា ២០០៣ មានស្ថានីយ៍វិទ្យុនិងទូរទស្សឯកជនយ៉ាងតិចចំនួន ៦ មិនព្រមលក់ម៉ោងផ្សាយខ្លួន ទៅអោយគណបក្សនយោបាយផ្សេងៗដែលទិដ្ឋភាពនេះត្រូវបានគេមើលឃើញថាជាការបំពេញចិត្តដល់គណបក្សប្រជាជន។ ស្ថានីយ៍ទូរទស្សន៍របស់ជាតិ ជាប្រព័ន្ធផ្សព្វផ្សាយតែមួយគត់ដែលបានផ្សព្វផ្សាយពតិមានទាំងឡាយ ទាក់ទងដល់ការបោះឆ្នោតហើយស្ថានីយ៍វិទ្យុឯកជនចំនួន៩បានលក់ម៉ោងផ្សាយខ្លួនទៅអោយគណបក្សនយោបាយផ្សេងៗ។ អង្គការមិនមែនរដ្ឋាភិបាល និង គណបក្សនយោបាយខ្លះបានចោទប្រកាន់ថាសមាជិកភាពក្នុងគណបក្សប្រជាជនមានប្រៀបជាងក្នុងការទទួលយកអំណោយ និងលទ្ធភាពដើម្បីទទួលអំនោយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល។ គ្មានការរឹតត្បិតចំពោះការចូលរួមផ្នែកនយោបាយនៅក្នុងសង្គមដែលមានលក្ខណៈបុរាណទេ ក៏ប៉ុន្តែសម្តេចព្រះសង្ឃរាជគណមហានិកាយ ទេព វង្ស ដែលគេជឿថាគាំទ្ររដ្ឋាភិបាល បានចេញនូវបញ្ញត្តិនូវមួយជំរុញព្រះសង្ឃមិនអោយចូលរួមក្នុងការបោះឆ្នោត។ រដ្ឋាភិបាលមិនបានហាមឃាត់ដល់ក្រុមយុវជនក្នុងការបង្កើតគណបក្សនយោបាយទេ ប៉ុន្តែក៏មិនបានរារាំងសកម្មភាពនានារបស់សមាគមក្មេងវត្តដែលគាំទ្រគណបក្សប្រជាជន នៅពេលពួកគេធ្វើបាតុកម្មបង្ក្រាបក្រុមប្រឆាំង។

នៅឆ្នាំ ២០០២ រដ្ឋាភិបាលបានរៀបចំការបោះឆ្នោតថ្នាក់ជាតិឃុំសង្កាត់ជាលើកដំបូង។ លទ្ធផលនៃការបោះឆ្នោតឃុំសង្កាត់នោះ បានធ្វើអោយបាត់បង់អំនាចខ្លះរបស់គណបក្សប្រជាជន ដែលបានគ្រប់គ្រង

លើរដ្ឋបាលមូលដ្ឋាននេះ អស់រយៈពេល ២៣ឆ្នាំមកហើយ។ គណបក្សប្រជាជនបានទទួលសំលេង ៧៧០៣ អសនៈឃុំទូទាំងប្រទេស គណបក្សហ្វ៊ុនស៊ិនប៉ិចបានទទួល ២២១១ អសនៈ និងគណបក្សសមរង្ស៊ីបានទទួល ១៣៤៦ អសនៈ។ ទោះបីជាគណបក្សប្រជាជនបានទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំចំនួន ៩៩%នៃចំនួន

ឃុំសរុប ១៦២១ ក៏ដោយ លទ្ធផលនៃការបោះឆ្នោតនោះបានផ្តល់អោយគណបក្សដ៏ទៃទៀតមានសិទ្ធិចូលរួម ក្នុងការកាន់អំណាចក្រុមប្រឹក្សាឃុំទាំងអស់ លើកលែងតែចំនួន ១៤៨ឃុំទេ។ ការផ្ទេរអំនាចដល់ក្រុមប្រឹក្សា ឃុំសង្កាត់ដែលបានជាប់ឆ្នោតថ្មី បានប្រព្រឹត្តទៅដោយរលូន ហើយក្រុមប្រឹក្សាឃុំសង្កាត់ជាច្រើនមានតំណាង ជ្រើសចេញពីគណបក្សនយោបាយធំៗទាំងបី។ មកដល់ចុងឆ្នាំ២០០៣នេះ ក្រសួងមហាផ្ទៃនៅមិនទាន់បាន ចេញនូវសេចក្តីណែនាំដល់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាប់ឆ្នោតនោះអោយអនុវត្តច្បាប់ គ្រប់គ្រងឃុំសង្កាត់ ដែលបានចែងពីអំនាច តួនាទី និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាឃុំទាំងអស់នោះនៅឡើយទេ។ ក្នុងកំឡុងពេលឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នោះ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា សកម្មជន និង បេក្ខជន របស់គណបក្សហ្វ៊ុនស៊ិនប៉ិច និងសមរង្ស៊ីចំនួន ២៥នាក់ត្រូវបានគេធ្វើឃាត ក្នុងសភាពគួរអោយសង្ស័យហើយក្នុងចំនួននោះ អង្គការសិទ្ធិមនុស្សបានវាយតំលៃថា ឃាតកម្មចំនួន ៧ករណី ជារឿងនយោបាយ។ វប្បធម៌បូរាណបានកំរិតតួនាទីរបស់ស្ត្រីនៅក្នុងរដ្ឋាភិបាល។ ប៉ុន្តែស្ត្រីបានចូលរួមយ៉ាង សកម្មក្នុង ការបោះឆ្នោតជ្រើសរើសសភាជាតិ ខែកក្កដា ឆ្នាំ២០០៣កន្លងទៅនេះ។ ក្រោយការបោះឆ្នោតនេះ មានស្ត្រី ២២រូបបាន ជាប់ឆ្នោតជាសមាជិកសភា នៅក្នុងរដ្ឋសភាដែលមានចំនួនសមាជិកសរុប ១២៣នាក់។ ក្នុងចំនោមកៅអី ៦១ របស់ព្រឹទ្ធសភា ក៏មានស្ត្រីចំនួន ១១រូបដែរ។ ក្នុងរដ្ឋាភិបាលដែលបានបង្កើតថ្មី មានស្ត្រី ២៤រូបមានតំណែងជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងគណ កម្មការជាតិរៀបចំការបោះឆ្នោត។ ហើយមានស្ត្រីមួយចំនួនទៀតបំរើការជាទីប្រឹក្សានិងស្ត្រី១២រូបធ្វើជាចៅក្រម ហើយនាយកសាលាភូមិន្ទ ចៅក្រមក៏ជាស្ត្រីដែរ។ ក្រោយការបោះឆ្នោតថ្នាក់មូលដ្ឋានឆ្នាំ ២០០២មក មានស្ត្រីចំនួន ៩៣៣នាក់ (៨,៣%) បានកាន់កាប់អសនៈនៅក្នុង ក្រុមប្រឹក្សាឃុំសង្កាត់ដែលមានចំនួន សរុប១១ ២៦១កៅអី។ ក្រុមជនជាតិភាគតិចក៏បានចូលរួមក្នុងជួររដ្ឋាភិបាលដែរ។ ការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា ខែកក្កដា កន្លងទៅនេះបានផ្តល់សិទ្ធិដល់ជនជាតិភាគតិចចំនួន ៦រូប ក្នុងនោះមានចាម ២រូប កុលសម្ព័ន្ធ ២រូប និងថៃ២រូប បានជាប់ឆ្នោតនៅក្នុងសភាជាតិដែលមាន អសនៈសរុប ១២៣។ លើសពីនេះទៀត ក៏មានតំណាង ៦ រូបមកពីក្រុមជនជាតិភាគតិចផងដែរ (ចាម, កុលសម្ព័ន្ធ និងថៃ) ដែលអង្គុយក្នុងអសនៈព្រឹទ្ធសភាដែល មានចំនួនសរុប ៦១រូប។ យ៉ាងហោចណាស់មានមន្ត្រី៥រូប

ដែលមានតំណែងជាន់ខ្ពស់ក្នុងរដ្ឋាភិបាល ចេញមក ពីក្រុមជនជាតិភាគតិច ផ្សេងៗដែរ ។

**ផ្នែកទី៤ : ឥរិយាបថរដ្ឋាភិបាលចំពោះការស៊ើបអង្កេតអន្តរជាតិនិងអង្គការ មិនមែនរដ្ឋាភិបាលលើការចោទប្រកាន់ស្តី ពីការរំលោភសិទ្ធិមនុស្ស**

សមាគមអង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិជាច្រើនបានធ្វើសកម្មភាពស៊ើបអង្កេត និងបោះពុម្ពផ្សាយរបកគំហើញរបស់គេលើករណីសិទ្ធិមនុស្សដោយមិនមានការគាបសង្កត់ពីរដ្ឋាភិបាលទេ។ ជាទូទៅរដ្ឋា ភិបាលសហការណ៍ជាមួយបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតប៉ុន្តែនៅក្នុងឆ្នាំនេះ មានរបាយការណ៍មួយ ចំនួននិយាយអំពីភាពមិនសូវសហការ រឺ ការគំរាមកំហែងរបស់អាជ្ញាធរមូលដ្ឋាននៅទូទាំងប្រទេសដែរ។ អង្គការក្រៅរដ្ឋាភិបាលប្រមាណជា៤០ មានសកម្មភាពទាក់ទងនឹងសិទ្ធិមនុស្សទោះបីជាមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានសកម្មភាពយ៉ាងសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល រឺស៊ើបអង្កេតលើបទល្មើសនានា។

នៅឆ្នាំនេះ មានការគំរាមចំពោះអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលផ្តល់ជំរកដល់ជនរងគ្រោះដោយសារការជួញដូរ និង ធ្វើការតស៊ូមតិនិងស៊ើបអង្កេតប្រឆាំងការជួញដូរបានធ្វើអោយអង្គការក្រៅរដ្ឋាភិបាលព្យួរការស៊ើបអង្កេត របស់ខ្លួនទៅលើក្រុមជួញដូរមនុស្ស។ ការគំរាមកំហែងនោះបានប្រព្រឹត្តដោយពួកជួញដូរមនុស្ស និងមានការចូលលុកលុយដល់ទីស្នាក់ការផង។ ខុសពីសកម្មភាពឆ្នាំមុនៗ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការស៊ើរអង្កេត លើសកម្មភាពកាប់ឈើខុសច្បាប់មិនបានអោយដឹងអំពីការរំខានដល់សកម្មភាពគេឡើយ។

នៅឆ្នាំ ២០០២ រដ្ឋាភិបាលនិង UNHCHR បានចុះហត្ថលេខាលើអនុស្សរណយោគយល់មួយស្តីពីការពន្យារវត្តមានការិយាល័យរបស់ UNHCHR នៅក្នុងប្រទេសកម្ពុជារយៈ ពេល២ឆ្នាំបន្ថែមទៀត។ UNHCHR ត្រូវពិភាក្សាសុំពន្យាអនុស្សរណយោគយល់នេះទៀតនៅចុងឆ្នាំ២០០៤។ UNHCHR បានធ្វើសកម្មភាពជាច្រើន ទាក់ទងនឹងសិទ្ធិមនុស្សនិងតុលាការ ហើយបានរក្សាទីស្នាក់ការរបស់ខ្លួននៅទីក្រុងភ្នំពេញ និងមានការិយាល័យតំបន់មួយទៀតនៅក្នុងខេត្តបាត់ដំបង។

គណកម្មការសិទ្ធិមនុស្សកម្ពុជា ដែលរដ្ឋាភិបាលបានបង្កើតកាលពីឆ្នាំ១៩៩៨ ជារួមមានភាពអកម្ម

ហើយគណកម្មការនេះ មិនមានការប្រជុំជាទៀងទាត់ និងមិនមានលក្ខណៈគួរអោយទុកចិត្តឡើយ។ ក្នុងខែមេសា គណកម្មាការនេះបានចេញផ្សាយរបាយការប្រចាំឆមាសជាលើកដំបូង ស្ដីពីការធ្វើឃាតដោយហ្វូងមហាជន តែរបាយការនោះមិនបាននិយាយពីការសំលាប់លើប្រធានសហជីពជា វិជ្ជានិងរឿងរំលោភសិទ្ធិធ្ងន់ៗផ្សេងទៀតឡើយ។

## ផ្នែកទី៥: ការរើសអើង ការមើលងាយក្នុងសង្គម ការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញហាមប្រាមការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឬក៏ ទស្សនៈនយោបាយផ្សេងៗ។ ទោះបីច្បាប់បានចែងយ៉ាងដូច្នេះក៏ដោយ ក៏រដ្ឋាភិបាលមិនសូវជាបានផ្ដល់ការការពារដល់សិទ្ធិទាំងអស់នេះឡើយនៅក្នុងការអនុវត្តជាក់ស្ដែង។

### ស្ត្រី

អង្គការក្នុងស្រុក និងអន្តរជាតិនានាបានរាយការណ៍ថា អំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ រួមមានអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភជារឿងដែលកើតមានឡើងច្រើន។ ច្បាប់បានហាមប្រាមលើការរំលោភនិងការវាយប្រហារផ្សេងៗ។ ការរំលោភក្នុងអាពាហ៍ពិពាហ៍ និងការរំលោភបំពានក្នុងគ្រួសារមិនត្រូវបានគេចាត់ទុកថាជាបទល្មើសណាមួយឡើយ។ ករណីរំលោភក្នុងអាពាហ៍ពិពាហ៍មួយ អាចត្រូវគេកាត់ទោសថាជា "បទល្មើស រំលោភ" "បទបង្កអោយមានរបួសស្នាម" រឺ "អំពើអាសអាភាសដោយបង្ខំ" ប៉ុន្តែការចោទប្រកាន់បែបនេះមិន សូវមានទេ។ ចាប់តាំងពីខែមករាដល់វិច្ឆិកា ក្រសួងមហាផ្ទៃបានស៊ើបអង្កេតលើបណ្ដឹងរំលោភផ្លូវភេទចំនួន ២៧០ ហើយបានឃាត់ខ្លួនជនល្មើសចំនួន២៩៧ នាក់។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយបានរាយការណ៍ថា ពីខែមករា ដល់តុលាឆ្នាំ២០០៤ មានអំពើហិង្សាទៅលើស្ត្រីភេទចំនួន ៣៨៧ ករណី ក្នុងនោះបណ្ដាលអោយស្លាប់២២ ករណី និងរបួសស្នាម៣០៦ ករណី។ ក្នុងចំណោមការរំលោភផ្លូវភេទចំនួន២៦៧ករណី ដែលបានកត់ត្រាដោយអង្គការក្រៅរដ្ឋាភិបាលពីខែមករាដល់តុលា មាន៦ករណីស្លាប់ និង១៧១ ករណីផ្សេងទៀតទាក់ទងដល់អនិតិជន។ ជាធម្មតា អាជ្ញាធរបានបដិសេធមិនព្រមពាក់ព័ន្ធក្នុងជំលោះ ក្នុងគ្រួសារ ទេហើយជនរងគ្រោះជានិច្ចកាលក៏មិនចង់ ដាក់ពាក្យបណ្ដឹងជាផ្លូវការដែរ។ ក្នុងពាក្យបណ្ដឹង ចំនួន១៣៥ករណី ដែលបានដាក់ទៅតុលាការ មានជនល្មើសចំនួន១៨

នាក់ត្រូវបានចាប់ខ្លួន ហើយមិនទាន់មានជនណាម្នាក់ត្រូវបានគេកាត់ទោសឡើយ។

ពេស្យាចារត្រូវបានហាមឃាត់ដោយរដ្ឋធម្មនុញ្ញ ប៉ុន្តែមិនមានការចែងជាច្បាប់ជាក់លាក់ដើម្បីប្រឆាំងនឹងការធ្វើជាពេស្យាចារនេះឡើយ។ ការជួញដូរស្ត្រីអោយធ្វើជាពេស្យាគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ទោះបីជាមានច្បាប់ប្រឆាំងនឹងសច្ចារកម្ម និងពង្រត់ក្នុងគោលបំនងកេងប្រវ័ញ្ចផ្លូវភេទក៏ដោយ (សូមមើលផ្នែក ៥ ស្តីពីការជួញដូរមនុស្ស)។

ទោះបីជាមានការបង្ក្រាបលើផ្ទះបនដែលធ្វើឡើងយូរៗម្តងនៅក្នុងក្រុងភ្នំពេញក៏ដោយ ក៏ពេស្យា ចារ និងការជួញដូរដែលទាក់ទិន នៅតែបន្តជាបញ្ហា។ របាយការណ៍ឆ្នាំ១៩៩៧មួយរបស់គណកម្មការសិទ្ធិ មនុស្សដែលដាក់ជូនទៅសភាជាតិបានអោយដឹងថា មានស្ត្រីប្រកបរបរពេស្យាចារចំនួន១៤៧២៥នាក់ ហើយ ចំនួននេះត្រូវបានបញ្ជាក់ដោយការសិក្សាស្ថិតិមួយនៅឆ្នាំនោះដែរ ដែលបានប៉ាន់ប្រមាណថាមានពេស្យាចារ ១៨២៥៦នាក់ នៅក្នុងប្រទេសកម្ពុជា។

បញ្ញត្តិមួយក្នុងច្បាប់ការងារមានចែងពីការប្រឆាំងនឹងការបៀតបៀនផ្លូវភេទនៅក្នុងកន្លែងធ្វើការ ហើយអង្គការ ពលកម្មអន្តរជាតិ (ILO) រាយការណ៍ថាការបៀតបៀនផ្លូវភេទនៅក្នុងផ្នែកឧស្សាហកម្មមិនសូវកើតមានទេ។ គ្មានរបាយការនិយាយអំពីការបៀតបៀនផ្លូវភេទមានកើតនៅក្នុងផ្នែក ផ្សេងៗទៀតនៃសេដ្ឋកិច្ចទេ។

រដ្ឋធម្មនុញ្ញមានចែងនូវពាក្យពេចន៍ដោយជាក់លាក់ដែលផ្តល់នូវសិទ្ធិស្មើគ្នាសំរាប់ស្ត្រី ដូចជាប្រាក់បៀវត្សន៏ស្មើគ្នាសំរាប់ការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៏ពិពាហ៏។ ក្នុងការអនុវត្ត ស្ត្រីមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិស្មើគ្នានឹងបុរស មានឋានៈស្មើគ្នាក្នុងការស្នើសុំលែងលះ និងមានលទ្ធភាពទទួលការអប់រំ និងការងារស្មើបុរស។ ប៉ុន្តែ វប្បធមិប្រពៃណីបានបន្តក៏រិតលទ្ធភាពស្ត្រីក្នុងការចាប់យកមុខតំនែងធំដុំនៅក្នុងជំនួញ និងផ្នែកដទៃទៀត។ ការប្រែប្រួលផ្នែកប្រជាសាសន៏និង ប្រវត្តិទំនាស់ក្នុងសង្គម បានញាំងអោយមានការកើន ឡើងខាងកំលាំង ពលកម្មដែលមានការចូលរួមយ៉ាងច្រើនពីស្ត្រី។ ការអង្កេតថ្មីមួយ អំពីកំលាំងពលកម្មបានអោយដឹងថា ស្ត្រីមានចំនួន៥២ភាគរយនៃចំនួនប្រជាជនទាំងអស់ ៦០ភាគរយនៃអ្នកប្រកបរបរកសិកម្ម ៨៥ភាគរយនៃអ្នក ប្រកបរបរជំនួញ ៧០ភាគរយនៃកំលាំងការងារផ្នែកឧស្សាហកម្ម និងមានភាគរយយ៉ាងខ្ពស់កំលាំងសរុបក្នុងវិស័យកាត់ដេរ ៦០ភាគរយនៃកម្មករផ្នែកសេវាកម្ម ទាំងអស់ដែលស្ថិតនៅផ្នែកឧស្សាហកម្មទេសចរ។ ស្ត្រីច្រើននៅផ្តុំគ្នានៅផ្នែកដែលទទួលបាន ប្រាក់កំរៃទាប នៃវិស័យទាំងនេះ។ ហើយភាគច្រើនមិន ត្រូវបានគេបញ្ចូលទៅក្នុងតំនែងថ្នាក់គ្រប់គ្រងដឹកនាំទេ។ មានបុរសភាគ

ច្រើនបានបំរើការវិស័យយោធា ប៉ូលីសនិងមន្រ្តីរាជការ ។

មានអង្គការស្ត្រីមួយចំនួនធំដែរដែលផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីក្រីក្រ និងស្ត្រីមេម៉ាយ និងបានដោះស្រាយបញ្ហាសង្គមជាច្រើនដូចជាការរំលោភបំពានពីស្វាមី ពេស្យាកម្ម និងការជួញដូរជាដើម។ មជ្ឈមណ្ឌលពតិមានមួយបានផលិត និងចាក់ផ្សាយកម្មវិធីទាក់ទងនឹងបញ្ហារបស់ស្ត្រី។ អង្គការក្រៅរដ្ឋាភិបាលក៏បានផ្តល់ទីជំរកដល់ស្ត្រីដែលមានវិបត្តិផងដែរ ។

កុមារ

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិសំរាប់កុមារ និងធានាថា សុខមាលភាពរបស់កុមារគឺជាទិសដៅមួយជាក់លាក់នៅក្នុងកម្មវិធីនយោបាយរបស់រដ្ឋាភិបាល។ រដ្ឋាភិបាលពឹងផ្អែកលើជំនួយអន្តរជាតិដើម្បីផ្តល់មូលនិធិចំពោះកម្មវិធីសុខមាលភាពសង្គមជាច្រើនសំរាប់កុមារ ដែលធ្វើអោយមានថវិការតែបន្តិចបន្តួចប៉ុណ្ណោះសំរាប់ប្រើក្នុងការដោះស្រាយបញ្ហាដែលប៉ះពាល់ដល់កុមារ ។

កុមារត្រូវរងការប៉ះពាល់យ៉ាងខ្លាំងក្លាពីកង្វះខាតប្រព័ន្ធអប់រំ។ កុមារអាចទទួលការអប់រំដោយមិនបាច់ បង់ថ្លៃរហូតដល់ថ្នាក់ទី៩ ប៉ុន្តែវាមិនមែនជាកាតព្វកិច្ចទេ។ កុមារជាច្រើន ខ្លះត្រូវបោះបង់ការសិក្សាដើម្បីជួយ ដល់គ្រួសារប្រកបរបរកសិកម្មដែលគ្រាន់តែដើម្បីផ្គត់ផ្គង់ជីវភាព ខ្លះបានចូលសាលានៅពេលពួកគេមានអាយុ ច្រើន ហើយខ្លះទៀតមិនបានចូលរៀនទាល់តែសោះ។ របាយការណ៍ឆ្នាំ២០០៣ របស់ក្រសួងអប់រំនិយាយថា ការចុះឈ្មោះចូលរៀននៅថ្នាក ់បឋមសិក្សាមានចំនួន៩០ភាគរយ ប៉ុន្តែមានសិស្សប្រហែលតែ២១ភាគរយ ដែលបានចូលរៀនថ្នាក់មធ្យមសិក្សា។ ទោះបីជារដ្ឋាភិបាលមាន កម្មវិធីសាងសង់សាលារៀនជាច្រើន ក្តី ក៏សាលានៅតែមានលក្ខណៈចង្អៀតខ្លាំងព្រមទាំងខ្វះខាតសម្ភារៈសិក្សាថែមទៀត ហើយ សាលារៀនដែល នៅទីជនបទឆ្ងាយៗមានលទ្ធភាពបង្រៀនត្រឹមតែថ្នាក់ទី២រឺទី៣តែប៉ុណ្ណោះ។ របាយការនោះបាននិយាយថាសាលាប្រមាណ៥២ភាគរយជួបកង្វះខាតទឹកស្អាតសំរាប់បរិភោគ និង៤១ ភាគរយ គ្មានបង្គន់ប្រើប្រាស់។ គ្រូបឋមសិក្សាចំនួនតិចជាង ៥ភាគរយបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ប្រាក់ខែគ្រូបង្រៀនមិន បានបើកអោយបានទៀងទាត់ទេ ហើយប្រាក់ខែនោះទៀតសោត មិនគ្រប់គ្រាន់សំរាប់អោយគេមានជីវភាព រស់នៅបានសមរម្យឡើយ។ កង្វះខាតនេះបានជំរុញអោយលោកគ្រូអ្នកគ្រូមួយចំនួនបានតំរូវអោយឪពុកម្តាយរបស់សិស្សបង់ប្រាក់ក្រៅផ្លូវការមួយចំនួន ដែលគ្រួសារក្រីក្របំផុតមិនអាចមានលទ្ធភាពបង់បាន។ រដ្ឋាភិបាលមិនបានហាមឃាត់ ក្មេងស្រីមិនអោយរៀនសូត្រទេ ប៉ុន្តែក្នុងជីវភាពជាក់ស្តែងគ្រួសារដែលមានធនធានតិចតែងតែផ្តល់ អាទិភាពទៅអោយកូន

ប្រុសបានចូលរៀនសូត្រ។ នៅតំបន់ជាច្រើន សាលារៀនឋិតនៅឆ្ងាយពីលំនៅដ្ឋាន ពេលនោះការធ្វើដំណើរទៅមកក៏ក្លាយជាបញ្ហាចំបងមួយទៀត។ បញ្ហានេះមានផលប៉ះពាល់ជាពិសេសទៅ លើក្មេងស្រី ដោយសារការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់ពួកគេក្នុងការធ្វើដំណើរ ពីផ្ទះទៅសាលារៀន។

កុមារជាច្រើនទទួលរងគ្រោះដោយសារកង្វះជីវជាតិ និងប្រព័ន្ធថែទាំសុខភាព។ នៅឆ្នាំ ២០០២ អត្រាស្លាប់របស់កុមារត្រូវបានគេប៉ាន់ប្រមាណថាមានប្រហែល៩៦ក្នុង១០០០នាក់។

គេក៏បានប៉ាន់ស្មានផងដែរថា អត្រាស្លាប់ សំរាប់កុមារអាយុក្រោម៥ឆ្នាំ មាន១៣៨នាក់ក្នុង១០០០។ ការធ្វើបាបលើកុមារត្រូវបានគេជឿថាជារឿង ដែលកើតមានជាធម្មតា ទោះបីជាមិនមានស្ថិតិណាមួយបានបង្ហាញច្បាស់លាស់ក៏ដោយ។ អង្គការក្នុងស្រុក មួយបានប៉ាន់ស្មានថាមានកុមារច្រើន ជាង១៥០០នាក់រស់នៅតាមចិញ្ចើមផ្លូវដែលបានកាត់ផ្តាច់ទំនាក់ទំនងជា មួយគ្រួសារទាំងស្រុង និងមានកុមារជាង១០០០០នាក់ទៀតដែលបានធ្វើការតាមចិញ្ចើមផ្លូវប៉ុន្តែត្រលប់ទៅផ្ទះ គ្រួសារគេវិញនៅពេលល្ងាច។ គេបានប៉ាន់ស្មានថាមានក្មេងអនាថាតាមចិញ្ចើមផ្លូវចំនួន៩៥០នាក់ទៅ១៥០០នាក់ដែលកំពុងរស់នៅទីរួមខេត្តនាៗ។

ក្នុងខែមិថុនា ២០០៤ អភិបាលក្រុងភ្នំពេញបានអនុវត្តកម្មវិធីចំរូងចំរាស់មួយ ស្តីពីការចាប់ប្រមូលកុមារអនាថាតាមចិញ្ចើមថ្នល់ដោយគេបានលើកហេតុផលថា វត្តមានកុមារទាំងនោះបានបង្កអោយមានការពិបាកដល់ភ្នែកទេសចរបរទេស។ មានរបាយការណ៍ខ្លះបាននិយាយថា រដ្ឋភិបាលបានបញ្ជូនកុមារទាំងនោះទៅអង្គការមិនមែនរដ្ឋាភិបាលនៅខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការព្យាបាលការញៀនថ្នាំ។ មានកុមារជាច្រើនត្រូវគេដាក់ចោលនៅតាមផ្លូវ ហើយក្រោយមកពួកគេក៏ធ្វើមកក្រុងភ្នំពេញវិញដដែល។ ទោះជាយ៉ាងនេះក្តី គេមិនបានតាមពិនិត្យរកក្មេងទាំងនោះទេ ហើយគ្មានអង្គការក្រៅរដ្ឋាភិបាលណាមួយបានអះអាងថាបានទទួលក្មេងទាំងនោះឡើយ។ ទោះបីជាការរួមភេទជាមួយនឹងក្មេងអាយុក្រោម១៥ឆ្នាំជាអំពើ ខុសច្បាប់ក៏ដោយ ក៏ពេស្យាកម្ម និងការជួញដូរកុមារជាបញ្ហាកើតមានស្ទើរគ្រប់ទីកន្លែង (សូមមើលផ្នែកទី៥ស្តីពីការជួញដូរមនុស្ស)។ នៅឆ្នាំ ២០០០ រដ្ឋាភិបាលបានបង្កើតគំរោងការ ៥ឆ្នាំមួយសំរាប់ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ដែលសង្កត់ធ្ងន់ទៅលើការ ទប់ស្កាត់តាមរយៈការផ្សព្វផ្សាយពតិមាន និងការការពារតាមរយៈការអនុវត្តន៍ច្បាប់ ( សូមមើលផ្នែកទី៥ស្តីពីការជួញដូរមនុស្ស )។ ក្នុងកំឡុងឆ្នាំ២០០៤នេះ មានយ៉ាងតិចក៏៥ករណីដែរ ដែលជនបរទេសត្រូវបានគេចោទប្រកាន់ពីបទថតរូបភាពអាសអាភាស និងការរួមភេទជាមួយកុមារ។ ការរួមភេទជាមួយកុមារ នៅតែជាបញ្ហាធ្ងន់ធ្ងរដដែលក្នុងប្រទេសកម្ពុជា។ មានការរួមភេទជាមួយកុមារចំនួន ៥៧ករណីដែលគេប្រព្រឹត្តជាមួយកុមារក្រោមអាយុ ១០ឆ្នាំ នៅចន្លោះខែ

មករា ដល់ខែតុលា ។

ការទិញនិងលក់ទារកនិងកុមារដោយខុសច្បាប់ដើម្បីអោយធ្វើជាពេស្យារឺធ្វើជាកូនចិញ្ចឹម ក៏ជាបញ្ហាធ្ងន់ធ្ងរមួយទៀត ។ ក្នុងឆ្នាំនេះ ការចុះបង្ក្រាបផ្ទះបន បានរំដោះក្មេងស្រីមិនទាន់គ្រប់អាយុមួយចំនួន ដែលត្រូវបានគេ ជួញដូរចូលមកកម្ពុជាអោយធ្វើជាពេស្យាចារ ។ នៅឆ្នាំ២០០៤ គ្មានរបាយការស្តីពីបុគ្គល រឺអង្គការ បានទិញទារករឺកុមារពីឳពុកម្តាយបង្កើតរបស់គេដើម្បី លក់បន្តទៅអោយគ្រួសារណា ដែលចង់បានកូនយកមកចិញ្ចឹមទេ ។ លទ្ធផលនេះកើតឡើង ក្រោយពីមានការផ្អាក ការសុំកូនមកចិញ្ចឹមមួយរយៈសិន ចំពោះសហរដ្ឋអាមេរិក បារាំង និងព្រះរាជាណាចក្រអង់គ្លេស ។ មានក្មេងមួយចំនួនក្នុងចំនោមក្មេង ដែលគេសុំយកទៅចិញ្ចឹមត្រូវបានគេកេងប្រវ័ញ្ច ។ ក្នុងករណីខ្លះជនល្មើសបានជំរុញស្ត្រីជាម្តាយអោយ បោះបង់កូនរបស់គេ ដោយការបោកប្រាស់ ដូចជាសន្យាថាមើលថែក្មេងនោះតែមួយរយៈប៉ុណ្ណោះ ប៉ុន្តែក្រោយមកគេមិនព្រមប្រគល់ក្មេងទៅអោយម្តាយបង្កើតវិញឡើយ ។

ពលកម្មកុមារគឺជាបញ្ហាមួយដែលគេបានជួបប្រទះនៅក្នុងផ្នែកផ្សេងៗនៃសេដ្ឋកិច្ចជាតិ (សូមមើលផ្នែកទី៦.ឃ) ។

## ការជួញដូរមនុស្ស

ច្បាប់បានហាមឃាត់ការជួញដូរមនុស្ស ក៏ប៉ុន្តែមនុស្សត្រូវបានគេជួញដូរមកប្រទេសកម្ពុជា ចេញពីប្រទេសកម្ពុជា និងនៅក្នុងប្រទេសកម្ពុជា ។ ច្បាប់ស្តីពីការបង្ក្រាបការចាប់ពង្រត់ ជួញដូរ និងកេងប្រវ័ញ្ចលើមនុស្ស (ច្បាប់ជួញដូរ) ផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ទៅ២០ឆ្នាំចំពោះជនណាដែលមានទោសពីបទជួញដូរមនុស្សអាយុក្រោម១៥ឆ្នាំ និងពី១០ទៅ១៥ឆ្នាំសំរាប់ការជួញដូរមនុស្សអាយុលើស១៥ឆ្នាំ ។

នៅខែតុលាក្នុងការប្រជុំមួយស្តីពីគំនិតផ្តួចផ្តើមរបស់រដ្ឋមន្ត្រីនៃក្រុមប្រទេស តាមដងទន្លេមេគង្គដើម្បីប្រឆាំងនឹងការជួញដូរមនុស្ស (CMMIAT) ប្រទេសកម្ពុជាចូលរួមជាមួយប្រទេស ៥ផ្សេងទៀតក្នុងតំបន់ក្នុងការចុះហត្ថលេខាលើអនុសារណៈស្តីពីកិច្ចសហប្រតិបត្តិការ ប្រឆាំងនឹងការជួញដូរមនុស្សក្នុងតំបន់ដែលរួមបញ្ចូលទាំងការប្តេជ្ញាបង្កើតផែនការសកម្មភាពដ៏ច្បាស់លាស់សំរាប់ប្រទេស ។ អង្គការក្រៅរដ្ឋាភិបាលមួយបានរាយការណ៍ថា គេបានឃាត់ខ្លួនមនុស្ស ១៥០នាក់ ដែលទាក់ទងនឹងសកម្មភាពជួញដូរមនុស្ស ហើយបានជួញរំដោះជនរងគ្រោះចំនួន ៦៧២នាក់ ក្នុងនេះមានចំនួន ១/៥ ជាក្មេងស្រី ។

ក្នុងច្បាប់ជួញដូរមនុស្សសព្វថ្ងៃនេះ មិនមានបទបញ្ញត្តិណាមួយដែលអាចការពារជនរង គ្រោះអោយផុតពីការ

ចោទប្រកាន់ ក្រោមច្បាប់អន្តោប្រវេសន៍របស់កម្ពុជាឡើយ។ ការអនុវត្តន៍ច្បាប់ជួញដូរមនុស្ស និងការកាត់ទោសជនល្មើសនៅតែមិនទាន់បានត្រឹមត្រូវទាំងអស់នៅឡើយទេ ក៏ប៉ុន្តែមានការ រីកចំរើនខ្លះនៅក្នុងអត្រាចោទប្រកាន់និងដាក់ទោសដល់ជនល្មើស។ ក្រសួងមហាផ្ទៃបាន អោយដឹងថា ប៉ូលីសបានស៊ើបអង្កេតសំណុំរឿងជួញដូរមនុស្សចំនួន១០៦ករណី មានមនុស្សចំនួន១១៣ ត្រូវបានចាប់ខ្លួនក្រោមច្បាប់ជួញដូរមនុស្ស ដែលមានការទាក់ទងនឹងការជួញដូរមនុស្ស នឹងសច្ចារកម្ម ហើយរំដោះជនរងគ្រោះបាន៣៦៦នាក់។ ប៉ូលីសក្រុងភ្នំពេញបានឃាត់ខ្លួនមនុស្សចំនួន៥២នាក់ដែលការទាក់ទិននឹងការជួញដូរមនុស្ស និងរំដោះជនរងគ្រោះបាន២០២ នាក់រួមបញ្ចូលទាំងក្មេងស្រីចំនួន៤៥នាក់។ ចំណែកឯអង្គការក្រៅរដ្ឋាភិបាល វិញបានរាយការថាមានតែមនុស្សចំនួន៧នាក់ទេក្នុងចំនួន១៥០នាក់ ដែលបានឃាត់ខ្លួនដែលបានទទួល ការផ្តន្ទាទោសនោះ។ ក្នុងចំណោមជនខាងលើ ជនសង្ស័យ៧៥នាក់ ត្រូវបានដោះលែងដោយហេតុផលថាខ្វះភស្តុតាង ហើយជនដែលនៅសេសសល់ត្រូវរង់ចាំការធ្វើ សវនការ។ អង្គការក្រៅរដ្ឋាភិបានផ្តល់ការការពារផ្នែកច្បាប់ដល់ជនរងគ្រោះបានប្តឹងទៅតុលាការនូវ សំណុំ រឿងចំនួន៥០ ករណីដែលទាក់ទីននឹងការជួញដូរមនុស្ស ។ ចំពោះពាក្យបណ្តឹងទាំងនោះ តុលាការបានជំនុំជំរះ១៤ ករណី ហើយមានជនជួញដូរមនុស្ស៦ នាក់ត្រូវបានកាត់ទោសអោយជាប់គុកពី២ ទៅ២០ ឆ្នាំ។ បន្ថែមលើការជាប់ពន្ធាគារ តុលាការបានបញ្ជាអោយបង់ប្រាក់ចំនួន ៤០០ ទៅ៦០០ ដុល្លា(១៦ សែន ទៅ២៤ សែនរៀល) ជាសំណងដល់ជនរងគ្រោះថែមទៀត។ មិនមានរបាយការស្តីពីការដោះស្រាយនៅក្រៅតុលាការទេ។ នៅខែកុម្ភះជនជាតិញូហ្សេលែនមួយរូបត្រូវតុលាការកាត់ទោសអោយជាប់គុកចំនួន២០ឆ្នាំ ពីបទចោទប្រកាន់ថាបានប្រព្រឹត្តអំពើអាណាចារ្យទៅលើ កុមារ។ ក្នុងខែសីហា មានជនជាតិញូហ្សេឡែនម្នាក់ទៀតត្រូវផ្តន្ទាទោសជាប់គុក១០ ឆ្នាំពីបទចោទប្រកាន់ថាបានប្រព្រឹត្តអំពើអាណាចារ្យដើម្បីរំលោភផ្លូវភេទលើកុមារ៤នាក់ ដែលមានអាយុចន្លោះ ពី១១ ឆ្នាំទៅ១៦ ឆ្នាំ ហើយអោយបង់ប្រាក់ចំនួន ២ពាន់ដុល្លា (៨លានរៀល) ទៅអោយជនរងគ្រោះថែមទៀត។ ក្រសួងមួយចំនួនរបស់រដ្ឋាភិបាលបានធ្វើការយ៉ាងសកម្ម ក្នុងការបង្រ្កាបការជួញដូរមនុស្ស។ នៅឆ្នាំ ២០០០ រដ្ឋាភិបាលបានអនុម័តគំរោងផែនការជាតិ៥ឆ្នាំប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារដោយផ្តោតទៅលើការទប់ស្កាត់តាមរយៈការផ្សព្វផ្សាយពតិមាន និងការការពារ និងការអនុវត្តន៍ច្បាប់។ រដ្ឋាភិបាលបានបង្កើតយន្តការសំរាប់ត្រួតពិនិត្យ និងរាយការណ៍អំពីគំរោងនោះ និងបាន បង្កើត នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស របស់ក្រសួងមហាផ្ទៃបានពង្រាយមន្ត្រីជំនាញនៅតាមខេត្តចំនួន៧ និងដាក់អង្គភាពប្រឆាំងការជួញដូរនេះ

នៅតាមខេត្តចំនួន១៧ ផ្សេងទៀត។

ក្រសួងសង្គមកិច្ច ការងារ និងស្តារយុវនីតិសម្បទា រួមជាមួយ នឹងជំនាញការបច្ចេកទេសរបស់អង្គការអន្តោប្រវេសន៍អន្តរជាតិ (IOM) បានបញ្ជូនជនរងគ្រោះដែលត្រូវបាន គេជួញដូរពីប្រទេសថៃមកកម្ពុជា និងពីកម្ពុជាទៅវៀតណាមវិញជាប្រចាំ។ ក៏ប៉ុន្តែការបញ្ជូនចេញពីកម្ពុជា ទៅវៀតណាមត្រូវជួបនឹងការលំបាកច្រើននិងប្រើរយះពេលយូរថែមទៀត។ លើសពីនេះ ក្រសួងបានសហការជាមួយ UNICEF និងអង្គការក្នុងស្រុកដទៃទៀតដើម្បីគ្រប់គ្រងបណ្តាញតាមសហគម៍ដែលមាន គោលដៅទប់ស្កាត់ការជួញដូរនៅដំណាក់កាលដំបូង។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនបានបន្តយុទ្ធនាការ អប់រំសាធារណៈប្រឆាំងនឹងការជួញដូរដោយផ្តោតលើបណ្តាខេត្តនៅតាមព្រំដែន។ នៅខែមិថុនា រដ្ឋាភិបាលបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់មួយជាមួយ ប្រទេសថៃដើម្បីធ្វើការស៊ើបអង្កេតរួម លើការជួញដូរឆ្លងដែន។

ភាគច្រើននៃជនរងគ្រោះជាកុមារនិងមនុស្សពេញវ័យត្រូវបានគេបោកប្រាស់អោយទៅបំរើសេវាកម្មផ្លូវភេទ។ ការប៉ាន់ស្មានលើចំនួនអ្នក រងគ្រោះនៃការជួញដូរនៅក្នុងឧស្សាហកម្មផ្លូវភេទមាន ចាប់ពី ២០០០នាក់ ទៅជាង៣០០០នាក់ ប្រហែលជា ៨០ភាគរយនៃអ្នកទាំងនោះគឺជាស្ត្រី និងក្មេងស្រីវៀតណាម។ ស្ត្រី និងក្មេងស្រីវៀតណាមខ្លះត្រូវបានគេជួញ ដូរឆ្លងកាត់ប្រទេសកម្ពុជាដើម្បីយកទៅកេងប្រវ័ញ្ចនៅក្នុងអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសដទៃទៀតក្នុងទ្វីប អាស៊ី។

ការសិក្សាមួយបានប៉ាន់ប្រមាណថា មានមនុស្ស៨៨០០០នាក់ធ្វើការនៅក្នុងប្រទេស ថៃជាកម្មករ ដែលជាប់បំណុលក្នុងរយះពេលមួយ មនុស្សជាច្រើនត្រូវបានគេកេងប្រវ័ញ្ចនៅ ក្នុង ឧស្សាហកម្មផ្លូវភេទ រឺក៏ត្រូវបានគេជួលអោយធ្វើជាអ្នកសុំទាន ជាពិសេសក្មេងៗ។ ដូចគ្នានេះដែរ ក្មេងមួយចំនួនទៀតត្រូវបាន គេជួញដូរទៅវៀតណាមអោយធ្វើជាអ្នកសុំទាន។

ជនរងគ្រោះដោយសារការជួញដូរ ជាពិសេសអ្នកដែលត្រូវគេជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ត្រូវប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ រួមបញ្ចូលទាំងជំងឺអេដស៍ផងដែរ។ ក្នុងករណីមួយចំនួន ជនរងគ្រោះត្រូវគេបង្ខាំងទុក និងធ្វើបាបលើរាងកាយ និងផ្លូវចិត្តពីអ្នកជួញដូរ មេបន និងភ្ញៀវ។

អ្នកជួញដូរប្រើវិធីសាស្ត្រផ្សេងៗជាច្រើនដើម្បីបោកបញ្ឆោតជនរងគ្រោះ។ ក្នុងករណីជាច្រើន ជនរងគ្រោះត្រូវបានគេល្បួងដោយសន្យាថារកការងារត្រឹមត្រូវអោយធ្វើ។ ក្នុងករណីផ្សេងទៀត អ្នកស្គាល់គ្នា មិត្តភ័ក្រ្ត និងសមាជិកគ្រួសារបានលក់ជនរងគ្រោះដោយត្រង់ៗ រឺបានទទួលប្រាក់សំរាប់ការដែលគេជួយបោកប្រាស់ជនរងគ្រោះ។ ក្មេងតូចៗ ភាគច្រើនជាក្មេងស្រី ជារឿយៗត្រូវបានឪពុកម្តាយដែលមានជីវភាព

ទីទ័លបំផុតប្រើជារបស់បញ្ចាំដើម្បីខ្ចីលុយ ។ ក្មេងទាំងនោះភាគច្រើនត្រូវគេចាប់អោយទទួលខុសត្រូវក្នុងការសងបំណុលនិងប្រាក់ការដែលចេះតែកើនឡើងជាលំដាប់ ។

អ្នកជួញដូរក្នុងស្រុកដែលបានស្គាល់ទីតាំងភូមិសាស្ត្រ តូចៗច្បាស់លាស់បានដើរតួជាអាជ្ញាកណ្តាល សំរាបប្រព័ន្ធជួញដូរធំ ។ ក្រុមឧក្រិដ្ឋកម្មឆ្លងដែន ដែលអាចមានរូបភាពជាភ្នាក់ងាររកការងារធ្វើ រឺ អ្នកគួកជេរអោយរៀបការ ត្រូវបានគេជឿថាមានការពាក់ព័ន្ធក្នុងករិតណាមួយក្នុងរឿងនេះ ។

ជាទូទៅគេជឿថា មន្ត្រីអនុវត្តច្បាប់និងមន្ត្រីរាជការខ្លះទៀតទទួលសំនូកដែលជួយសំរួលដល់អាជីវកម្មផ្លូវភេទ និងការជួញដូរមនុស្ស ។ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលនិងសមាជិកគ្រួសាររបស់គេមួយចំនួនត្រូវបានគេរាយការណ៍ថា បានដំណើរការរកស៊ី មានភាគហ៊ុន រឺក៏ទទួលប្រាក់ថ្លៃការពារផ្ទះបនដែលដាក់ជនរងគ្រោះដោយការជួញដូរ ដែលរួមបញ្ចូលទាំងអ្នករកស៊ីផ្លូវភេទដែលមិនទាន់គ្រប់អាយុផងដែរ ។ គេមិនដែលបានឃើញថា មានការ កាត់ទោសមន្ត្រីពុករលួយដែលជាប់សង្ស័យក្នុងការជួញដូរមនុស្ស ណាមួយឡើយ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាបានបញ្ជូនជនរងគ្រោះដោយ ការជួញដូរទៅអង្គការក្រៅរដ្ឋាភិបាល ។ ជំនួយភាគច្រើនសំរាប់ជនរងគ្រោះទាំងនោះត្រូវបានផ្តល់តាមរយៈ គំរោងដែលចាត់ចែង ដោយអង្គការក្រៅរដ្ឋាភិបាលនិងអង្គការអន្តរជាតិ ។ រដ្ឋាភិបាលបានចូលរួមជាដៃគូក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះមួយចំនួន ។ ទោះយ៉ាងនេះក្តី ការចូលរួមរបស់រដ្ឋាភិបាលត្រូវរាំងស្ទះដោយសារកង្វះខាតផ្នែកធនធាន ។ ជនរងគ្រោះខ្លះត្រូវបានអង្គការ និងក្រសួងមហាផ្ទៃជំរុញអោយដាក់ពាក្យបណ្តឹងប្តឹងជនល្មើស ។ ប៉ុន្តែ នៅក្នុងបរិយាកាសនិរទណ្ឌភាព ការការពារដល់ជនរងគ្រោះគឺជាបញ្ហាមួយហើយជនរងគ្រោះតែងតែត្រូវគេគំរាមអោយបោះបង់ចោលការប្តឹងរបស់ពួកគេ ។

ក្នុងកំឡុងឆ្នាំនេះ មូលនិធិអាស៊ី អង្គការនានានិងក្រសួងកិច្ចការនារីបានរួមគ្នាធ្វើមាតុភូមិនិវត្តន៍ នូវជនរងគ្រោះពីការជួញដូរមនុស្សចំនួន៩នាក់ពីម៉ាឡេស៊ីមកកម្ពុជាវិញ ។

ក្រសួងមហាផ្ទៃបានធ្វើការស៊ើបអង្កេតលើការជួញដូរស្ត្រី នឹងក្មេងស្រីដែលគេនាំទៅប្រទេសម៉ាឡេស៊ី ។

រដ្ឋាភិបាលបានបង្កើតអង្គភាពជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជននៅតាមបណ្តាខេត្តមួយចំនួន ដែលបានបង្ក្រាបផ្ទះបនមួយចំនួន ។ ពីខែមករាដល់ខែវិច្ឆិកា អង្គភាពជំនាញប្រចាំភ្នំពេញបានផ្តួចផ្តើមការស៊ើបអង្កេតចំនួន៤១៥ លើសកម្មភាពទាំងឡាយរួមមានការរួម ភេទជាមួយកុមារ ការជួញដូរ ការរំលោភ អំពើអានាចារ និងការថតរូបភាពអាសអាភាស ។ ការស៊ើបអង្កេតទាំងនេះបានឈានទៅដល់ការបង្ក្រាបចំនួន២៥លើជនល្មើសជួញដូរមនុស្សដែលជាប់សង្ស័យ ហើយជនសង្ស័យ

៣៣នាក់ត្រូវបានប្រគល់ជូនតុលាការក្រុងភ្នំពេញ។ ការបង្ក្រាបរបស់ក្រុមជំនាញពិសេសនៅភ្នំពេញនេះ ក៏បាននាំទៅដល់ការរំដោះជនរងគ្រោះនៃការជួញដូរមនុស្សចំនួន៦៨នាក់ផងដែរ ក្នុងនោះមាន៣៦នាក់អាយុក្រោម ១៨ឆ្នាំ។ អង្គភាពប៉ូលីសដទៃទៀតក៏បានធ្វើការបង្ក្រាបផ្ទះបននិងរំដោះស្រីពេស្យាមួយចំនួនធំដែរ រួមទាំងអ្នកមិនទាន់គ្រប់អាយុផង។ រដ្ឋាភិបាលបានផ្តល់ការការពារដល់ជនរងគ្រោះដែលត្រូវបានរំដោះទាំងនោះ ក្នុងខណៈពេលដែលកំពុងធ្វើការជាមួយអង្គការនា១ដើម្បីបញ្ជូនជនរងគ្រោះទាំងនោះអោយទៅជួបជុំគ្រួសារវិញ រឺក៏បញ្ជូនពួក គេទៅទីជំរករបស់អង្គការរឺសមាគមមនុស្សធមិឯកជនដទៃទៀត។ ជាផលវិបាកជនរងគ្រោះដោយអំពើជួញ ដូរនេះ ជាពិសេសអ្នកដែលត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទរងនូវការមើលងាយមើលថោក ជាពិសេស នៅភូមិកំនើតរបស់គេ និងគ្រួសាររបស់គេផ្ទាល់តែម្តង។ គ្មានរបាយការណាមួយក្នុងឆ្នាំ២០០៤នេះដែលនិយាយអំពីការចាត់ទុកជនរងគ្រោះពីការជួញដូរមនុស្សថាជាជនអន្តោរប្រវេសន៏ខុសច្បាប់ឡើយ។

ទោះបីជារដ្ឋាភិបាលបានការពារអ្នកដែលបានសារភាពថាគេជាជនរងគ្រោះនៃការជួញដូរក៏ដោយ ក៏នៅតែមានករណើខ្លះនៅឆ្នាំ២០០២ ដែលជនរងគ្រោះដែលអះអាងថាគេមានអាយុ១៨ឆ្នាំ ហើយបានធ្វើជាពេស្យាចារដោយស្ម័គ្រចិត្ត ត្រូវគេចាត់ទុកថាជាជនបរទេសដែលអាចនិរទេសខ្លួនអោយត្រលប់ទៅស្រុកគេវិញ។ ក៏ប៉ុន្តែការបញ្ជូនចេញជនអន្តោប្រវេសន៏ខុសច្បាប់ចេញ ពីកម្ពុជាទៅវៀតណាមត្រូវជួបនឹងការលំបាកច្រើននិងប្រើរយះពេលយូរថែមទៀត។ ក្នុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលរួមជាមួយអង្គការពលកម្មអន្តរជាតិ អង្គការអន្តោប្រវេស្ទន៏អន្ទរជាតិ អង្គការអ៊ុយនីសេហ្វ និងអង្គការជាច្រើនទៀតបានជួយឧបត្ថម្ភដល់វេទិការជាតិស្តីការប្រយុទ្ធប្រឆាំងនឹងអំពើ រត់ពន្ធមនុស្ស។ ប្រតិភូកុមារបួនរូបដែលជ្រើសរើសជាតំណាងអោយជនរងគ្រោះបានថ្លែងរៀបរាប់អំពីការ ជួញដូរក្នុងវេទិការ។

រដ្ឋាភិបាលបានប្រើបដាផ្សព្វផ្សាយ យុទ្ធនាការផ្សព្វផ្សាយតាមទូរទស្សន៏និងវិទ្យុ និងល្ខោនប្រពៃណីតាមមូលដ្ឋាន ដើម្បីលើកកំពស់ការយល់ដឹងសាធារណៈអំពីការជួញដូរមនុស្ស។ នៅឆ្នាំ២០០១ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន បានបើកយុទ្ធនាការឃោសនាពតិមានដ៏ធំមួយ។ IOM បានសហការជាមួយនឹងក្រសួងពេញមួយឆ្នាំដើម្បីពង្រីកវិសាលភាពគំរោងនេះទៅគ្រប់ខេត្តទាំងអស់។

**ជនមានពិការភាព**

រដ្ឋាភិបាលមិនតំរូវថា រាល់អាគារ ឬក៏សេវាកម្មផ្សេងៗរបស់រដ្ឋាភិបាលត្រូវផ្តល់លក្ខណៈងាយស្រួលដល់ជនពិការឡើយ។ រដ្ឋាភិបាលថែមទាំងហាមឃាត់អ្នកដែលមានពិការភាពសូម្បីតែតិចតួចប៉ុណ្ណោះ មិនអោយធ្វើជាគ្រូបង្រៀននៅសាលារដ្ឋឡើយ។ នៅឆ្នាំ១៩៩៩ មានរបាយការណ៏ថាមានជនពិការចំនួន ១៧០០០០នាក់ រួមមាន២៤០០០នាក់បាត់បង់យ៉ាងហោចណាស់អវៈយវៈមួយ និង៦៧៤៤នាក់បាត់អវៈយវៈលើសពី១។ ពិការភាពដោយសារគ្រាប់មីនមានចំនួន១១.៥ភាគរយនៃប្រជាជនទាំងអស់ដែលមានពិការភាព រីឯពិការភាពពីកំនើត រឺដោយជំងឺមាន៥៣ភាគរយ។ ក្នុងឆ្នាំនេះ មានអ្នករងគ្រោះដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះចំនួន ប្រមាណ៨០០នាក់។ កម្មវិធីដែលគ្រប់គ្រងដោយអង្គការ ក្រៅរដ្ឋាភិបាលផ្សេងៗបាននាំ មកនូវការរីកចំរើនគួរអោយកត់សំគាល់ក្នុងការព្យាបាល និងស្តារនិតិសម្បទាររបស់អ្នកដែលបានបាត់បង់អវៈយវៈ។ ប៉ុន្តែបណ្តាអ្នកដែលបានបាត់បង់អវៈយវៈ ត្រូវប្រឈមនឹងការរើសអើងក្នុងសង្គមគួរអោយកត់សំគាល់ផងដែរ ជាពិសេស ក្នុងការស្វែងរកការងារជំនាញណាមួយ។

**ជនជាតិភាគតិច**

ប្រជាពលរដ្ឋដែលមានដើមកំនើតជាជនជាតិវៀតណាមនិងជនជាតិចិនមានចំនួនច្រើនជាងគេបំផុត ។ ប្រជាពលរដ្ឋដែលជាអណិកជនចិនត្រូវ បានគេទទួលស្គាល់ដោយគ្មានការរើសអើងនៅក្នុងសង្គម។ ក៏ប៉ុន្តែ ការចងគំនុំចំពោះអណិកជនវៀតណាម ដែលត្រូវបានគេមើលឃើញថាជាការគំរាមគំហែង ចំពោះប្រទេសជាតិ និងវប្បធម៌កម្ពុជានៅតែបន្តមាន។ សិទ្ធិជនជាតិភាគតិចដែលចែងក្នុងច្បាប់សញ្ជាតិឆ្នាំ១៩៩៦ មានភាពមិនច្បាស់លាស់ទេ។ ការការពារដោយ រដ្ឋធម្មនុញ្ញមានចំពោះតែ "ប្រជាជនខ្មែរ" ប៉ុណ្ណោះ។ នៅមុនការបោះឆ្នោតសភាជាតិខែកក្កដា ឆ្នាំ២០០៣ គណបក្សសមរង្ស៊ីហ្វ៊ុនស៊ីនប៊ិច និង គណបក្សនយោបាយតូចៗមួយចំនួនទៀតបានកេងចំណេញលើទឹកចិត្ត ប្រឆាំងវៀតណាមនេះ។ គណបក្សនយោបាយមានបំណងធ្វើអោយអណិកជនវៀតណាមភាគតិចរាប់ពាន់នាក់ បាត់បង់សិទ្ធិបោះឆ្នោត ដោយតវ៉ាចំពោះសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់ពួកគេ ហើយយ៉ាងហោចណាស់ក៏មានមណ្ឌលបោះឆ្នោតមួយកន្លែងដែរ ដែលមនុស្សមួយក្រុមបានរាំងជនជាតិវៀតណាម មិនអោយចូលទៅបោះឆ្នោត។ បន្ថែមពីនេះទៅទៀត ក្រុមនិស្សិតនៅតែបន្តធ្វើសេចក្តីថ្លែងការណ៏ខ្លាំងៗប្រឆាំងនឹងជនជាតិ វៀតណាមពួកគេតវ៉ាពីការត្រួតត្រាផ្នែកនយោបាយនៃគណបក្សប្រជាជនដោយរដ្ឋាភិបាលវៀតណាម ការឈ្លានពានយកទឹកដីនិងបញ្ហាដទៃទៀតដោយគេចាត់ទុកអាណិកជនវៀតណាម ដែលនៅក្នុងស្រុកថាជាអ្នករួមចំនែកទទួលខុសត្រូវ យ៉ាងហោចណាស់ក៏មួយផ្នែកដែរក្នុងរឿងទាំងនេះ។ ភាពតានតឹងរវាងជនជាតិមានសភាពកាន់តែកើនខ្លាំងឡើង

នៅក្រោយការបោះឆ្នោត ឆ្នាំ២០០៣ដែលនាំអោយមានការដុត ផ្ទះរបស់ជនជាតិវៀតណាម និងទំនាក់ទំនងតឹងតែងនៅតំបន់មួយចំនួននៅក្នុងខេត្តកណ្ដាល ។

**ការរំលោភបំពាន និង ការរើសអើងដទៃទៀត**

ការរើសអើងសង្គមចំពោះអ្នកដែលបានឆ្លង មេរោគហ៊ីវ អេដស៍ នៅតែជាបញ្ហាសំរាប់តំបន់ជនបទ ។ ក៏ប៉ុន្តែ ការរើសអើងត្រូវបានកាត់បន្ថយដោយកម្មវិធីស្វែងយល់អំពីរោគហ៊ីវ អេដស៍ ។ ពុំមានការរើងអើងជាផ្លូវការចំពោះបណ្ដាអ្នកដែលបានឆ្លងមេរោគហ៊ីវ អេដស៍ឡើយ ។

## ផ្នែកទី ៦: សិទ្ធិកម្មករ

### ក. សិទ្ធិក្នុងការបង្កើតសមាគម

ច្បាប់ស្ដីពីការងារផ្ដល់ជូនកម្មករនិយោជិតនូវសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈ តាមការជ្រើសរើសរបស់ពួកគេ ដោយមិនចាំបាច់មានការអនុញ្ញាតិជាមុន ហើយកម្មករនិយោជិតទាំងអស់មានសេរីភាពក្នុងការចូលរួមសហជីពទៅតាមជំរើសរបស់ពួកគេ ។ ក៏ប៉ុន្តែរដ្ឋាភិបាលមិនបានអនុវត្តសិទ្ធិទាំងនេះជាទូទៅទេ ហើយថ្នាក់ដឹកនាំសហជីពពីររូបត្រូវបានគេសំលាប់នៅក្នុងឆ្នាំនេះ (សូមមើលផ្នែក ១ ក )។ សមាជិកភាពនៅក្នុងសហជីពឬក៏សមាគមនិយោជិតពុំមានលកណៈបង្ខិតបង្ខំទេ ហើយកម្មករអាចមានសេរីភាពក្នុងការដកខ្លួនចេញពីអង្គការឺសមាគមទាំងនេះបាន ។ ក៏ប៉ុន្តែ ក្រសួង ការងារ និងបណ្តុះបណ្ដាលវិជ្ជាជីវៈ បានទទួលយកនូវលក្ខន្តិកៈមួយរបស់សហជីពយ៉ាងហោចណាស់ ដែលតម្រូវអោយកម្មករ និយោជិតសុំការអនុញ្ញាត មុននឹងគេអាចដកខ្លួនបាន ។

ច្បាប់ស្ដីពីការងារមិនអនុវត្តទៅលើមន្ត្រីរាជការ រួមទាំងគ្រូបង្រៀន ចៅក្រម និងបុគ្គលិកយោធា ឺអ្នកបំរើក្នុងផ្ទះទេ ។ បុគ្គលិកនៅក្នុងឧស្សាហាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងនាវាសមុទ្រមិនស្ថិតនៅក្រោមច្បាប់ស្ដីពីការងារទាំងស្រុងទេ ប៉ុន្តែក៏មានសេរីភាពក្នុងការបង្កើតសហជីពដែរ ។

កម្មករនិយោជិតភាគច្រើនគឺជាកសិករដែលមានជីវភាពគ្រាន់តែសំរាប់ចញ្ចឹមជីវិត ហើយទោះជាមានវិស័យសេវាកម្មមួយកំពុងរីកដុះដាលក៏ដោយ ក៏កម្មករនិយោជិតនៅទីក្រុងភាគច្រើនចូលរួមក្នុងពាណិជ្ជកម្មខ្នាតតូច ជាអ្នកមានជំនាញរកស៊ីដោយខ្លួនឯង ឺជាអ្នកធ្វើការពេលថ្ងៃដែលគ្មានជំនាញប៉ុណ្ណោះ ។ សហជីពទាំងឡាយទទួលរងផងដែរនូវការខ្វះខាតផ្នែកធនធាន ការបណ្ដុះបណ្ដាល និងបទពិសោធន៍ ។ មានតែផ្នែកដ៏

តូចមួយ (ប៉ាន់ប្រមាណតិចជាងមួយភាគរយ) នៃកំលាំងពលកម្មប៉ុណ្ណោះ ដែលបានចូលជាសមាជិកសហជីព ហើយចលនាសហជីពកំពុងស្ថិតនៅក្នុងសភាពចាប់កកើតនៅឡើយ ហើយនៅមានភាពទន់ខ្សោយណាស់។ សហជីពទទួលរងកង្វះធនធាន ការបណ្តុះបណ្តាល និងបទពិសោធន៍ សហជីពបានប្រមូលផ្តុំនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងស្បែកជើងដែលមានចំនួនប្រហែលពី ៥០ទៅ៦០ភាគរយ នៃចំនួនកម្មករនិយោជិតជាង ២៥០០០០នាក់ ដែលបានចូលជាសមាជិកសហជីព។ សហព័ន្ធសហជីពកម្មករវិស័យទេសចរណ៏ និងសេវាកម្មកម្ពុជា ដែលបានបង្កើតឡើងកាលពីឆ្នាំ២០០៣ តំណាងអោយនិយោជិតជាង ៣៥០០នាក់ មកពីផ្នែកព្រលាន យន្តហោះ កាស៊ីណូ និងសណ្ឋាគារ។ មានសហជីពមួយខាងផ្នែកសាធារណៈដែលកំពុងដំណើរការនៅក្នុង ប្រទេស គឺសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ដែលត្រូវបានចុះបញ្ជីជាសមាគម និងតំណាងអោយសមាជិក៥៣០០នាក់។ អាជ្ញាធរខេត្ត និងអាជ្ញាធរ មូលដ្ឋានដែលធ្វើតាមបទបញ្ជារបស់រដ្ឋាភិបាល បានហាមឃាត់បណ្តាសកម្មភាពស្ទើរតែទាំងអស់របស់សមា គមគ្រូបង្រៀនកម្ពុជាឯករាជ្យ។

ច្បាប់ស្តីពីការងារតម្រូវអោយសហជីពទាំងឡាយ និងអង្គការនិយោជិករៀបចំនិងដាក់ជូននូវលក្ខន្តិកៈ និងបញ្ជីឈ្មោះថ្នាក់ដឹកនាំស្នើសុំចុះបញ្ជីជាមួយក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។ ចាប់តាំងពីច្បាប់ស្តីពីការងារបានចូលជាធរមានកាលពីឆ្នាំ១៩៩៧មក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជីសហជីពរោងចក្រចំនួន៦៧៥ និងសហព័ន្ធ សហជីពថ្នាក់ជាតិចំនួន១៨ និង សហភាពមួយ (សម្ព័ន្ធភាពនៃសហព័ន្ធសហជីពដែលមានគំនិតដូចគ្នាមួយចំនួន) រួមបញ្ចូលទាំងសហជីពចំនួន១៧៥ សហព័ន្ធសហជីពចំនួន៥ និងសហភាព១ នៅក្នុងអំឡុងឆ្នាំ នេះ។ នៅក្នុងឆ្នាំនេះ គេពុំឃើញមានពាក្យបណ្តឹងដែលថារដ្ឋាភិបាលខកខានពុំបានចុះបញ្ជីសហជីព ឬសហព័ន្ធសហជីពឡើយ។ ក៏ប៉ុន្តែ សហជីពមួយចំនួនបានត្អូញត្អែពីភាពយឺតយ៉ាវនិងការបង់ថ្លៃឈ្នួលដោយមិនចាំបាច់។ ទោះបីជាគ្រប់សហជីពទាំងអស់ ប្រមូលប្រាក់វិភាគទានពីសមាជិករបស់ពួកគេក៏ដោយ ក៏ពុំមានសហជីពណាមួយអាចដំណើរការបានដោយគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រភពខាងក្រៅទេ។

សហព័ន្ធសហជីពសំខាន់ពីរ និងសហជីពរោងចក្រមួយចំនួនដែលពុំមានការពាក់ព័ន្ធ មានលក្ខណៈឯករាជ្យ។ សហព័ន្ធសហជីពចំនួន១១ ដែលត្រូវបានចុះបញ្ជី មានទំនាក់ទំនងតាំងពីដើមមកជាមួយរដ្ឋាភិបាល រឺជាមួយបុគ្គលដែលមានការពាក់ព័ន្ធជាមួយគណបក្សប្រជាជននៅក្នុងរដ្ឋាភិបាល។ មានភស្តុតាងដែលជាក់លាក់មួយចំនួនអំពីការជាប់ពាក់ព័ន្ធរបស់និយោជកទៅក្នុងសហជីពមួយចំនួន។ នៅតាមរោងចក្រមួយចំនួនអ្នក គ្រប់គ្រងរោងចក្របាក់ដូចជាបានបង្កើតសហជីពផ្ទាល់របស់ពួកគេ និងបានគាំទ្រសហជីពដែល លំអៀង

ទៅ ខាងអ្នកគ្រប់គ្រង ឬក៏បានទិញទឹកចិត្តបណ្តា ថ្នាក់ដឹកនាំសហជីព ដទៃទៀតផង។ ថ្នាក់ដឹកនាំសហជីពឯករាជ្យបានត្អូញត្អែថាសហភាពសហព័ន្ធសហជីពជាតិកម្ពុជា ដែលជាសហភាពមួយទើបបានបង្កើតឡើង និងរួមមានសហព័ន្ធ១១ ដែលលំអៀងទៅខាងរដ្ឋាភិបាល និងលំអៀងទៅខាងនិយោជក បានធ្វើអន្តរាគមន៏ជារឿយៗចូលក្នុងកិច្ចការ របស់សហជីពដទៃទៀត និង បានជំរិតទារប្រាក់ពីនិយោជកជាថ្នូរទៅនឹងការបំបាក់ទឹកចិត្តកម្មករនិយោជិតមិនអោយធ្វើកូដកម្ម និងបាតុកម្មស្របច្បាប់។ សកម្មជនសហជីពមួយចំនួនបានចោទប្រកាន់ថា តំណាងសហភាពសហព័ន្ធសហជីពជាតិកម្ពុជា បានគំរាមកំហែងថ្នាក់ដឹកនាំសហជីពប្រកួតប្រជែង និងនិយោជក។ សហភាពសហព័ន្ធសហជីពជាតិកម្ពុជា បានជំនួសអង្គការសាមគ្គីដើម្បីពលករកម្ពុជាយ៉ាងប្រសិទ្ធភាព ដែលជាអង្គការក្រៅរដ្ឋាភិបាលជាប់ពាក់ព័ន្ធនឹងរដ្ឋាភិបាលដែលបានប្រកាសថា នឹងការពារកម្មករ និយោជិត និងសេដ្ឋកិច្ចជាតិពីសកម្មជនសហជីព និងកូដកម្មទាំង ឡាយដែលមានលក្ខណៈរំខានបង្កបញ្ហា បានគំរាមកំហែង និង បានប្រើអំពើហឹង្សាទៅលើសកម្មជនសហជីព និង កម្មករនិយោជិតដទៃទៀតផង។ សកម្មជនសហជីពគឺជាចំណុចគោលដៅនៃអំពើហឹង្សាជាញឹកញាប់។ នៅថ្ងៃទី២២ខែមករា លោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេសំលាប់នៅតាមផ្លូវដ៏អូរអរមួយ នៅរាជធានីភ្នំពេញ (មើលផ្នែក១ក) នៅថ្ងៃទី ៧ខែឧសភា លោក រស់ សុវណ្ណារ៉េត ជាប្រធានសហជីព ប្រចាំរោងចក្រកាត់ដេរទ្រីនុងហ្គាលកុមារា និងជាសមាជិកប្រតិបត្តិនៃសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេសំលាប់ (សូមមើលផ្នែក ១ក)។ លើសពីនេះទៅទៀត សហព័ន្ធសហជីពសេរីអន្តរជាតិ បាន រាយការណ៏ ថាកាលពីថ្ងៃទី២៣ខែមិថុនា កញ្ញា ឡាយ សុភាព ប្រធានសហជីពដែលមានចំណងទាក់ទងជាមួយសហជីពសេរីកម្មករនៃព្រះរាជាណា ចក្រកម្ពុជា ត្រូវបានគេវាយធ្វើបាប ហើយបានទុកនាងចោលអោយដេកស្លាប់។ កញ្ញា ឡាយ សុភាព បានជាសះស្បើយឡើងវិញ ហើយបានដាក់ពាក្យរកការធ្វើនៅរោងចក្រមួយទៀត ក៏ប៉ុន្តែពាក្យសុំរបស់នាងត្រូវបានគេបដិសេធន៏ចោលដោយអំពើជាក់ស្តែងនៃការរើសអើងប្រឆាំងសហជីព។ ក្រោយពីមរណភាពរបស់លោក ជា វិជ្ជា ថ្នាក់ដឹកនាំសហជីពមួយចំនួនបានរាយការណ៏ថាបានទទួល ការគំរាមកំហែង រួមទាំង លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និង លោក ស៊ុំ សំនៀង អគ្គលេខានៃសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានរត់គេចចេញពីប្រទេស។ លើសពីនេះទៅទៀត ភរិយាលោក ជា វិជ្ជា បានចាកចេញពីប្រទេសហើយត្រូវបានគេផ្តល់អោយសិទ្ធិជ្រកកោណនៅប្រទេសទីបី។ ក្នុងអំឡុងពេលមានភាពទាល់ច្រកផ្នែកនយោបាយក្រោយពេលបោះឆ្នោតជាតិ

ការអនុវត្តន៍នូវបទបញ្ញត្តិច្បាប់របស់រដ្ឋាភិបាលសំដៅការពារសិទ្ធិបង្កើតសមាគម និងសេរីភាពពីការរើសអើងទៅលើសហជីពនៅមានភាពទន់ខ្សោយ ហើយនិងសកម្មភាពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្រុតធ្លាក់ចុះយ៉ាងខ្លាំង។ បន្ថែមពីនេះទៅទៀត កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៍ច្បាប់ត្រូវបានធ្វើអោយរាំងស្ទះ ដោយសារកង្វះ ឆន្ទៈនយោបាយ និងដោយសារហិរញ្ញវត្ថុដែលមានភាពច្របូកច្របល់ និងទំនាក់ទំនងនយោបាយ ជាមួយនិយោជក ព្រមទាំងថ្នាក់ដឹកនាំសហជីព។ រដ្ឋាភិបាលក៏មានការខ្វះខាតនូវធនធាន រួមបញ្ចូលទាំងអធិការការ ងារដែលមានបទពិសោធន៍ និងទទួលបានការបណ្តុះបណ្តាល និងមួយផ្នែកទៀត ដោយសារតែរដ្ឋាភិបាលពុំ បានផ្តល់ប្រាក់បៀវត្សរ៍សមរម្យជូនដល់បុគ្គលិក។ ជារឿយៗ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើសេចក្តីសំរេចគាំទ្រកម្មករនិយោជិត ប៉ុន្តែកម្របានប្រើអំណាចស្របច្បាប់ របស់ខ្លួនក្នុងការដាក់ទណ្ឌកម្មចំពោះនិយោជកទាំងឡាយណាដែលមិនបានគោរពតាមបទបញ្ជារបស់ខ្លួន ណាស់។ មានរបាយការណ៍គួរអោយជឿទុកចិត្តបាន មួយចំនួនអំពីការយាយីរំខានទៅលើសហជីពដោយនិយោជក រួមទាំងការបញ្ឈប់ថ្នាក់ដឹកនាំសហជីពពីការងារ នៅបណ្តារោងចក្រកាត់ដេរជាង២៥ និងសហគ្រាស ផ្សេងទៀតនៅក្នុងឆ្នាំនេះ។ មានពេលខ្លះ ថ្នាក់ដឹកនាំសហជីពមួយចំនួនដែលត្រូវបានបញ្ឈប់ពីការងារបានសុខចិត្តទទួលយកដំណោះ ស្រាយជាទឹកប្រាក់ ក្រោយពីពុំបានទទួលជោគជ័យក្នុងការអំពាវនាវដល់រដ្ឋាភិបាល អោយអនុវត្តបទ បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ដែលតម្រូវអោយទទួលយកពួកគេចូលធ្វើការវិញ។ ក៏ប៉ុន្តែមានករណីខ្លះ ដែលរដ្ឋាភិបាលបានការពារលើកស្ទួយសិទ្ធិកម្មករដែរ។ ជាឧទាហរណ៍ រដ្ឋាភិបាលបានព្យួរបុព្វសិទ្ធិនាំចេញរបស់ រោងចក្រមួយ ដែលអ្នកគ្រប់គ្រងបាន រំលោភបំពាននិងគំរាមកំហែងថ្នាក់ដឹកនាំសហជីពមួយរូប។ លើសពីនេះទៅទៀត យោងតាមស្ថិតិរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុនចំនួន៩២ ត្រូវបានផាកពិន័យដោយហេតុថាបានរំលោភច្បាប់ស្តីពីការងាររវាងខែធ្នូឆ្នាំ២០០៣ និងខែវិច្ឆិកា។ សហជីពអាចចងសម្ព័ន្ធជាមួយគ្នា បានដោយសេរីក៏ប៉ុន្តែច្បាប់មិនបានបញ្ជាក់ អោយ បានជាក់ លាក់ អំពីសិទ្ធិរបស់ពួកគេក្នុងការចងសម្ព័ន្ធជាលក្ខណៈអន្តរជាតិទេ។

## ខ. សិទ្ធិបង្កើតសហជីព និងសិទ្ធិក្នុងការធ្វើការចរចារួម

ច្បាប់ស្តីពីការងារបានចែងអំពីសិទ្ធិបង្កើតសហជីព និងសិទ្ធិក្នុងការធ្វើការចរចារួម។ ក៏ប៉ុន្តែការអនុវត្តន៍របស់រដ្ឋាភិបាលទៅលើសិទ្ធិទាំងនេះគ្មានសង្គតភាពឡើយ។ ប្រាក់បៀវត្សន៍ត្រូវបានកំនត់ដោយ

កំលាំងទីផ្សា លើកលែងតែបៀវត្សន៏របស់មន្ត្រីរាជការដែលត្រូវកំនត់ដោយរដ្ឋាភិបាល ។

ចាប់តាំងពីការអនុម័តច្បាប់ស្តីពីការងារក្នុងឆ្នាំ១៩៩៧មក មានការច្របូកច្របល់អំពីតួនាទីជាន់គ្នារបស់សហជីព និងប្រតិភូបុគ្គលិកដែលត្រូវបានបោះឆ្នោតជ្រើសរើស ។ ច្បាប់ការងារបានផ្តល់សិទ្ធិដល់សហជីពដើម្បីចរចារជាមួយក្រុមអ្នកគ្រប់គ្រងអំពីប្រាក់ឈ្នួល និងលក្ខ័ណ្ឌការងារ ហើយអនុញ្ញាតអោយសហជីពជ្រើសតាំងបេក្ខជនសំរាប់តំណែងជាប្រតិភូបុគ្គលិក ។ ច្បាប់ផ្តល់ជូនប្រតិភូបុគ្គលិកនូវសិទ្ធិតំណាងសហជីពចំពោះមុខនាយកក្រុមហ៊ុន និងចុះហត្ថលេខាលើអនុសញ្ញារួមនៃការងារ ។ ក៏ប៉ុន្តែតាមការជាក់ស្តែង រោងចក្រស្ទើរតែទាំងអស់បានបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក មុនពេលដែលសហជីពមានវត្តមាននៅក្នុងសហគ្រាស ។ សហជីពជាច្រើនមិនមានសិទ្ធិអនុវត្តតាមច្បាប់ ក្នុងការចរចាជាមួយអ្នកគ្រប់គ្រងទេក្នុងស្ថានភាពដែលមានប្រតិភូបុគ្គលិកពុំមែនជាសហជីពត្រូវបានបោះឆ្នោតជ្រើសរើស ។ លើសពីនេះទៅទៀត ច្បាប់ការពារប្រតិភូបុគ្គលិក
យ៉ាងជាក់លាក់អោយរួចផុតពីការបញ្ឈប់ពីការងារដោយគ្មានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែពុំបានផ្តល់ការការពារដូចគ្នានេះដល់ថ្នាក់ដឹកនាំសហជីពដែលត្រូវ បានបោះឆ្នោតជ្រើសរើសឡើយ ។ នៅឆ្នាំ២០០០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសមួយដែលបានផ្តល់ដល់សហជីពនូវតួនាទីដែលអាចប្រៀបធៀបគ្នាទៅ នឹងតួនាទីរបស់ប្រតិភូបុគ្គលិកនិងបានបន្ថែមការការពារដល់ថ្នាក់ដឹកនាំសហជីពមួយចំនួនអោយរួចផុតពីការ បញ្ឈប់ពីការងារនៅក្នុងសហគ្រាស ។ ទោះបីជាយ៉ាងណាក៏ដោយ ការការពារចំពោះថ្នាក់ដឹកនាំសហជីពទាំង នេះពុំបានបង្ហាញអោយឃើញថាមានប្រសិទ្ធិភាពទេ ។

មានអនុសញ្ញារួមនៃការងារចំនួន១៨ដែលត្រូវបានចុះបញ្ជីជាមួយរដ្ឋាភិបាល ហើយអនុសញ្ញារួមទាំងនោះមិនបានបំពេញតាមបទដ្ឋានអនុសញ្ញារួមអន្តរជាតិឡើយ ។ មានអនុសញ្ញារួមពីរពិតប្រាកដជាលើកដំបូងមួយនៅក្នុងឧស្សាហកម្មកាត់ដេរ ។ អនុសញ្ញារួមនេះបានចែងពីការបន្ថែមរយៈពេលឈប់សំរាកដោយជំងឺ និងការឈប់ សំរាលកូន ហើយបានអំពាវនាវអោយបង្កើតមូលនិធិសុខមាលភាព មួយដែលគ្រប់គ្រងចាត់ចែងដោយសហជីព ព្រមទាំងតម្រូវអោយអ្នកគ្រប់គ្រងរោងចក្រធ្វើអោយ ប្រសើរឡើងនូវគិលានដ្ឋានរបស់រោងចក្រ ។ នៅឆ្នាំ២០០១ រដ្ឋាភិបាលបានចេញបទបញ្ជាបង្កើតនីតិវិធីមួយ ដើម្បីអនុញ្ញាតអោយសហជីពទាំងឡាយបង្ហាញថា ពួកគេតំណាងអោយកម្មករ និយោជិតក្នុងគោលបំណងនៃការចរចាររួម ។ បទបញ្ជានេះ ក៏បានបង្កើតផង ដែរនូវតំរូវការទាំងឡាយសំរាប់និយោជក និងសហជីពស្តីពីការចរចាររួម

និងផ្តល់ជូនថ្នាក់ដឹកនាំសហជីពនូវ ការការពារបន្ថែមពីការបញ្ឈប់ពីការងារ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីជួយសម្រួលដល់ដំណើរការនៃការចុះបញ្ជិកាសហជីព និងការដាក់ពាក្យស្នើសុំភាពជាតំណាងបំផុតរបស់សហជីព ដែលជាឋានៈមួយផ្តល់សិទ្ធិអោយសហជីពដែលជាតំណាងអោយមតិភាគច្រើនដាច់ខាត នៅក្នុងរោងចក្រណាមួយធ្វើជាតំណាងអោយកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រនោះ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់ភាពជាតំណាងដល់សហជីពចំនួន៥៦ ដែលធ្វើអោយ សហជីពទាំងនោះមានលទ្ធភាពធ្វើជាតំណាងអោយកម្មករនិយោជិតក្នុងគោលបំណងនៃការចរចារួម។ សហជីពផ្សេងៗទៀតដែលបានដាក់ពាក្យ ស្នើសុំឋានៈជាតំណាងនេះ ហើយដែលនៅមិនទាន់បានទទួលឋានៈនេះនៅ ឡើយនោះបានត្អូញត្អែរអំពីភាពយឺតយូរ ដោយសារតែការិយាល័យធិបតេយ្យនិយមដែលពុំចាំបាច់សោះ។

នៅខែមករាឆ្នាំ២០០២ អង្គការពលកម្មអន្តរជាតិបានផ្តួចផ្តើមឡើងនូវកម្មវិធីមួយដើម្បីដោះស្រាយបណ្តាវិវាទការងារ។ ចាប់តាំងពីពេលដែលកម្មវិធីនេះបានបង្កើតឡើងនៅខែឧសភាមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រីភាគីនៃកម្មវិធីនេះបានទទួលវិវាទការងាររួមរវាងកម្មករនិយោជិត និងអ្នកគ្រប់គ្រងចំនួន១៣៩ករណី។ ក្នុងចំណោមករណីទាំងអស់នេះ មាន ១២៣ករណីដែលត្រូវបានដោះស្រាយ (៨២ករណីឆ្លងតាមរយៈ សេចក្តីបង្គាប់អាជ្ញាកណ្តាល និងត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនត្រឹមត្រូវ ហើយ ៤១ករណីទៀតឆ្លងតាមរយៈ ការផ្សះផ្សារនៅក្នុងអំឡុងពេលនៃដំណើរការនៃអាជ្ញាកណ្តាល)។ ចំនួន១២ករណីដែលនៅសល់កំពុងរង់ចាំការ ដោះស្រាយនៅដំណាច់ឆ្នាំនេះ។

ច្បាប់ស្តីពីការងារចែងអំពីសិទ្ធិធ្វើកូដកម្ម និងការពារកូដករពីការសងសឹក។ នៅក្នុងអំឡុងឆ្នាំនេះ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានរាយការណ៍ថាឃើញមានកូដកម្មចំនួន៧៩ករណី ហើយកូដកម្មស្ទើរតែទាំងអស់នេះបានរំលោភលើសេចក្តីតម្រូវអោយមានការជូនដំណឹងរយៈពេលប្រាំពីរជាមុន។ ផ្ទុយទៅវិញ ថ្នាក់ដឹកនាំសហជីពបានអះអាងថាតាមពិតមានចំនួនកូដកម្មលើសប្រមាណពីរដងនៃចំនួនកូដកម្មខាងលើនេះបានកើតមានឡើង ដែលភាគច្រើននៃកូដកម្មទាំងអស់នោះ មានលក្ខណៈស្របច្បាប់។ សហជីពបានត្អូញត្អែរថាភាពខ្វះខាតយ៉ាងខ្លាំងនៃការចូលរួមទាក់ទិនរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងអំឡុងរយៈពេលមានភាពទាល់ច្រកផ្នែកនយោបាយបានឈានដល់មានការកើន ឡើងយ៉ាងច្រើននៃកូដកម្ម។

រដ្ឋាភិបាលបានអនុញ្ញាតកូដកម្មស្ទើរតែ ទាំងអស់ ហើយ ជាទូទៅ អន្តរាគមន៍របស់ប៉ូលិសមានលក្ខណៈអប្បបរមា និងមានភាពអត់ធ្មត់ សូម្បីតែក្នុងករណីខ្លះ ដែលកម្មករនិយោជិតធ្វើកូដកម្មបានធ្វើអោយមានការខូចខាតទ្រព្យសម្បត្តិទៀតផង។ ក្នុងអំឡុងពេលមានភាពទាល់ច្រកផ្នែកនយោបាយរវាងការបោះឆ្នោតខែកក្កដាឆ្នាំ២០០៣ និងការបង្កើតរដ្ឋាភិបាលថ្មី រដ្ឋាភិបាលមិនអនុញ្ញាតសំណើរសុំធ្វើបាតុកម្មស្ទើរតែទាំងអស់ដោយលើកយកការព្រួយបារម្ភផ្នែកសន្តិសុខមកធ្វើជាសំអាង។ វត្តមានរបស់ប៉ូលីសនៅពេលមានបាតុកម្មខ្លះដែលបានកើតឡើងនោះ មានលក្ខណៈច្រើនលើសលប់ ហើយតែងតែមានអង្គភាព អន្តរាគមន៍នៃប៉ូលីសជំនាញទៀតផង។ នៅខែតុលា ប៉ូលីសបានប្រើក្បាលទុយយោបាញ់ទឹកទៅលើកម្មករនិយោជិត១៧០០រូបនៅទីក្រុងព្រះសីហនុ ដែលបានធ្វើកូដកម្មដោយគ្មានការអនុញ្ញាតក្រោយពីមានការបញ្ឈប់ ពីការងាររួមយ៉ាងច្រើនសន្ធឹកសន្ធាប់នូវកម្មករនិយោជិតចំនួន៤១នាក់។ រដ្ឋាភិបាលបានអនុញ្ញាតអោយបាតុកម្មខ្លះ ប្រព្រឹត្តទៅដោយពុំមានការរំខានជាធំដុំ រួមទាំងក្បួនដង្ហែជាកិត្តិយសដល់សពលោក ជា វិជ្ជា ថ្នាក់ដឹកនាំសហជីពដែលត្រូវបានគេសំលាប់ ដោយមានការចូលរួមពីអ្នកគាំទ្ររាប់ពាន់អ្នក (សូមមើល ផ្នែក១ក)និងក្បួនដង្ហែសពដែលមានអ្នកចូលរួម២៥០ នាក់ដល់ថ្នាក់ដឹកនាំសហជីពមួយរូបទៀត ដែលត្រូវបានគេធ្វើឃាតនៅខែឧសភា (មើល ផ្នែក១ក)។

ទោះបីជាមានបទបញ្ញត្តិច្បាប់ដែលការពារកូដករពីការសងសឹកក៏ដោយ ក៏មានរបាយការណ៍ដែលគួរអោយទុកចិត្ត មួយចំនួនរាយការណ៍អំពីការដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ពីការងារ ដោយពុំមានមូលដ្ឋានត្រឹមត្រូវ បន្ទាប់ពីបានរៀបចំ រឺបានចូលរួមធ្វើកូដកម្ម។ ក្នុងករណីមួយចំនួន កូដករត្រូវទទួលរងការគាបសង្កត់ពីនិយោជកអោយទទួលយកការទូទាត់សំណង ហើយអោយចាក ចេញពីការងាររបស់ពួកគេ។ កម្មករនិយោជិតនៅសណ្ឋាគារទំនើបពីរត្រូវបានបញ្ឈប់ពីការងារក្រោយពីបានធ្វើកូដកម្មនៅខែមេសាដែលពួកគេបានអះអាងថាជាកូដកម្មស្របច្បាប់។
កម្មករនិយោជិតទាំងនោះបានចោទប្រកាន់ថាអ្នកគ្រប់គ្រងបានបិទទ្វារសណ្ឋាគារអោយពួកគេនៅខាងក្រៅនៅពេលដែលពួកគេបដិសេធន៍មិនព្រមចុះហត្ថលេខាលើសេចក្តីថ្លែងបោះបង់សិទ្ធិធ្វើកូដកម្មស្របច្បាប់របស់ពួកគេនៅពេលអនាគត។ រយៈពេលប្រាំខែក្រោយពីមានការចរចារមក អ្នកគ្រប់គ្រងនិងកម្មករនិយោជិតបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាមួយនៅខែកញ្ញា ក្នុងការទទួលយកកម្មករ និយោជិត៦០ភាគរយអោយចូលធ្វើការវិញដោយទទួលបានប្រាក់រំលឹក ហើយបានផ្តល់ប្រាក់បំណាច់បញ្ឈប់ពីការងារ

ទៅអោយកម្មករនិយោជិតដែលនៅសេសសល់។ ប្រទេសកម្ពុជាគ្មានតំបន់កែឆ្នៃសំរាប់នាំចេញនៅឡើយទេ។

### គ. ការហាមឃាត់នូវការងារដោយបង្ខំ ឬដោយដាក់អោយជាប់បំណុល

ច្បាប់ស្តីពីការងារហាមប្រាមមិនអោយមានការធ្វើការដោយបង្ខំ រឺដោយការជំពាក់បំណុលទេ រួមបញ្ចូលទាំងការបង្ខំអោយកុមារធ្វើការងារផងដែរ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលមិនបានអនុវត្តបទបញ្ញត្តិរបស់ខ្លួនអោយបានគ្រប់គ្រាន់ឡើយ។ ការធ្វើការបន្ថែមម៉ោង ដោយ ពុំស្ម័គ្រចិត្តនៅតែមានការរីកសុះសាយពាសពេញ។ កម្មករនិយោជិត បានប្រឈមមុខនឹងការពិន័យការបញ្ឈប់ពីការងារ ឬការបាត់បង់ប្រាក់រង្វាន់ ប្រសិនបើពួកគេបដិសេធមិនធ្វើ ការបន្ថែមម៉ោងទេនោះ។ របាយការណ៍មួយចំនួនក៏បានរាយការណ៏ផងដែរថា មានករណីដាច់ដោយឡែកខ្លះ ចំពោះការងារដោយបង្ខំទៅលើអ្នកបំរើក្នុងផ្ទះ។

### ឃ. ស្ថានភាពនៃការអនុវត្តន៏ពលកម្មកុមារ និងអាយុអប្បបរមាសំរាប់ធ្វើការងារ

រដ្ឋាភិបាលបានអនុម័តច្បាប់ការពារកុមារពីការកេងប្រវ័ញ្ចនៅទីកន្លែងធ្វើការងារ។

ច្បាប់ស្តីពីការងារកំណត់អាយុអប្បបរមា១៥ឆ្នាំ សំរាប់ធ្វើការងារ និងអាយុអប្បបរមា១៨ឆ្នាំសំរាប់ការងារដែលមានគ្រោះថ្នាក់។ ច្បាប់បានអនុញ្ញាតអោយ កុមារអាយុចន្លោះពី ១២ ដល់ ១៥ឆ្នាំធ្វើ "ការងារស្រាល"បាន ពោលគឺការងារដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និង មិនជះឥទ្ធិពលអាក្រក់ដល់វត្តមានរៀនសូត្ររបស់ពួកគេ។ គណៈកម្មការប្រឹក្សាការងារត្រីភាគី ជាអ្នកទទួលខុសត្រូវលើការបញ្ជាក់ថា មុខរបរណាខ្លះដែលធ្វើអោយមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព និងសីលធម៌ដល់ក្មេងជំទង់ ព្រមទាំងពិគ្រោះយោបល់ជាមួយក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីកំណត់ប្រភេទនៃការងារ និងលក្ខខ័ណ្ឌការងារណាមួយថាជា "ការងារស្រាល"។ ក្នុងចំណោមក្មេងដែលមានអាយុចន្លោះពី ៥ ទៅ ១៧ឆ្នាំមាន៥៣%នៃ ពួកគេធ្វើការ។ មួយភាគបីនៃក្មេងទាំងអស់នេះ មានអាយុច្រើនជាង១៤ ឆ្នាំ ហើយ ៧១%នៃពួកគេធ្វើការនៅវិស័យ កសិកម្ម ធ្វើស្រែចំការ ឬព្រៃឈើ។ ២១%នៃក្មេងដែលធ្វើការ គឺជាកម្មករបំរើសេវាកម្មឬលក់ដូរ ហើយ ៧%ធ្វើការងារ ផ្នែកផលិតកម្ម។

នៅក្នុងអំឡុងឆ្នាំនេះ អង្គការពលកម្មអន្តរជាតិបានរាយការណ៏ថាពលកម្មកុមារមិនកើតមាននៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ទេ។ ជាលក្ខណៈទូទៅ ពលកម្មកុមារ កម្រកើតមាន ណាស់ នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ទោះជាមានកម្មករ និយោជិតវ័យក្មេងៗ ដែលបានបង្ហាញអាយុខ្លួនខុសដើម្បីបានការងារធ្វើ។ កង្វះខាតខាងឯកសារដែលអាចទុកចិត្ត បានធ្វើអោយមានការលំបាកដល់និយោជក ក្នុងការពារ

ទប់ស្កាត់បញ្ហានេះ ហើយរោងចក្រកាត់ដេរស្ទើរតែទាំងអស មាននយោបាយដែលកំណត់ អាយុសំរាប់ធ្វើការងារលើសពីអាយុអប្បបរមា ១៥ឆ្នាំ។

បញ្ហាពលកម្មកុមារដ៏ធ្ងន់ធ្ងរបំផុត គឺមាននៅក្នុងវិស័យក្រៅផ្លូវការ ។ អ្នកសង្កេតការណ៍មួយ ចំនួនបានកត់សំគាល់ឃើញថា បទដ្ឋានច្បាប់ដែលនៅជាធរមាន ពុំបានដោះស្រាយបញ្ហាពលកម្មកុមារនៅក្នុងវិស័យក្រៅផ្លូវការអោយ បានត្រឹមត្រូវឡើយ ។ ក្រសួងការងារ និងណ្តុះបណ្តាលវិជ្ជាជីវៈបាននិងកំពុងធ្វើការជាមួយអង្គការពលកម្មអន្តជាតិ ដើម្បីកំណត់រកចន្លោះខ្វះខាតនៅ ច្បាប់ដែលនៅជាធរមាន ហាមឃាត់ពលកម្មកុមារ និងដើម្បីបង្កើតវិធានការនានាក្នុងការអនុវត្តអោយបានពេញលេញនូវអនុសញ្ញាទាំងឡាយដែលពាក់ព័ន្ធ។

ដោយមានជំនួយឧបត្ថម្ភពីអង្គការពលកម្មអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតផ្នែកពលកម្មកុមារដើម្បីអង្កេត និងប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ។

រដ្ឋាភិបាលបានបង្កើតផែនការ សកម្មភាពដែលនឹងក្លាយជាក្របខ័ណ្ឌ សំរាប់គោលនយោបាយ និងអន្តរាគមន៍ ប្រឆាំងនឹងទំរង់អាក្រក់បំផុតនៃពលកម្មកុមារ ។ រដ្ឋធម្មនុញ្ញហាមឃាត់ពលកម្មកុមារ ដោយបង្ខំ និងដោយ ជំពាក់បំណុល ។ ទោះបីជាយ៉ាងនេះក្តី ពលកម្មកុមារ ដោយការបង្ខិតបង្ខំ គឺជាបញ្ហាដ៏ធ្ងន់ធ្ង រមួយនៅក្នុង ឧស្សាហកម្មជំនួញផ្លូវភេទ (សូមមើលផ្នែក ៥)។ ទោះបីជាភ្នាក់ងារអនុវត្តច្បាប់មានសិទ្ធិអំណាចនៅក្នុងការប្រយុទ្ធប្រឆាំងនឹងពេស្យាចារកុមារ ក៏ពួកគេ ពុំបានបំពេញភារកិច្ចខ្លួនអោយបានជាប់លាប់ និងប្រកបដោយនិរន្តរភាពទេ ។ អំពើពុករលួយដែលរីក សុះសាយ កង្វះតម្លាភាព ប្រភពធនធានមិនគ្រប់គ្រាន់ និងកង្វះបុគ្គលិកនៅតែជាឧបសគ្គប្រឈម មុខដ៏ស្រួចស្រាវបំផុត។

ក្រសួងបានចូលរួមនៅក្នុងកម្មវិធីអន្តរជាតិរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីលុបបំបាត់នូវពលកម្មកុមារ ដែលផ្តល់ថវិការដោយរដ្ឋាភិបាលបរទេសមួយដើម្បីយកកុមារចេញពីការងារគ្រោះថ្នាក់នៅក្នុងឧស្សាហកម្មផលិតអំបិល នេសាទ និងចំការកៅស៊ូ ហើយដើម្បីផ្តល់អោយពួកគេនូវឱកាសទទួលការអប់រំសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅខែមិថុនា រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដើម្បីចូលរួមក្នុងគំរោងមួយដែលផ្តល់ថវិការដោយរដ្ឋាភិបាលបរទេស ហើយដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាលមួយ ក្នុងការពង្រីកឱកាសសិក្សាអប់រំសំរាប់កុមារដែលងាយរងគ្រោះបំផុតដោយពលកម្មកុមារ ជាពិសេសចំពោះក្មេងស្រីដែលងាយរងគ្រោះក្នុងការជួញដូរមនុស្ស ។

រដ្ឋធម្មនុញ្ញហាមឃាត់ពលកម្មកុមារដោយបង្ខំ និងដោយជំពាក់បំណុល។ ទោះបីជាយ៉ាងនេះក្តី ពលកម្មកុមារដោយការបង្ខិតបង្ខំ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅក្នុងឧស្សាហកម្មជំនួញផ្លូវភេទ (សូមមើលផ្នែកទី៦ ច)។ ភ្នាក់ងារអនុវត្តច្បាប់មានសិទ្ធិអំណាចនៅក្នុងការប្រយុទ្ធប្រឆាំងនឹងពេស្យាចារកុមារ ក៏ប៉ុន្តែពុំបាន

បំពេញភារកិច្ចខ្លួនអោយបានជាប់លាប់និងប្រកបដោយនិរន្តរភាពទេ។

**ង. លក្ខខ័ណ្ឌការងារដែលអាចទទួលយកបាន**

ច្បាប់ស្តីពីការងារតំរូវអោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំនត់ប្រាក់ឈ្នួលអប្បបរមាដោយ ផ្អែកលើអនុសាសន៍ពីគណៈកម្មការប្រឹក្សាការងារ។ តាមច្បាប់ ប្រាក់ឈ្នួល អប្បបរមាអាចប្រែប្រួលទៅតាមតំបន់។ នៅខែកក្កដាឆ្នាំ២០០០ គណៈកម្មការប្រឹក្សាការងារបានអនុម័តប្រាក់ឈ្នួលអប្បបរមាចំនួន ៤៥ដុល្លាអាមេរិក (១៧៥.៥០០ រៀល) ក្នុងមួយខែ ក៏ប៉ុន្តែតំលៃនេះ ត្រូវអនុវត្តចំពោះតែឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងស្បែកជើងប៉ុណ្ណោះ។ រោងចក្រកាត់ដេរសំលៀកបំពាក់និងស្បែកជើងស្ទើរតែទាំងអស់បានគោរពតាមប្រាក់ឈ្នួលអប្បបរមានេះ។ តែគេពុំឃើញមាន ប្រាក់ឈ្នួលអប្បបរមានេះត្រូវបានអនុវត្តចំពោះឧស្សាហកម្មដ៏ទៃណាមួយទៀតទេ ។

កម្មករនិយោជិតកាត់ដេរសំលៀកបំពាក់ទទួលបានប្រាក់ឈ្នួលជាមធ្យមចំនួន ៦៥ដុល្លាអាមេរិក (២៦០.០០០រៀល) ក្នុងមួយខែ រួមទាំងការធ្វើបន្ថែមម៉ោង និងប្រាក់រង្វាន់ផ្សេងៗទៀត ។ ប្រាក់ឈ្នួលប្រចាំខែជាទូទៅនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងមុខវិជ្ជាជីវៈដទៃទៀត គឺពុំគ្រប់គ្រាន់សំរាប់អោយកម្មករនិយោជិត និងក្រុមគ្រួសាររបស់គេមានកំរិតជីវភាពរស់នៅបានសមរម្យឡើយ ។ ប្រាក់បៀវត្សន៍នៃមន្ត្រីរាជការ ក៏ពុំគ្រប់គ្រាន់ដែរក្នុងការផ្តល់នូវកំរិតជីវភាពរស់នៅអោយបានសមរម្យ ដែលជាមូលហេតុមួយធ្វើអោយមន្ត្រីរដ្ឋាភិបាលស្វះស្វែងរកប្រភពចំណូលពីខាងក្រៅ ហើយក្នុងករណីជាច្រើន ដោយរកការងារទីពីរ រឺដោយទទួលយកប្រាក់សំណូក ។

ច្បាប់ស្តីពីការងារចែងថា ស្តង់ដាការងារតាមច្បាប់គឺ ៤៨ម៉ោងក្នុង១សប្តាហ៍ មិនអោយលើស៨ម៉ោងក្នុង១ថ្ងៃ។ ច្បាប់ចែងថា ការធ្វើការបន្ថែមម៉ោងត្រូវទទួលប្រាក់ស្មើនឹង១,៥នៃប្រាក់ខែ ហើយទ្វេដងប្រសិនបើការងារបន្ថែមម៉ោងនោះធ្វើនៅពេលយប់ ថ្ងៃអាទិត្យ រឺថ្ងៃឈប់សំរាក។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលមិនបានអនុវត្តស្តង់ដាទាំងនេះប្រកបដោយប្រសិទ្ធិភាពឡើយ។ កម្មករនិយោជិត នៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់ជាច្រើនបានរាយការណ៍ថា ការធ្វើការបន្ថែមម៉ោងគឺមានលក្ខណៈហួសប្រមាណ ពុំតាមការស្ម័គ្រចិត្ត រឺត្រូវបានបង្ខំអោយធ្វើការ៧ថ្ងៃក្នុង១សប្តាហ៍។ ក្រៅពីឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ បទបញ្ញត្តិទាំងឡាយស្តីពីថិរវេលាធ្វើការកម្រត្រូវបានអនុវត្តណាស់។

ច្បាប់ស្តីពីការងារចែងថា កន្លែងធ្វើការគួរតែមានស្តង់ដាសុខភាព និងសុវត្ថិភាពត្រឹមត្រូវដើម្បីធានា សុខមាលភាពរបស់កម្មករនិយោជិត។ រដ្ឋាភិបាលមិនបានអនុវត្តនូវស្តង់ដាដែល មានស្រាប់ជាទូ

ទៅទេមួយ ផ្អែកដោយសារតែរដ្ឋាភិបាលខ្វះបុគ្គលិកដែលមានការបណ្តុះបណ្តាល និងគ្រឿងបរិក្ខារ។ ការរង របួសដោយ សារការងារ និងបញ្ហាសុខភាពកើតមានច្រើន។ បណ្តារោងចក្រកាត់ដេរធំៗស្ទើរតែទាំងអស់ ដែលផលិត អោយទីផ្សារនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ទាំងឡាយ បានឆ្លើយតបទៅនឹងស្តង់ដាសុវត្ថិភាព និងសុខភាព ខ្ពស់ដែលជាលក្ខខ័ណ្ឌនៃកិច្ចសន្យារបស់ពួកគេជាមួយអ្នកទិញ។ លក្ខខ័ណ្ឌការងារក្នុងរោង ចក្រខ្នាតតូច និង សិប្បកម្មនានាមានភាពខ្សត់ខ្សោយហើយមិនត្រូវតាមស្តង់ដាអន្តរជាតិទេ។ រដ្ឋាភិបាលបាន ចេញសេចក្តីណែ នាំមួយចំនួនស្តីពីស្តង់ដាកន្លែងធ្វើការ ហើយបទបញ្ញត្តិច្បាប់លំអិតពិស្តារ ជាងនេះ រង់ចាំការយល់ព្រមពី គណកម្មការប្រឹក្សាការងារ មុនពេលដែលបទបញ្ញត្តិច្បាប់លំអិត ពិស្តារទាំងនោះត្រូវ បានប្រកាសអោយប្រើ។ ទោសបញ្ញត្តិ ត្រូវបានបញ្ជាក់នៅក្នុងច្បាប់ស្តីពីការងារ ប៉ុន្តែ ពុំមានបទ បញ្ញត្តិជាក់លាក់ណាមួយដើម្បីការពារ កម្មករនិយោជិតដែលត្អូញត្អែពីស្ថានភាពគ្មានសុវត្ថិភាព រឺមានគ្រោះ ថ្នាក់ដល់សុខភាពទេ។ កម្មករនិយោជិត ទាំងឡាយណាដែលចាកចេញពីស្ថានភាពការងារគ្មាន សុវត្ថិភាពត្រូវ ប្រថុយប្រថាននឹងការបាត់បង់ការងារ។

ច្បាប់ស្តីពីការងារអនុវត្ត ទៅលើកម្មករ និយោជិតបរទេសនិងកម្មករនិយោជិតទាំងអស់។ ប្រកាស មួយរបស់ក្រសួងការងារបានកំរិតចំនួនកម្មករនិយោជិតបរទេស ដែលនិយោជកអាចជួលអោយធ្វើការងារ បាន។ ចំនួនដែលបានកំនត់នោះគឺ១០%។